Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា
ខែ ឧសភា ឆ្នាំ 2023

THE WORLD BANK
IBRD • IDA | WORLD BANK GROUP
East Asia & Pacific



# ការស្តារ សេដ្ឋកិច្ចឡើងវិញ ក្រោយវិបត្តិកូវីដ-19

## អត្ថបទផ្តោតពិសេស

ពីការចំណាយកាន់តែច្រើន
ទៅការចំណាយកាន់តែប្រសើរ–
ឆ្ពោះទៅការបង្កើនគុណភាព
អភិវឌ្ឍន៍មនុស្ស

បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា
ខែ ឧសភា ឆ្នាំ 2023

THE WORLD BANK
IBRD • IDA | WORLD BANK GROUP
East Asia & Pacific

# ការស្តារសេដ្ឋកិច្ចឡើងវិញ ក្រោយវិបត្តិកូវីដ-19

## អត្ថបទផ្តោតពិសេស

ពីការចំណាយកាន់តែច្រើន
ទៅការចំណាយកាន់តែប្រសើរ –
ឆ្ពោះទៅការបង្កើនគុណភាព
អភិវឌ្ឍន៍មនុស្ស

# មាតិកា


សេចក្តីថ្លែងអំណរគុណ vi

អក្សរកាត់ vii

## ជំពូក 1 ការអភិវឌ្ឍសេដ្ឋកិច្ច និងទស្សនវិស័យថ្មីៗ 1

ខ្លឹមសារសង្ខេប 1

ការវិវត្តថ្មីៗ 6

តម្រូវការអ្នកប្រើប្រាស់កើនឡើងបានជំរុញវិស័យសេវាកម្ម 6

ការនាំចេញរបស់កម្ពុជាចាប់ផ្តើមធ្លាក់ចុះក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ 7

ការធ្លាក់ចុះនៃការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបមានចំនួន 95 ភាគរយនៃការធ្លាក់ចុះសរុប 9

ចំនួនទុនវិនិយោគសរុបនៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តបានថមថយ 10

ការអនុញ្ញាតសាងសង់បានកើនឡើងជាលើកដំបូងចាប់តាំងពីឆ្នាំ 2019 12

ការងើបឡើងវិញនៃសកម្មភាពទេសចរណ៍កំពុងបង្កើនល្បឿន 13

ផ.ស.ស. វិស័យកសិកម្មត្រូវបានប៉ាន់ប្រមាណថាមានការកើនឡើងតិចតួច 15

ការនាំចេញផលិតផលកសិកម្មមានភាពប្រសើរឡើង 16

ការប្រើប្រាស់របស់អតិថិជនត្រូវបានពង្រឹង ដែលជំរុញដោយកំណើនតម្រូវការអតិថិជន 17

អតិផរណាបានធូរស្រាលខ្លាំង ដោយត្រឡប់ទៅកម្រិតមុនវិបត្តិ 17

សមតុល្យគណនីចរន្តមានភាពប្រសើរឡើង ដោយសារការធូរស្រាលនៃវិបត្តិតម្លៃប្រេង 18

កំណើនសាច់ប្រាក់ជារួមបានបន្តថមថយ 19

កំណើនឥណទានបានធ្លាក់ចុះយ៉ាងខ្លាំង ប៉ុន្តែនៅតែមានការប្រមូលផ្តុំឥណទាននៅក្នុងវិស័យអចលនទ្រព្យ 19

សម្ពាធលើអត្រាការប្រាក់ក្នុងស្រុកបានបន្ត 20

ប្រព័ន្ធធនាគារនៅតែមានភាពធន់ 21




ចំណូលក្នុងស្រុកបានងើបឡើងវិញពេញលេញ និងបន្តកើនឡើង 21

ទោះបីជាមានការខិតខំប្រឹងប្រែងក្នុងការពង្រឹងផ្នែកសារពើពន្ធក៏ដោយ ការចំណាយបានកើនឡើងតិចតួច 22

ការដំឡើងប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈទូទាំងប្រទេសបានចាប់ផ្តើមឡើងវិញ 23

ឱនភាពសារពើពន្ធកាលពីឆ្នាំមុនត្រូវបានប៉ាន់ប្រមាណថាបានរួមតូចមកត្រឹម 4.7 ភាគរយនៃ ផ.ស.ស. 24

បំណុលសាធារណៈបានកើនឡើងដល់ 33.7 ភាគរយនៃ ផ.ស.ស.ដែលក្នុងនោះ 99.8 ភាគរយ ជាបំណុលខាងក្រៅ 24

## ជំពូក 2 អត្ថបទផ្តោតពិសេស 29

ពីការចំណាយកាន់តែច្រើន ទៅការចំណាយកាន់តែប្រសើរ – ឆ្ពោះទៅការបង្កើនគុណភាពអភិវឌ្ឍន៍មនុស្ស 29

សេចក្តីផ្តើម 29

ចំណូលក្នុងស្រុកដ៏រឹងមាំបានគាំទ្រនូវការពង្រីកចំណាយសាធារណៈ 30

ភាពទូលំទូលាយនៃលំហសារពើពន្ធបានអនុញ្ញាតិឱ្យមានការចំណាយកាន់តែខ្ពស់ ជាពិសេសក្នុងវិស័យសង្គម 31

បន្ទាប់ពីការធ្វើកំណែទម្រង់ និងការដំឡើងប្រាក់បៀវត្សរ៍រយៈពេលមួយទសវត្សរ៍កន្លងមក បៀវត្សរ៍ជាមធ្យម ក្នុងវិស័យសាធារណៈ បច្ចុប្បន្នលើសពីប្រាក់ខែជាមធ្យមរបស់វិស័យឯកជន 32

ការចំណាយនៅក្នុងវិស័យអប់រំបានកើនឡើង ប៉ុន្តែនៅមិនទាន់ធ្វើឱ្យលទ្ធផលសិក្សាប្រសើរឡើងនៅឡើយទេ 36

ប្រសិទ្ធភាពនៃគោលនយោបាយសុខភាពសាធារណៈត្រូវបានរឹតត្បិតដោយការចំណាយទាបលើសុខភាពសាធារណៈ អត្រានៃការប្រើប្រាស់មណ្ឌលសុខាភិបាលសាធារណៈទាប និងកម្រិតខ្ពស់នៃការចំណាយលុយហោប៉ៅ 41

## សេចក្តីសន្និដ្ឋាន និង អនុសាសន៍ 48

ឧបសម្ព័ន្ធទី 1៖ កម្ពុជា – សូចនាករដែលបានជ្រើសរើស 50

គន្ថនិទ្ទេស 52




# ប្រអប់


| | | |
|---|---|---|
| ប្រអប់ 1 | ការអភិវឌ្ឍសេដ្ឋកិច្ចសកល និងទស្សនវិស័យ | 8 |
| ប្រអប់ 2 | តើមានអ្វីបន្ថែមទៀតដែលអាចធ្វើបានដើម្បីកែលម្អការរួមចំណែកនៃការវិនិយោគផ្ទាល់ពីបរទេសដល់សេដ្ឋកិច្ច? | 11 |
| ប្រអប់ 3 | ការតភ្ជាប់ "ប៉ូលសេដ្ឋកិច្ចទីបួន" ទៅកាន់ច្រកទ្វារអន្តរជាតិ | 14 |
| ប្រអប់ S.1. | ការចំណាយក្រោមជំពូក 62 (ការចំណាយអត្ថប្រយោជន៍សង្គម) | 42 |


# រូបភាព


| | | |
|---|---|---|
| រូបភាព ES.1 | ការវិវឌ្ឍថ្មីៗរបស់ប្រទេសកម្ពុជាដោយសង្ខេប | 5 |
| រូបភាព 1 | ការងើបឡើងវិញនៃសេដ្ឋកិច្ចមានភាពកាន់តែរឹងមាំ | 6 |
| រូបភាព 2 | ការនាំចេញបានធ្លាក់ចុះ | 7 |
| រូបភាព B1.1 | អតិផរណា | 8 |
| រូបភាព B1.2 | កំណើនសក្តានុពល | 8 |
| រូបភាព 3 | ការរួមចំណែកដល់កំណើននៃការនាំចេញ | 9 |
| រូបភាព 4 | ការធ្វើពិពិធកម្មការនាំចេញបានបន្ត | 9 |
| រូបភាព 5 | ចំណង់នៃការវិនិយោគបានធូរស្រាល | 10 |
| រូបភាព 6 | គម្រោងដែលផ្តល់ហិរញ្ញប្បទានដោយការវិនិយោគផ្ទាល់ពីបរទេសដែលបានអនុម័ត តាមវិស័យ | 10 |
| រូបភាព B2.1 | កំណើននៃការទាញកម្លាំងពលកម្មពីប្រទេស ជិតខាង និងពិពិធកម្មនៃខ្សែសង្វាក់ផ្គត់ផ្គង់ | 11 |
| រូបភាព B2.2 | ការវិនិយោគផ្ទាល់ពីបរទេស របស់កម្ពុជាតាមវិស័យ | 11 |
| រូបភាព 7 | តម្លៃការអនុញ្ញាតសាងសង់ដែលបានអនុម័តបានកើនឡើង | 13 |
| រូបភាព 8 | បរិមាណនៃការនាំចូលសម្ភារៈសំណង់នៅមានកម្រិតទាប | 13 |
| រូបភាព B 3.1 | ប៉ូលសេដ្ឋកិច្ចទីបួន | 14 |
| រូបភាព 9 | ការមកដល់នៃភ្ញៀវអន្តរជាតិ និងចំណូលបានពីការលក់សំបុត្រទស្សនាអង្គរបានងើបឡើងវិញយ៉ាងឆាប់រហ័ស | 16 |
| រូបភាព 10 | ការនាំចេញផលិតផលកសិកម្ម - សក្តានុពលកែច្នៃកសិផលដែលមិនបានអនុវត្ត | 16 |
| រូបភាព 11 | អតិផរណាបានធូរស្រាលបន្ទាប់ពីការកើនឡើងខ្ពស់ | 17 |
| រូបភាព 12 | អតិផរណានៅក្នុងប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា | 17 |
| រូបភាព 13 | គណនីចរន្តមានភាពប្រសើរឡើង | 18 |
| រូបភាព 14 | អត្រាប្តូរប្រាក់រៀល-ដុល្លារអាមេរិក ស្ថិតក្រោមសម្ពាធ | 18 |
| រូបភាព 15 | កំណើនសាច់ប្រាក់ជារួមបានថយចុះ | 19 |
| រូបភាព 16 | ការប្រមូលផ្តុំឥណទាននៅក្នុងវិស័យអចលនទ្រព្យ | 19 |
| រូបភាព 17 | អត្រាការប្រាក់ក្នុងស្រុកបានបន្តកើនឡើង | 20 |
| រូបភាព 18 | អនុបាតនៃការគ្របដណ្តប់សន្ទនីយភាពរបស់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | 21 |
| រូបភាព 19 | ការរួមចំណែកដល់កំណើនប្រាក់ចំណូលក្នុងស្រុក | 21 |
| រូបភាព 20 | ការចំណាយថវិកាបានថយចុះ នៅពេលដែលមានកិច្ចខិតខំប្រឹងប្រែងពង្រឹងលំហសារពើពន្ធ | 22 |
| រូបភាព 21 | ឱនភាពរដ្ឋាភិបាលទូទៅ | 24 |
| រូបភាព 22 | អតិរេក/ឱនភាព និងហិរញ្ញប្បទានរបស់រដ្ឋាភិបាលទូទៅ | 24 |
| រូបភាព S.1 | ថវិកាសរុបរបស់រដ្ឋាភិបាលនៅថ្នាក់ជាតិ តាមប្រភេទ (លានរៀល) ឆ្នាំ 2011-21 | 29 |
| រូបភាព S.2 | ចំណូល និងចំណាយសរុបរបស់រដ្ឋាភិបាលកើនឡើងក្នុងឆ្នាំ 2011-22 | 30 |
| រូបភាព S.3 | ថវិកាសរុបរបស់រដ្ឋាភិបាលបានកើនឡើងចន្លោះឆ្នាំ 2011 និង 2022 | 31 |
| រូបភាព S.4 | ប្រាក់បៀវត្សរ៍ជាមធ្យមប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលកម្ពុជា ឆ្នាំ2021 | 32 |

| | | |
|---|---|---|
| រូបភាព S.5 | ប្រវត្តិនៃការចំណាយប្រាក់បៀវត្សរ៍មន្ត្រីរាជការសាធារណៈ | 32 |
| រូបភាព S.6 | បុព្វលាភប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈ | 33 |
| រូបភាព S.7 | បុព្វលាភប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈរបស់កម្ពុជាក្នុងពេលកន្លងមក | 33 |
| រូបភាព S.8 | បុព្វលាភប្រាក់បៀវត្សរ៍តាមកម្រិតអប់រំ | 34 |
| រូបភាព S.9 | បុព្វលាភប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈ តាមក្រុមមុខរបរ | 34 |
| រូបភាព S.10 | គម្លាតប្រាក់បៀវត្សរ៍យេនឌ័រនៅកម្ពុជា | 35 |
| រូបភាព S.11 | ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃថវិកាក្រសួងអប់រំ យុវជន និងកីឡា | 36 |
| រូបភាព S.12 | ចំណាយចរន្ត និងចំណាយមូលធនរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ 2017-21 | 37 |
| រូបភាព S.13 | ផែនការចំណាយមូលធន និងលទ្ធផលថវិកា | 38 |
| រូបភាព S.14 | ការចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំ៖ ភាគរយនៃ ផ.ស.ស. ធៀបនឹងចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ ឆ្នាំ2021 | 38 |
| រូបភាព S.15 | អត្រាចុះឈ្មោះចូលរៀនសុទ្ធ ទីក្រុង និងជនបទ 2009-2019/20 | 39 |
| រូបភាព S.16 | អត្រាអក្ខរកម្មនៅកម្ពុជា និងធៀបនឹងប្រទេសអាស៊ានដទៃទៀត | 39 |
| រូបភាព S.17 | លទ្ធផលសិក្សាសម្រាប់ថ្នាក់ទី 6 ឆ្នាំ 2013-21 | 40 |
| រូបភាព S.18 | ភាគរយនៃសិស្សថ្នាក់ទី 8 ដែលស្ទាត់ជំនាញក្នុងការអាន និងគណិតវិទ្យាជាភាសាខ្មែរ ឆ្នាំ 2014-17 | 40 |
| រូបភាព S.19 | ការចំណាយថវិការបស់ក្រសួងសុខាភិបាល ឆ្នាំ 2017-22 | 41 |
| រូបភាព S.20 | ថវិកាក្រសួងសុខាភិបាល តាមប្រភេទ (% នៃថវិកាសរុប) ឆ្នាំ 2017-22 | 41 |
| រូបភាព S.21 | ថវិកាចរន្តរបស់ក្រសួងសុខាភិបាល តាមចំណាត់ថ្នាក់សេដ្ឋកិច្ច (លានរៀល) ឆ្នាំ 2017-21 | 42 |
| រូបភាព S.22 | ថវិការបស់ក្រសួងសុខាភិបាលលើការចំណាយអត្ថប្រយោជន៍សង្គម តាមចំណាត់ថ្នាក់សេដ្ឋកិច្ច (លានរៀល) ឆ្នាំ 2017-21 | 42 |
| រូបភាព S.23 | ការចំណាយលើវិស័យសុខាភិបាលរបស់កម្ពុជាធៀបនឹងបណ្តាប្រទេសអាស៊ានផ្សេងទៀត តាមមុខងារថែទាំសុខភាព (% ការចំណាយលើវិស័យសុខាភិបាលរបស់រដ្ឋាភិបាល) ឆ្នាំ 2019 | 43 |
| រូបភាព S.24 | ប្រភេទអ្នកផ្តល់សេវាសុខភាពបានពិគ្រោះយោបល់ជាមុន | 43 |
| រូបភាព S.25 | ចំណាយវិស័យសុខាភិបាល (% នៃ ផ.ស.ស.) | 44 |
| រូបភាព S.26 | ចំណាយវិស័យសុខាភិបាលទូទៅរបស់រដ្ឋាភិបាលក្នុងមនុស្សម្នាក់, អំណាចទិញ | 44 |
| រូបភាព S.27 | ចំណាយវិស័យសុខាភិបាលទូទៅរបស់រដ្ឋាភិបាលក្នុងស្រុក | 44 |
| រូបភាព S.28 | ហិរញ្ញប្បទានសុខភាពកម្ពុជា និងការពឹងផ្អែកលើការចំណាយលុយហោប៉ៅ ឆ្នាំ 2000-20 | 45 |
| រូបភាព S.29 | និន្នាការនៃការគ្របដណ្តប់វ៉ាក់សាំង និងមរណភាពកុមារ | 46 |
| រូបភាព S.30 | អាយុសង្ឃឹមរស់ និងអត្រាមរណៈរបស់កុមារប្រទេសកម្ពុជាធៀបនឹងបណ្តាប្រទេសអាស៊ាន | 46 |
| រូបភាព S.31 | អត្រាមរណភាពទារក និងកុមារអាយុក្រោម 5 ឆ្នាំ ទីក្រុងធៀបនឹងជនបទ | 47 |
| រូបភាព S.32 | អត្រាមរណៈទារក និងកុមារអាយុក្រោម 5 ឆ្នាំ អ្នកមានបំផុតធៀបនឹងអ្នកក្រីក្របំផុត | 47 |

# តារាង

| | | |
|---|---|---|
| តារាង ES1 | ការព្យាករណ៍កំណើនពិត | 3 |
| តារាង B2.1 | គោលនយោបាយវិនិយោគ | 12 |
| តារាង B3.1 | ខេត្តផលិតដំណាំនៅភាគពាយ័ព្យសំខាន់ៗ | 14 |
| តារាង 1 | បំណុលសាធារណៈ ប្រាក់កម្ចីដែលបានចុះហត្ថលេខាខ្ចីថ្មីៗ និងការចំណាយប្រាក់កម្ចី | 25 |
| តារាង 2 | ទស្សនវិស័យម៉ាក្រូបង្ហាញពីការបន្តងើបឡើងវិញនៃសេដ្ឋកិច្ច | 26 |
| តារាង S.1 | សង្ខេប អនុសាសន៍ទាំងនេះ | 49 |

# សេចក្តីថ្លែងអំណរគុណ


**បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា (CEU) ខែឧសភា ឆ្នាំ 2023 ត្រូវបានរៀបចំដោយលោក លី សូដេត លោក Serdar Yilmaz លោក សូ សុខប៊ុនធឿន និង លោក ទូក ឃី ដោយមានការរួមចំណែកពីលោក Samuel Christopher Hill, Peter Kusek, Gerlin May U. Catangui, លោក ភឹម រុនស៊ីណារិទ្ធ Lindley Higgins, Paul Jacob Robyn, Kimsun Tong, Fata No, Flavia Giannina Sacco Capurro និង Tim L. De Vaan. លោកស្រី Chankesey Heav មានតួនាទីជាជំនួយការស្រាវជ្រាវ។** ហេង សៀកហ៊ាង ផ្តល់ជំនួយផ្នែករដ្ឋបាល។ លោក ប៊ូ សារឿន ជួយគាំទ្រលើការធ្វើសេចក្តីប្រកាសព័ត៌មាន ការបង្ហាញលើគេហទំព័រ និងព្រឹត្តិការណ៍ផ្សព្វផ្សាយនានា។

**ក្រុមការងារនេះបានធ្វើការក្រោមការណែនាំរួមរបស់លោក Sebastian Eckardt និង Alma Kanani ។** ក្រុមការងារសូមថ្លែងអំណរគុណចំពោះការណែនាំ និងមតិយោបល់ ដែលផ្តល់ដោយលោក Hassan Zaman លោកស្រី Mariam Sherman និងលោកស្រី Maryam Salim ។ សហសេវិកជាច្រើនដែលបានចូលរួមផ្តល់មតិលើកំណែពង្រាងរួមមាន Aaditya Mattoo, Ergys Islamaj និង Kim Alan Edwards ។

**ក្រុមការងារសូមថ្លែងអំណរគុណចំពោះអាជ្ញាធរកម្ពុជា ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ដែលបានផ្តល់កិច្ចសហការ និងការគាំទ្រ។** របាយការណ៍នេះក៏ទទួលបានដំបូន្មាន យោបល់ និងទស្សនៈរបស់អ្នកពាក់ព័ន្ធផ្សេងៗនៅក្នុងប្រទេសកម្ពុជា រួមទាំងអ្នកនិយមការអាន និងអ្នកធ្វើវិវេចនា។

**បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ដែលត្រូវបានផលិតជារៀងរាល់ឆ្នាំ ផ្តល់ព័ត៌មានថ្មីៗអំពីការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។** របាយការណ៍នេះត្រូវបានចែកចាយ និងពិភាក្សាយ៉ាងទូលំទូលាយរួមទាំងក្នុងចំណោមអាជ្ញាធរកម្ពុជា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ក្រុមជំនាញ (think tank) អង្គការសង្គមស៊ីវិល និងផ្នែកសិក្សាស្រាវជ្រាវ។

**សម្រាប់ព័ត៌មានអំពីធនាគារពិភពលោក និងសកម្មភាពរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា សូមចូលទៅកាន់គេហទំព័ររបស់យើងតាមរយៈ www.worldbank.org/cambodia ។**

**ដើម្បីបញ្ចូលទៅក្នុងបញ្ជីចែកចាយតាមអ៊ីមែលសម្រាប់បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា និងការបោះពុម្ពផ្សាយដែលពាក់ព័ន្ធ សូមទាក់ទង ហេង សៀកឃាង (sheng4@worldbank.org)។** សម្រាប់សំណួរអំពីខ្លឹមសារនៃការបោះពុម្ពផ្សាយនេះ សូមទាក់ទងលោក ប៊ូ សារឿន (sbou@worldbank.org)។

**លទ្ធផល ការបកស្រាយ និងសេចក្តីសន្និដ្ឋានដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ មិនតម្រូវឱ្យឆ្លុះបញ្ចាំងពីទស្សនៈរបស់នាយកប្រតិបត្តិនៃធនាគារពិភពលោក ឬរដ្ឋាភិបាលដែលពួកគេតំណាងនោះទេ។** ធនាគារពិភពលោកមិនធានាចំពោះសុក្រិតភាពទិន្នន័យដែលបានដាក់បញ្ចូលនៅក្នុងការបោះពុម្ពផ្សាយនេះទេ។ ព្រំដែន ពណ៌ ខ្នាត និងព័ត៌មានផ្សេងទៀតដែលបង្ហាញនៅលើផែនទីនៅក្នុងការបោះពុម្ពផ្សាយនេះមិនបញ្ជាក់ពីការវិនិច្ឆ័យណាមួយរបស់ធនាគារពិភពលោកទាក់ទងនឹងស្ថានភាពផ្លូវច្បាប់នៃរដ្ឋ ឬដែនដីណាមួយ ឬការយល់ព្រម ឬការទទួលយកព្រំដែននោះទេ។




# អក្សរកាត់

| | |
|---|---|
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) |
| CEU | បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា |
| COVID-19 | ជំងឺកូរ៉ូណាវីរុសឆ្នាំ 2019 (កូវីដ-19) |
| CPI | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ |
| CR | ប្រាក់រៀលកម្ពុជា |
| CSES | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា |
| DP | ដៃគូអភិវឌ្ឍន៍ |
| EAP | តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក |
| EMDEs | ទីផ្សារដែលកំពុងរីកលូតលាស់ និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ |
| EU | សហភាពអឺរ៉ុប |
| FDI | ការវិនិយោគដោយផ្ទាល់ពីបរទេស |
| FED | ធនាគារកណ្តាលអាមេរិក |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GTF | សម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | ក្រសួងសុខាភិបាល |
| NSSF | បេឡាជាតិរបបសន្តិសុខសង្គម |
| OOP | ការចំណាយលុយហោប៉ៅ |
| PISA-D | កម្មវិធីវាយតម្លៃនិស្សិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ |
| Q.I.P | គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ |
| U.S. | សហរដ្ឋអាមេរិក |
| USD | ប្រាក់ដុល្លារអាមេរិក |
| VAT | អាករលើតម្លៃបន្ថែម |
| YTD | រហូតដល់បច្ចុប្បន្ន/ឆ្នាំនេះ |
| ឆ្នាំ/ឆ្នាំ | ធៀបនឹងមួយឆ្នាំមុន |


CHENGLONG
MAERSK
MINH AN
70H 014.61

# ជំពូក 1
# ការអភិវឌ្ឍសេដ្ឋកិច្ច និងទស្សនវិស័យថ្មីៗ

## ខ្លឹមសារសង្ខេប

### ការអភិវឌ្ឍថ្មីៗ

**ការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជាមានសភាពរឹងមាំនៅឆ្នាំ 2022 ជាមួយនឹងកំណើន 5.2 ភាគរយ។** បន្ទាប់ពីការផ្លាស់ប្តូរទៅ "រស់នៅជាមួយមេរោគកូវីដ-19" នៅចុងឆ្នាំ 2021 សេដ្ឋកិច្ចកំពុងស្ថិតនៅលើផ្លូវឆ្ពោះទៅរកការងើបឡើងវិញយ៉ាងរឹងមាំ ហើយបច្ចុប្បន្នបានត្រលប់ទៅគន្លងកំណើនមុនវិបត្តិកូវីដ-19។

**ដំបូងជំរុញដោយភាពរឹងមាំនៃផលិតកម្មដែលផ្តោតលើការនាំចេញ បច្ចុប្បន្នកត្តាជំរុញកំណើនកំពុងបង្វែរទិសដៅទៅកាន់វិស័យសេវាកម្ម និងកសិកម្ម។** ដោយសារកំណើនតម្រូវការអ្នកប្រើប្រាស់ ការរួមចំណែកជាទូទៅនៃវិស័យសេវាកម្មចំពោះកំណើនសេដ្ឋកិច្ចកំពុងត្រឡប់ទៅកម្រិតឆ្នាំ 2019 វិញ។ ក្រោយការដកចេញទាំងស្រុងនូវការរឹតបន្តឹងការធ្វើដំណើរដោយសារជំងឺកូវីដ-19 និងបន្ទាប់ពីការបើកប្រទេសចិនឡើងវិញនាពេលថ្មីៗនេះ ការមកដល់របស់ភ្ញៀវអន្តរជាតិបានកើនឡើងដល់ 830,000 នាក់ ក្នុងអំឡុងពេលពីរខែដំបូងនៃឆ្នាំ 2023 ដែលខិតជិតដល់កម្រិតមុនការរាតត្បាតនៃជំងឺ។

**ទន្ទឹមនឹងនេះ វិស័យកសិកម្មកំពុងទទួលបានអត្ថប្រយោជន៍ពីការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពចូលទៅកាន់ទីផ្សារក្នុងតំបន់ដោយសារកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងកិច្ចព្រមព្រៀងតំបន់ដែលកម្ពុជាទើបបានផ្តល់សច្ចាប័ន។** ក្រៅពីទំនិញកសិកម្មបែបប្រពៃណីដូចជា អង្ករ ដំឡូងមី និងកៅស៊ូ ការនាំចេញស្វាយ និងចេកស្រស់ ជាពិសេសទៅកាន់ទីផ្សារប្រទេសចិនបានលេចចេញជារូបរាងឡើង។ ការនាំចេញចេកបានកើនឡើងយ៉ាងឆាប់រហ័សដល់ 182 លានដុល្លារក្នុងឆ្នាំ 2022 កើនឡើងពី 49.3 លានដុល្លារក្នុងឆ្នាំ 2019។ វាក៏មានសញ្ញានៃការកើនឡើងនៅក្នុងវិស័យសំណង់ និងអចលនទ្រព្យ ដែលជាកត្តាសំខាន់ បើទោះបីវាមិនមែនជាកត្តាជំរុញកំណើនប្រកបដោយនិរន្តរភាពមុនវិបត្តិកូវីដ-19 ក៏ដោយ។ ខណៈពេលដែលភាពមិនច្បាស់លាស់នៅក្នុងទីផ្សារលំនៅដ្ឋាននៅតែមានកម្រិតខ្ពស់ តម្លៃការអនុញ្ញាតសាងសង់បានចាប់ផ្តើមកើនឡើងជាលើកដំបូងចាប់តាំងពីវិបត្តិកូវីដ-19 ដែលឈានដល់ 802 លានដុល្លារអាមេរិក ឬកើនឡើង 484 ភាគរយ ឆ្នាំ/ឆ្នាំ (ធៀបនឹងមួយឆ្នាំមុន) ក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ 2023។

**ទោះជាយ៉ាងណាក៏ដោយ ការចុះខ្សោយនៃតម្រូវការខាងក្រៅកំពុងចាប់ផ្តើមដាក់សម្ពាធលើការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា។** កំណើនសេដ្ឋកិច្ចសកលកំពុងធ្លាក់ចុះយ៉ាងខ្លាំង ខណៈអតិផរណាកើនឡើង អត្រាការប្រាក់កាន់តែខ្ពស់ ការវិនិយោគត្រូវបានកាត់បន្ថយ និងការរំខានដែលបណ្តាលមកពីការឈ្លានពានរបស់រុស្ស៊ីលើប្រទេសអ៊ុយក្រែន។ ដោយសារការធ្លាក់ចុះនៃការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ការនាំចេញសរុបបានបានធ្លាក់ចុះមកនៅ 14.2 ភាគរយ ឆ្នាំ/ឆ្នាំ ក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ 2023 ធៀបនឹងអត្រាកំណើនជាមធ្យម 6.7 ភាគរយក្នុងឆ្នាំ 2019។ ក្នុងចំណោមការធ្លាក់ចុះ 14.5 ភាគរយ ការនាំចេញសម្លៀកបំពាក់រួមចំណែកធំបំផុត គឺ 11.8 ពិន្ទុភាគរយ។ តម្លៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តក៏ធ្លាក់ចុះមកត្រឹម 156 លានដុល្លារអាមេរិក ដោយធ្លាក់ចុះមកនៅ 92.3 ភាគរយក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ 2023។ ក្នុងចំណោមទឹកប្រាក់សរុប 156 លានដុល្លារនោះ 83 លានដុល្លារ (60 ភាគរយ) ជាការវិនិយោគក្នុងឧស្សាហកម្មកាត់ដេរ ខណៈ 73 លានដុល្លារ (40 ភាគរយ) ទៀតជាការវិនិយោគលើការផលិតទំនិញធ្វើដំណើរ ស្បែកជើង និងឧស្សាហកម្មវេចខ្ចប់។

**ទោះបីជាការនាំចេញចុះខ្សោយក៏ដោយ សមតុល្យគណនីចរន្តកំពុងមានភាពប្រសើរឡើង ដោយសារការស្ទុះងើបឡើងវិញនៃឧស្សាហកម្មធ្វើដំណើរ និងទេសចរណ៍ និងការផ្ញើប្រាក់ពីបរទេស ទន្ទឹមនឹងនោះ វិបត្តិតម្លៃប្រេងក៏មានភាពធូរស្រាល។** នៅឆ្នាំ 2022 ឱនភាពគណនីចរន្តបានប្រសើរឡើងដល់ប្រមាណ 26.3 ភាគរយនៃ ផ.ស.ស. (GDP) ខណៈឱនភាពពាណិជ្ជកម្មបានរួមតូចដោយសារភាពរឹងមាំនៃការនាំចេញ។ សមតុល្យគណនីចរន្តត្រូវបានបន្តផ្តល់ហិរញ្ញប្បទានជាចម្បងដោយលំហូរចូលនៃមូលធន និងទុនបម្រុងអន្តរជាតិ។ ដូច្នេះ ទុនបម្រុងអន្តរជាតិសរុបបានធ្លាក់ចុះមកត្រឹម 17.7 ពាន់លានដុល្លារអាមេរិក ដែលគ្របដណ្តប់ប្រហែល 7 ខែនៃការនាំចូលក្នុងខែកុម្ភៈ ឆ្នាំ 2023 ធ្លាក់ចុះពី 20.3 ពាន់លានដុល្លារក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ 2022។

**អតិផរណាបានធូរស្រាលយ៉ាងខ្លាំង ខណៈដែលអត្រាប្តូរប្រាក់មានស្ថិរភាព ដែលគាំទ្រការប្រើប្រាស់ក្នុងស្រុក។** សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ (CPI) របស់កម្ពុជាបានធ្លាក់ចុះមកនៅត្រឹម 2.2 ភាគរយ ឆ្នាំ/ឆ្នាំ ក្នុងខែកុម្ភៈ ឆ្នាំ 2023 បន្ទាប់ពីឡើងដល់ 7.8 ភាគរយ ឆ្នាំ/ឆ្នាំ ក្នុងខែមិថុនា ឆ្នាំ 2022 ដោយសារស្ថិរភាពតម្លៃ

ថាមពល និងអាហារ។ ដោយសារការអនុវត្តទីផ្សារបើកចំហរបស់ធនាគារកណ្តាល អត្រាប្តូរប្រាក់មានស្ថិរភាពយ៉ាងទូលំទូលាយ ដោយរក្សានៅតម្លៃប្រមាណ 4,100 រៀលក្នុងមួយដុល្លារអាមេរិក។ ការថមថយអតិផរណាបានជួយជំរុញការប្រើប្រាស់ក្នុងស្រុក។ ក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ 2023 ការនាំចូលទំនិញប្រើប្រាស់បានកើនឡើង ដូចជាប្រេងសាំង 28.1 ភាគរយ អាល់កុល 16.7 ភាគរយ ប្រេងចម្អិនអាហារ 79.7 ភាគរយ និងស្ករ 49.6 ភាគរយ ឆ្នាំ/ឆ្នាំ រៀងគ្នា។ ដូចគ្នានេះដែរ តម្លៃនៃការនាំចូលទំនិញប្រើប្រាស់បានយូរ ដូចជារថយន្តដឹកអ្នកដំណើរ និងរថយន្តក្រុងបានកើនឡើងដល់ 6.6 ភាគរយ និង 127.1 ភាគរយរៀងគ្នា ឆ្នាំ/ឆ្នាំ។

**ស្ថានភាពហិរញ្ញវត្ថុកាន់តែតឹងតែង ដោយសារកម្ពុជា "ស្ថិតក្រោម" គោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក ដោយសារសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់។** ការកើនឡើងអត្រាការប្រាក់របស់សហរដ្ឋអាមេរិកបានជំរុញឱ្យអត្រាការប្រាក់ក្នុងស្រុកកើនឡើង។ អត្រាប្រាក់បញ្ញើ និងកម្ចីប្រាក់ដុល្លារអាមេរិករយៈពេល 12 ខែ (ជាមធ្យម) បានកើនឡើងដល់ 5.54 ភាគរយ និង 10.19 ភាគរយរៀងគ្នា នៅក្នុងខែកុម្ភៈ ឆ្នាំ 2023 កើនឡើងពី 3.94 ភាគរយ និង 9.51 ភាគរយ រៀងគ្នាក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022 ។ ដោយសារភាពយឺតយ៉ាវក្នុងការផ្លាស់ប្តូរគោលនយោបាយរូបិយវត្ថុ លទ្ធផលពីសកម្មភាពនៃការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុបច្ចុប្បន្នមិនទាន់សម្រេចបានទាំងស្រុងនៅឡើយទេ។ ទៅអនាគត វដ្តនៃការរឹតបន្តឹងទំនងជានឹងប៉ះពាល់ដល់ការវិនិយោគ និងការចំណាយរបស់អ្នកប្រើប្រាស់។

**កំណើនសាច់ប្រាក់ជារួមបានធ្លាក់ចុះមកត្រឹម 6.8 ភាគរយ ឆ្នាំ/ឆ្នាំ ក្នុងខែកុម្ភៈ ឆ្នាំ 2023 ចុះពី 14.5 ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022 ដែលអាចបណ្តាលមកពីភាពតានតឹងនៃស្ថានភាពហិរញ្ញវត្ថុពិភពលោក។** ការធ្លាក់ចុះនៃកំណើនសាច់ប្រាក់ជារួមត្រូវបានជំរុញជាចម្បងដោយការថមថយកំណើនប្រាក់បញ្ញើរូបិយប័ណ្ណបរទេស ដែលឆ្លុះបញ្ចាំងឱ្យឃើញពីលំហូរចូលយឺតជាងមុននៃមូលធន។ ការរួមចំណែកនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសដែលជាចំណែកសំខាន់ជាង 80 ភាគរយនៃសាច់ប្រាក់ជារួម បានធ្លាក់ចុះមកត្រឹម 5.7 ពិន្ទុភាគរយនៅក្នុងខែកុម្ភៈ ឆ្នាំ 2023 ចុះពី 11.7 ពិន្ទុភាគរយក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ 2022 ។ ដូចគ្នានេះដែរ កំណើនប្រាក់បញ្ញើរបស់វិស័យឯកជនបានធ្លាក់ចុះពាក់កណ្តាល ដោយបានធ្លាក់ចុះមកត្រឹម 7.5 ភាគរយ ឆ្នាំ/ឆ្នាំ ក្នុងខែកុម្ភៈ ឆ្នាំ 2023 ចុះពី 15.8 ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022។ ទោះបីវានៅមានភាពរឹងមាំ និងលូតលាស់លឿនជាងអត្រាកំណើន ផ.ស.ស. ចារីកក៏ដោយ កំណើនឥណទានក្នុងស្រុកក៏បានថមថយផងដែរ មកនៅត្រឹម 14.8 ភាគរយ ឆ្នាំ/ឆ្នាំ ក្នុងខែកុម្ភៈ ឆ្នាំ 2023 ធ្លាក់ចុះពី 22.6 ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022 ដោយសារការកើនឡើងនៃថ្លៃដើមនៃកម្ចី។

**ការងើបឡើងវិញនៃសេដ្ឋកិច្ច និងការគ្រប់គ្រងចំណូលបានល្អបានជំរុញឱ្យមានការកែលម្អគ្រប់ផ្នែកនៃការប្រមូលចំណូលក្នុងស្រុក។** នៅឆ្នាំ 2022 ការប្រមូលចំណូលរដ្ឋជារួមបានកើនឡើងខ្ពស់ ក្នុងកំណើន 19.5 ភាគរយ ដែលជួយគ្រប់គ្រងឱនភាពសារពើពន្ធ ដែលត្រូវបានប៉ាន់ស្មានថាបានរួមតូចមកត្រឹម 4.7 ភាគរយនៃ ផ.ស.ស.។ ជាលទ្ធផល ប្រាក់បញ្ញើរបស់រដ្ឋាភិបាល (ទុនបម្រុងសារពើពន្ធ) បានកើនឡើងដល់ 17.8 ភាគរយនៃ ផ.ស.ស. (21.9 ទ្រីលានរៀល) កើនឡើងពី 17.6 ភាគរយនៃ ផ.ស.ស. (19.5 ទ្រីលានរៀល)។ ក្នុងទស្សវត្សរ៍ចុងក្រោយនេះ ការធ្វើឱ្យប្រសើរឡើងនៃលំហសារពើពន្ធដែលកើតចេញពីកំណើនយ៉ាងឆាប់រហ័សនៃចំណូលក្នុងស្រុក បានអនុញ្ញាតឱ្យរដ្ឋាភិបាលបង្កើនការចំណាយក្នុងវិស័យសុខាភិបាល និងអប់រំ។ លើសពីនេះ ការបង្កើនការវិភាជថវិការបស់កម្ពុជាត្រូវបានជំរុញមួយផ្នែកដោយការដំឡើងប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីរាជការទូទៅ។ ប្រាក់បៀវត្សរ៍ប្រចាំខែរបស់វិស័យសាធារណៈជាមធ្យមគឺខ្ពស់ជាងប្រាក់បៀវត្សរ៍របស់វិស័យឯកជន។ បច្ចុប្បន្នកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលមានអត្រានៃចំណូលរដ្ឋខ្ពស់បំផុតចំណាយលើប្រាក់បៀវត្សរ៍មន្ត្រីសាធារណៈ (សូមមើលអត្ថបទផ្តោតពិសេស)។

**រដ្ឋាភិបាលបានបន្តផ្តល់ជំនួយសាច់ប្រាក់សម្រាប់គ្រួសារក្រីក្រ និងងាយរងគ្រោះ ទោះបីជាស្ថានភាពដ៏អាក្រក់នៃជំងឺកូវីដ-19 ត្រូវបានបញ្ចប់ហើយក៏ដោយ។** ក្នុងន័យនេះ រដ្ឋាភិបាលកម្ពុជាបានបន្តកម្មវិធីជំនួយសាច់ប្រាក់សម្រាប់ជំងឺកូវីដ-19 បន្ថែមទៀត ជាមួយនឹងថវិកាបន្ថែមប្រមាណ 400លានដុល្លារអាមេរិក។ គិតត្រឹមខែមីនា ឆ្នាំ 2023 កម្មវិធីនេះបានបញ្ចេញថវិកាចំនួន 994 លានដុល្លារអាមេរិក គិតចាប់ពីពេលចាប់ផ្តើមកម្មវិធីក្នុងខែមិថុនា ឆ្នាំ 2020។ លើសពីនេះ រដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីជំនួយសាច់ប្រាក់ថ្មីសម្រាប់គ្រួសារដែលមានហានិភ័យ ដោយសារសម្ពាធអតិផរណា និងទឹកជំនន់ធ្ងន់ធ្ងរ។ នៅក្នុងជុំទីមួយនៃការអនុវត្តកម្មវិធីជំនួយសាច់ប្រាក់សម្រាប់គ្រួសារដែលរងផលប៉ះពាល់ពីអតិផរណាបានបញ្ចេញប្រាក់ចំនួន 9.12 លានដុល្លារអាមេរិក និងផ្តល់អត្ថប្រយោជន៍ដល់គ្រួសារចំនួន 261,000 ។ កម្មវិធីជំនួយសាច់ប្រាក់ដល់គ្រួសាររងគ្រោះដោយទឹកជំនន់ត្រូវបានបញ្ចប់នៅខែមីនា ឆ្នាំ 2023 ដែលបានផ្តល់ប្រាក់ចំនួន 11.6 លានដុល្លារអាមេរិក និងផ្តល់អត្ថប្រយោជន៍ដល់ 99,000 គ្រួសារ។

## ទស្សនៈវិស័យ

**កំណើន ផ.ស.ស. ពិតរបស់កម្ពុជាសម្រាប់ឆ្នាំ 2023 ត្រូវបានព្យាករណ៍ថានឹងកើនឡើងបន្ថែមទៀត រហូតដល់ 5.5 ភាគរយ (សូមមើលតារាង ES1) ។** ខណៈដែលការនាំចេញទំនិញមានស្ថានភាពធូរស្រាល ឱនភាពគណនីចរន្តត្រូវបានរំពឹងថានឹងប្រសើរឡើងដល់ 19.3 ភាគរយនៃ ផ.ស.ស. បន្ទាប់ពីការងើបឡើងវិញនៃការនាំចេញសេវាកម្ម ជាពិសេសការទទួលបានភ្ញៀវទេសចរណ៍ និងការផ្ទេរប្រាក់ចូលពីបរទេស។ ទោះបីជាមានការធ្លាក់ចុះថ្មីៗនៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តក៏ដោយ លំហូរចូលមូលធនដ៏រឹងមាំ និងការផ្តល់ហិរញ្ញប្បទានសម្បទាននឹងបន្តគ្របដណ្តប់យ៉ាងទូលំទូលាយនូវតម្រូវការហិរញ្ញប្បទានពីខាងក្រៅ។

**នៅឆ្នាំ 2023 ឱនភាពសារពើពន្ធ ត្រូវបានរំពឹងថានឹងកើនឡើងដល់ 6.4 ភាគរយនៃ ផ.ស.ស.។** ប្រាក់ចំណូល រួមទាំងជំនួយ កំពុងមានភាពប្រសើរឡើង ហើយត្រូវបានព្យាករណ៍ថានឹងនៅតែរឹងមាំ ឈានដល់ 23.5 ភាគរយនៃ ផ.ស.ស.។ ការចំណាយត្រូវបានរំពឹងថានឹងកើនឡើងដល់ 29.9 ភាគរយនៃ ផ.ស.ស. ដោយសារការកើនឡើងនៃការចំណាយប្រតិបត្តិការក្រោយការរាតត្បាតនៃជំងឺ ដែលរួមមានការដំឡើងប្រាក់ឈ្នួលក្នុងវិស័យសាធារណៈជារួម និងកំណើននៃការចំណាយលើទំនិញ និងសេវាកម្ម ព្រមទាំងការចំណាយទាក់ទងនឹងការបោះឆ្នោតជាតិ និងការធ្វើជាម្ចាស់ផ្ទះរៀបចំកីឡាអាស៊ីអាគ្នេយ៍ និងអាស៊ានប៉ារ៉ាហ្គេម។

**ក្នុងរយៈពេលមធ្យម សេដ្ឋកិច្ចត្រូវបានរំពឹងថានឹងមានទំនោរត្រឡប់ទៅរកសក្តានុពលឡើងវិញ ដោយកើនឡើងក្នុងអត្រា 6 ភាគរយ។** ការនាំចេញទំនិញ និងសេវាកម្ម និងលំហូរនៃការវិនិយោគផ្ទាល់ពីបរទេស ត្រូវបានរំពឹងថានឹងជំរុញដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលទើបបានផ្តល់សច្ចាប័នថ្មីៗ កំណើនដ៏ខ្លាំងនៃការវិនិយោគឯកជន និងសាធារណៈលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តសំខាន់ៗ ដូចជាកំពង់ផែសមុទ្រ និងផ្លូវថ្នល់ ជាពិសេសក្រោមភាពជាដៃគូសាធារណៈ និងឯកជន និងកំណែទម្រង់រចនាសម្ព័ន្ធ។ ភាពក្រីក្រត្រូវបានរំពឹងថានឹងធ្លាក់ចុះ ដោយសារការងើបឡើងវិញនៃសេដ្ឋកិច្ច និងអតិផរណាកម្រិតមធ្យមដែលបានព្យាករណ៍។

តារាង ES1 ការព្យាករណ៍កំណើនពិត

| | ការព្យាករណ៍ | | | ការផ្លាស់ប្តូរពី ខែមីនា ឆ្នាំ 2023 | | |
|---|---|---|---|---|---|---|
| | 2023 | 2024 | 2025 | 2023 | 2024 | 2025 |
| កំណើនពិត | 5.5 | 6.1 | 6.3 | 0.3 | 0.4 | 0.2 |

## បញ្ហាប្រឈម និងហានិភ័យ

**ទោះជាយ៉ាងណាក៏ដោយ ទស្សនវិស័យនេះប្រឈមនឹងហានិភ័យនៃការធ្លាក់ចុះ។** ការបន្តភាពយឺតយ៉ាវនៃតម្រូវការខាងក្រៅត្រូវបានរំពឹងថានឹងធ្វើឱ្យការផលិតសម្រាប់នាំចេញរបស់កម្ពុជាចុះខ្សោយបន្ថែមទៀត ដែលការផលិតនេះបង្កើតការងារប្រហែល 40 ភាគរយនៃការងារសរុបនៅក្នុងវិស័យឧស្សាហកម្ម (17.3 ភាគរយនៃការងារមិនមែនកសិកម្មសរុប)។ ការបន្តរឹតបន្តឹងហិរញ្ញវត្ថុសកលអាចជះឥទ្ធិពលដល់វិស័យហិរញ្ញវត្ថុដែលជាប្រភពឥណទានសំខាន់នៃការរីកចំរើនក្នុងវិស័យសំណង់នាពេលថ្មីៗនេះ។ ការប្រែប្រួលតម្លៃប្រេងអាចបង្កឲ្យមានអតិផរណា និងប៉ះពាល់ដល់ការប្រើប្រាស់ក្នុងស្រុក។ នៅក្នុងប្រទេស ការប្រមូលផ្តុំឥណទាននៅក្នុងវិស័យសំណង់នៅតែជាហានិភ័យដ៏សំខាន់ចំពោះស្ថិរភាពហិរញ្ញវត្ថុ។

**ផ្ទុយទៅវិញ កំណើនសកលដែលមានសន្ទុះខ្លាំងជាងការរំពឹងទុក អាចបន្ធូរបន្ថយផលជះនៃការធ្លាក់ចុះតម្រូវការខាងក្រៅ។** ការស្ទុះងើបឡើងវិញជាងការរំពឹងទុកដោយសារការបើកចំហរនៅក្នុងប្រទេសចិន អាចជំរុញការមកដល់នៃភ្ញៀវទេសចរណ៍ ការនាំចេញ និងលំហូរនៃការវិនិយោគផ្ទាល់ពីបរទេសកាន់តែខ្លាំង ដែលអាចជួយទប់ទល់ការធ្លាក់ចុះដែលរំពឹងទុកនៅក្នុងប្រទេសអភិវឌ្ឍន៍ ក្នុងកម្រិតធំជាងការសន្មត់ពីពេលមុន។ លើសពីនេះ កំណើនសេដ្ឋកិច្ចប្រទេសជឿនលឿន ទោះបីទំនងជាយឺតជាងឆ្នាំមុន ក៏អាចនឹងប្រែជាខ្លាំងជាងការរំពឹងទុក ដែលរារាំងដល់ការធ្លាក់ចុះការនាំចេញដែលបានព្យាករណ៍។

## ជម្រើសគោលនយោបាយ

**គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចគួរបន្តគាំទ្រដល់កំណើន និងការងារ ទន្ទឹមនឹងនោះរក្សាបាននូវស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ។** កត្តានេះបានក្លាយជាបញ្ហាប្រឈមកាន់តែខ្លាំងនៅក្នុងបរិបទនៃការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុ និងការកើនឡើងកម្រិតបំណុលឯកជន។ ប៉ុន្តែអតិផរណាបានធ្លាក់ចុះយ៉ាងឆាប់រហ័សដល់កម្រិតមុនការរាតត្បាតនៃជំងឺកូវីដ-19 ដែលអនុញ្ញាតឱ្យរដ្ឋាភិបាលបន្តគោលនយោបាយរូបិយវត្ថុបែបសម្របសម្រួលដោយរក្សា ឬបន្ថយអនុបាតតម្រូវការទុនបម្រុង។ ទោះបីការពង្រឹងផ្នែកសារពើពន្ធមានភាពចាំបាច់ក្នុងរយៈពេលមធ្យម វាអាចដំណើរការទៅបន្តិចម្តងៗ ដែលផ្តល់លទ្ធភាពក្នុងការគ្រប់គ្រងកម្រិតបំណុលសាធារណៈ។ ប្រទេសកម្ពុជាមានលំហសារពើពន្ធដើម្បីរក្សា ឬបង្កើនកំណើនដោយបង្កើនការចំណាយលើហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងការអភិវឌ្ឍធនធានមនុស្ស ដែលនឹងជំរុញសមត្ថភាពផលិតភាពនៃសេដ្ឋកិច្ចក្នុងរយៈពេលវែង។ ការបន្តផ្តល់ជំនួយសង្គមដល់ជនក្រីក្រ ទន្ទឹមនឹងនោះទប់ស្កាត់ការបាត់បង់ការសិក្សាដែលកម្ពុជាបានជួបប្រទះក្នុងអំឡុងពេលនៃវិត្តិកូវីដ-19 និងការកសាងឡើង

វិញឱ្យកាន់តែប្រសើរឡើង ក៏ជាការចាំបាច់ផងដែរ ដើម្បីលើកកម្ពស់កំណើនប្រកបដោយបរិយាប័ន្ន។ កំណើននៃវិនិយោគសាធារណៈ រួមផ្សំនឹងជំហានក្នុងការបង្កើនប្រសិទ្ធិភាពចំណាយនឹងធានាបានថា ការចំណាយខ្ពស់នឹងប្រែក្លាយទៅជាលទ្ធផលកាន់តែប្រសើរ ដូចដែលបរិយាយលម្អិតនៅក្នុងផ្នែកទី 2 នៃរបាយការណ៍នេះ។

**ការការពារស្ថិរភាពហិរញ្ញវត្ថុនៅតែជាកត្តាអាទិភាព។** កំណើនឥណទានយ៉ាងឆាប់រហ័សនាពេលថ្មីៗនេះ និងបំណុលខ្ពស់ក្នុងវិស័យឯកជន ដែលប្រមូលផ្តុំនៅក្នុងវិស័យអចលនទ្រព្យ បង្កហានិភ័យសំខាន់ៗដល់ស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុរបស់កម្ពុជា។ ចំបាច់ត្រូវការការត្រួតពិនិត្យកាន់តែខ្លាំង ទន្ទឹមនឹងការអនុវត្តវិធានការទាក់ទងនឹងការរាតត្បាតនៃជំងឺកូវីដ-19 ដូចជាការរៀបចំប្រាក់កម្ចីឡើងវិញ និងការអត់ធ្មត់ពុំទារបំណុលត្រូវបានបញ្ចប់។ វាអាចរួមបញ្ចូលការពង្រឹងការផ្តោតទៅលើការធ្វើតេស្តភាពតានតឹង (stress test) នៃស្ថាប័ននីមួយៗ ការត្រួតពិនិត្យជាប្រព័ន្ធនៅនឹងកន្លែង ការសម្រួលបន្ថែមទៀតនូវក្របខណ្ឌបទប្បញ្ញត្តិជាមួយនឹងស្តង់ដារអន្តរជាតិ និងការវាយតម្លៃបន្ថែមលើគុណភាពនៃផលប័ត្រប្រាក់កម្ចី ក្នុងចំណោមកត្តាផ្សេងៗទៀត។ ទន្ទឹមនឹងនោះ រដ្ឋាភិបាលគួរបន្តកិច្ចខិតខំប្រឹងប្រែង ក្នុងការរៀបចំបទបញ្ញត្តិស្តីពីការធានារ៉ាប់រងប្រាក់បញ្ញើ និងដំណោះស្រាយធនាគារ។ ដើម្បីត្រៀមសម្រាប់កំណើនកម្រិតនៃប្រាក់កម្ចីមិនដំណើរការ (NPLs) អាជ្ញាធរគួរតែធានាថាមានជម្រើសនៃដំណោះស្រាយជាស្រេចដើម្បីដាក់ឱ្យអនុវត្តនៅពេលចាំបាច់។ ស្រដៀងគ្នានេះដែរ គោលនយោបាយរបបក្ស័យធនរបស់ប្រទេសអាចត្រូវបានកែលម្អ។ ដោយសារការព្រួយបារម្ភជុំវិញសកម្មភាពធនាគារស្រមោល ដូចជាឥណទានដែលចេញដោយក្រុមហ៊ុនសាងសង់ ឬអ្នកអភិវឌ្ឍន៍អចលនទ្រព្យដល់អ្នកទិញសំណង់លំនៅដ្ឋាន វាជារឿងចាំបាច់ខ្លាំងណាស់ក្នុងការប្រមូលទិន្នន័យសំខាន់ៗដើម្បីត្រួតពិនិត្យ និងវាយតម្លៃភាពស្របច្បាប់នៃសកម្មភាពទាំងនោះ។

**ដើម្បីបង្កើនភាពធន់ និងភាពប្រកួតប្រជែងរយៈពេលវែងនៃសេដ្ឋកិច្ច កិច្ចខិតខំប្រឹងប្រែងត្រូវចាំបាច់លើកកម្ពស់បន្ថែមទៀតនូវការធ្វើពិពិធកម្មផលិតផលនាំចេញ។** មិនដូចប្រទេសដទៃទៀតក្នុងតំបន់ទេ កម្ពុជាបានទទួលជោគជ័យតិចតួចក្នុងការធ្វើពិពិធកម្មផលិតផលនាំចេញក្រៅពីសម្លៀកបំពាក់ ស្បែកជើង ខណៈដែលសមត្ថភាពកែច្នៃកសិផលរបស់ខ្លួននៅមានកម្រិតនៅឡើយ។ ដើម្បីឈានទៅដល់ដំណាក់កាលបន្ទាប់នៃការចូលរួមក្នុងខ្សែសង្វាក់តម្លៃសកល បណ្តុំគោលនយោបាយត្រូវមានការវិវត្តផ្លាស់ប្តូរ។ ទីមួយ គួរតែយកចិត្តទុកដាក់លើការអនុវត្តកិច្ចសន្យា ការការពារកម្មសិទ្ធិបញ្ញា និងការពង្រឹងការបញ្ជាក់គុណភាពផលិតផលថ្នាក់ជាតិ និងសមត្ថភាពធ្វើតេស្ត ដើម្បីធានាបាននូវការអនុលោមតាមស្តង់ដារអន្តរជាតិ។ ទីពីរ ការបន្ថយរបាំងពាណិជ្ជកម្ម និងកែលម្អការតភ្ជាប់ទៅកាន់ទីផ្សារនឹងពង្រីកទំហំនៃទីផ្សារផលិតផលរបស់ប្រទេសកម្ពុជា និងធ្វើអោយប្រសើរឡើងនូវលទ្ធភាពទទួលបានធាតុចូលដែលចាំបាច់សម្រាប់ផលិតកម្ម។ ទីបី បន្តពង្រឹងការអប់រំ និងជំនាញនៃកម្លាំងពលកម្មរបស់កម្ពុជា ដោយការវិនិយោគលើធនធានមនុស្ស។ ទីបួន ប្រើប្រាស់សេដ្ឋកិច្ចឌីជីថល ដើម្បីគាំទ្រក្រុមហ៊ុននានាក្នុងការធ្វើសមាហរណកម្មទៅក្នុងខ្សែសង្វាក់សលកតាមរយៈវេទិកាឌីជីថល ក៏ដូចជាតាមរយៈការភ្ជាប់អ្នកចូលរួមខ្សែសង្វាក់តម្លៃ។



## រូបភាព ES.1 ការវិវឌ្ឍថ្មីៗរបស់ប្រទេសកម្ពុជាដោយសង្ខេប

កំណើនសេដ្ឋកិច្ចបន្តរឹងមាំ...
កំណើនពិត (ភាគរយ)




...ដោយសារការពន្លឿនការស្តារឡើងវិញនូវវិស័យសេវាកម្ម...
ការមកដល់របស់ភ្ញៀវអន្តរជាតិ (លាននាក់)




...គាំទ្រដោយការថយចុះអតិផរណា...
(ការផ្លាស់ប្តូរភាគរយ ឆ្នាំ/ឆ្នាំ)




...ជួយទប់ទល់នឹងការធ្លាក់ចុះនៃការនាំចេញ...
ការនាំចេញទំនិញ (មិនរាប់បញ្ចូលមាស) (រហូតដល់ឆ្នាំបច្ចុប្បន្ន, ការផ្លាស់ប្តូរភាគរយ ឆ្នាំ/ឆ្នាំ)




...សាច់ប្រាក់ជារួម ( M2 ) កំណើនថយចុះ...
បំណុលសាច់ប្រាក់ជារួម (ការផ្លាស់ប្តូរភាគរយ ឆ្នាំ/ឆ្នាំ)




...កំណើនប្រាក់ចំណូលក្នុងស្រុកបានស្ទុះងើបឡើងវិញទាំងស្រុង។
ចំណូលក្នុងស្រុករបស់រដ្ឋាភិបាល (ការផ្លាស់ប្តូរភាគរយ ឆ្នាំ/ឆ្នាំ)




**ប្រភព៖** អាជ្ញាធរកម្ពុជា : ប៉ាន់ស្មាន និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក។
**សម្គាល់៖** ប = ប៉ាន់ស្មាន; ព = ព្យាករណ៍; YTD = រហូតដល់ឆ្នាំបច្ចុប្បន្ន; ឆ្នាំ/ឆ្នាំ = ធៀបនឹងមួយឆ្នាំមុន

# ការវិវត្តថ្មីៗ

## តម្រូវការអ្នកប្រើប្រាស់កើនឡើងបានជំរុញវិស័យសេវាកម្ម

**សេដ្ឋកិច្ចកម្ពុជាកំពុងស្ទុះងើបឡើងវិញយ៉ាងល្អ ក្រោយជំងឺរាតត្បាត។** ដោយសារភាពជោគជ័យក្នុងការដាក់ឱ្យដំណើរការកម្មវិធីចាក់វ៉ាក់សាំងរបស់ខ្លួន កម្ពុជាបានអនុវត្តការ "រស់នៅជាមួយកូវីដ-19" នៅចុងឆ្នាំ 2021។ ជាលទ្ធផល ការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចរបស់ប្រទេសមានភាពរឹងមាំនៅឆ្នាំ 2022 ជាមួយនឹងកំណើនពិតកើនឡើងដល់ 5.2 ភាគរយ (រូបភាព 1) ។ ជំរុញជំរុញដោយភាពរឹងមាំនៃឧស្សាហកម្មផលិតកម្មដែលផ្តោតលើការនាំចេញ ដោយការងើបឡើងវិញយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចបច្ចុប្បន្ននៅក្នុងវិស័យសេវាកម្ម ត្រូវបានគាំទ្រកាន់តែរឹងមាំដោយការងើបឡើងវិញយ៉ាងខ្លាំងនៅក្នុងវិស័យសេវាកម្ម ជាពិសេសពាណិជ្ជកម្ម ឧស្សាហកម្មធ្វើដំណើរ និងបដិសណ្ឋារកិច្ច ដែលជំរុញដោយកំណើនតម្រូវការអ្នកប្រើប្រាស់ និងការត្រឡប់មកវិញនៃភ្ញៀវទេសចរបរទេស។ ការប្រើប្រាស់ក្នុងស្រុកក៏កំពុងត្រូវបានជំរុញដោយការបន្ធូរបន្ថយអតិផរណា ដោយសារថាមពល និងតម្លៃអាហារចាប់ផ្តើមមានស្ថិរភាព ។

**ដូចគ្នានេះដែរ នៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិកដែលកំពុងអភិវឌ្ឍន៍ភាគច្រើន សកម្មភាពសេដ្ឋកិច្ចបានងើបឡើងវិញ ពីវិបត្តិកូវីដ-19 និងវិបត្តិតម្លៃប្រេង ដោយមានភាពប្រសើរឡើងនៃការនាំចេញ និងការប្រើប្រាស់ឯកជនជាកត្តាជំរុញនាំមុខ។**[1] ការប្រៀបធៀបក្នុងតំបន់បង្ហាញថា ទោះបីជាកម្ពុជាអាចពង្រឹងការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់ខ្លួនពីវិបត្តិនាពេលថ្មីៗនេះក៏ដោយ ក៏ប្រទេសនេះបានដើរយឺតជាងវៀតណាម និងចិន។ នៅចុងឆ្នាំ 2022 ប្រទេសកម្ពុជា និងប្រទេសជាច្រើននៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក រួមមាន ឥណ្ឌូណេស៊ី ឡាវ ម៉ាឡេស៊ី ម៉ុងហ្គោលី ហ្វីលីពីន ណៅរូ គីរីបាទី និងប៉ាពួញូហ្គីណេ បានស្ទុះឡើងលើសពីកម្រិតមុនការរាតត្បាត ខណៈប្រទេសចិន និងវៀតណាមមានទិន្នផលបែបនោះក្នុងឆ្នាំ 2020។ ផ្ទុយទៅវិញ ទិន្នផលនៅតែមានកម្រិតទាបជាងមុនការរាតត្បាតនៃជំងឺនៅក្នុងប្រទេសកោះប៉ាស៊ីហ្វិកមួយចំនួន ក៏ដូចជានៅមីយ៉ាន់ម៉ា ថៃ និងទីម័រខាងកើត។ កត្តាធំៗចំនួនបីបានជះឥទ្ធិពលលើកំណើនសេដ្ឋកិច្ចក្នុងប្រទេសក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក៖ វិធានការទប់ស្កាត់ជំងឺកូវីដ-19 លក្ខខណ្ឌខាងក្រៅ និងសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការផ្តល់ការគាំទ្រ។ កម្ពុជាអាចគ្រប់គ្រងលក្ខខណ្ឌទាំងអស់នោះ។

**ប៉ុន្តែបច្ចុប្បន្នមានសញ្ញានៃការចុះខ្សោយនៃតម្រូវការខាងក្រៅ ខណៈដែលកំណើនពិភពលោកកំពុងធ្លាក់ចុះយ៉ាងខ្លាំងនៅឆ្នាំនេះ។**[2] កត្តានេះបង្កឡើងដោយសារវិបត្តិត្រួតគ្នាដែលរួមមានការរឹតបន្តឹងគោលនយោបាយសមកាលកម្មដែលមានគោលបំណងគ្រប់គ្រងអតិផរណាដែលខ្ពស់ខ្លាំង ស្ថានភាពហិរញ្ញវត្ថុកាន់តែអាក្រក់ និងការរំខានបន្តពីការឈ្លានពានរបស់រុស្ស៊ីលើអ៊ុយក្រែន។ ប្រទេសតូចៗ រួមទាំងកម្ពុជា ងាយរងគ្រោះដោយវិបត្តិបែបនេះ ដោយសារការពឹងផ្អែកលើពាណិជ្ជកម្ម និងហិរញ្ញវត្ថុខាងក្រៅ ការធ្វើពិពិធកម្មសេដ្ឋកិច្ចមានកម្រិត បំណុលកើនឡើង និងភាពងាយរងគ្រោះចំពោះគ្រោះមហន្តរាយធម្មជាតិ (សូមមើលប្រអប់ 1 ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោក និងទស្សនវិស័យ)។

**រូបភាព 1** ការងើបឡើងវិញនៃសេដ្ឋកិច្ចមានភាពកាន់តែរឹងមាំ

ការរួមចំណែកដល់កំណើន ផ.ស.ស. ពិត (ភាគរយ)




**ប្រភព៖** ការព្យាករណ៍របស់អាជ្ញាធរកម្ពុជា និងបុគ្គលិកធនាគារពិភពលោក។
**សម្គាល់៖** ប = ការប៉ាន់ស្មាន ព = ការព្យាករណ៍។

1 ធនាគារពិភពលោក 2023a.
2 ធនាគារពិភពលោក 2023b.

## ការនាំចេញរបស់កម្ពុជាចាប់ផ្តើមធ្លាក់ចុះក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ

**សូចនាករថ្មីៗដែលត្រូវបានប្រើញឹកញាប់បង្ហាញពីការចុះខ្សោយតម្រូវការខាងក្រៅ។** ភាគច្រើនដោយសារការថយចុះនៃការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ការនាំចេញសរុបបានធ្លាក់ចុះ 14.2ភាគរយឆ្នាំ/ឆ្នាំ ក្នុងអំឡុងពេលពីរខែដំបូងនៃឆ្នាំ 2023 (រូបភាព 2) បើធៀបនឹងអត្រាកំណើនជាមធ្យម 6.7 ភាគរយនៅក្នុង ឆ្នាំ 2019 ។ សេដ្ឋកិច្ច តូច និងបើកចំហរបស់កម្ពុជានៅតែពឹងផ្អែកលើតម្រូវការពិភពលោក។ តម្លៃទំនិញកើនឡើង និងការរឹតបន្តឹងផ្នែកហិរញ្ញវត្ថុក្នុងប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនបន្តជះឥទ្ធិពលដល់សេដ្ឋកិច្ចក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ទាំងតាមរយៈបណ្តាញពិត និងផ្នែកហិរញ្ញវត្ថុ។

**ដូចដែលបានបង្ហាញក្នុងរូបភាព 2 ផលិតផលសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងការនាំចេញស្បែកជើងមានការថយចុះយ៉ាងខ្លាំង ដែលបង្ហាញពីតម្រូវការយឺតយ៉ាវសម្រាប់ផលិតផលទាំងនេះទាក់ទងនឹងប្រាក់ចំណូលក្នុងទីផ្សារនាំចេញសំខាន់ៗរបស់កម្ពុជាជាពិសេសសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប។** ក្នុងចំណោមការធ្លាក់ចុះ 14.5 ភាគរយនៃការនាំចេញសរុបក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ 2023 សម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើងបានរួមចំណែកធំបំផុតដែលមានចំនួន 11.8 ពិន្ទុភាគរយ 2.7 ពិន្ទុភាគរយ និង 2.4 ពិន្ទុភាគរយរៀងគ្នា។ ទោះជាយ៉ាងណាក៏ដោយ ការរួមចំណែកនៃ "ការនាំចេញទំនិញផ្សេងទៀត" បានកើនឡើង ដែលស្មើនឹង 6.7 ពិន្ទុភាគរយ។

**រូបភាព 2** ការនាំចេញបានធ្លាក់ចុះ

ការរួមចំណែកដល់កំណើននៃការនាំចេញ (ពិន្ទុភាគរយ)




ប្រភព៖ អាជ្ញាធរកម្ពុជា។



## ប្រអប់ 1 ការអភិវឌ្ឍសេដ្ឋកិច្ចសកល និងទស្សនវិស័យ

កំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានរំពឹងថានឹងថយចុះគួរឱ្យកត់សម្គាល់នៅឆ្នាំនេះ ដោយរងឥទ្ធិពលនៃការរឹតបន្តឹងគោលនយោបាយសមកាលកម្មដ៏សំខាន់ក្នុងគោលបំណងទប់ទល់នឹងអតិផរណាកម្រិតខ្ពស់ និងស្ថានភាពហិរញ្ញវត្ថុកាន់តែអាក្រក់។[ក] ទោះបីអតិផរណាបង្ហាញសញ្ញានៃការឡើងដល់កំពូលនៅក្នុងប្រទេសជឿនលឿន និងទីផ្សារកំពុងរីកលូតលាស់ និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ (EMDEs) វានៅតែមានកម្រិតខ្ពស់ជារួម (រូបភាព B1.1)។ អតិផរណាខ្ពស់ដែលនៅបន្តបាននាំឱ្យធនាគារកណ្តាលមួយចំនួន ជាពិសេសធនាគារកណ្តាលអាមេរិក និងធនាគារកណ្តាលអឺរ៉ុប បន្តដំឡើងអត្រាគោលនយោបាយនៅដើមឆ្នាំ 2023 ។ ទោះបីវដ្តនៃការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុហាក់ដូចជាឡើងជិតដល់កម្រិតកំពូលនៅក្នុងប្រទេសជាច្រើន ការបន្តការដំឡើងអត្រាការប្រាក់កាន់តែធ្វើស្ថានភាពអាក្រក់ក្នុងរយៈពេលដ៏ខ្លី ដោយសារភាពយឺតយ៉ាវរវាងការផ្លាស់ប្តូរគោលនយោបាយរូបិយវត្ថុ និងផលប៉ះពាល់របស់វាលើសេដ្ឋកិច្ច។ ភាពចលាចលនាពេលថ្មីៗនេះនៅក្នុងវិស័យធនាគាររបស់សហរដ្ឋអាមេរិក និងអឺរ៉ុបក៏បានរួមចំណែកដល់លក្ខខណ្ឌហិរញ្ញវត្ថុកាន់តែតឹងរ៉ឹង និងធ្វើឱ្យកាន់តែមានភាពមិនច្បាស់លាស់។

ពាណិជ្ជកម្មសកលត្រូវបានរំពឹងថានឹងថយចុះនៅឆ្នាំនេះ រួមជាមួយនឹងការធ្លាក់ចុះនៃសកម្មភាពសកល។ នៅចុងឆ្នាំ ពាណិជ្ជកម្មសកលបានធ្លាក់ចុះ ខណៈដែលតម្រូវការទន់ខ្សោយក្នុងប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនដាក់ទម្ងន់បន្ថែមលើការនាំចេញទៅទីផ្សារកំពុងលូតលាស់ និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍។ ទោះជាយ៉ាងណាក៏ដោយ ទស្សនវិស័យពាណិជ្ជកម្មសេវាកម្មមានភាពវិជ្ជមាន ជាមួយនឹងការស្ទុះងើបឡើងវិញនៃវិស័យទេសចរណ៍ពិភពលោក ត្រូវបានរំពឹងថានឹងបន្តគាំទ្រដោយការបើកប្រទេសចិនឡើងវិញ។ ការវិលមកសភាពធម្មតាវិញនៃលក្ខខណ្ឌការដឹកជញ្ជូន និងការធ្លាក់ចុះនៃតម្រូវការសម្រាប់ទំនិញបានរួមចំណែកដល់ការត្រឡប់មកវិញនៃសម្ពាធខ្សែសង្វាក់ផ្គត់ផ្គង់ពិភពលោកដល់កម្រិតមុនការរាតត្បាតនៅដើមឆ្នាំ 2023 ។

តម្លៃអាហារ និងថាមពលសកលបានធ្លាក់ចុះពីកម្រិតកំពូលរបស់វានៅឆ្នាំ 2022 ប៉ុន្តែនៅតែមានកម្រិតខ្ពស់ ទន្ទឹមនឹងនោះតម្លៃលោហធាតុបានកើនឡើង ដោយសារតែការរំពឹងទុកនៃតម្រូវការកាន់តែខ្លាំងពីប្រទេសចិន។ តម្លៃថាមពល និងអាហារត្រូវបានរំពឹងថានឹងធូរស្រាលនៅឆ្នាំនេះ ដោយសារការធ្លាក់ចុះនៃតម្រូវការពិភពលោក។ នៅក្នុងប្រទេសជាច្រើន ការបន្ធូរបន្ថយតម្លៃទំនិញនឹងជួយធ្វើឱ្យអតិផរណាធូរស្រាលក្នុងរយៈពេលដ៏ខ្លី ទន្ទឹមនឹងសកម្មភាពពាណិជ្ជកម្មខ្សោយ។

នៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក កំណើនត្រូវបានរំពឹងថានឹងកើនឡើងនៅឆ្នាំនេះ។ វាឆ្លុះបញ្ចាំងជាចម្បងពីកំណើនដ៏រឹងមាំនៅក្នុងប្រទេសចិន ដែលបើកសេដ្ឋកិច្ចឡើងវិញមុនការរំពឹងទុក និងមានការធ្លាក់ចុះយ៉ាងឆាប់រហ័សនៃករណី កូវីដ-19 នៅដើមឆ្នាំនេះ កំពុងគាំទ្រដល់ការងើបឡើងវិញនៃសកម្មភាពពាណិជ្ជកម្ម បន្ទាប់ពីមានកំណើនខ្សោយខ្លាំងក្នុងឆ្នាំ 2022។ នៅក្នុងខែដំបូងនៃឆ្នាំនេះ ការលក់រាយបានងើបឡើងវិញ ខណៈដែលការវិនិយោគនៅតែរឹងមាំ គាំទ្រដោយការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ។ ផ្ទុយទៅវិញ ផលិតកម្មឧស្សាហកម្មមានការថយចុះ ដែលមួយផ្នែកឆ្លុះបញ្ចាំងពីតម្រូវការខាងក្រៅខ្សោយ។ នៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដោយមិនរាប់បញ្ចូលប្រទេសចិន កំណើនត្រូវបានរំពឹងថានឹងមានកម្រិតមធ្យមនៅឆ្នាំ 2023 បន្ទាប់ពីមានកំណើនខ្លាំងនៅឆ្នាំ 2022 ដែលទាក់ទងនឹងការបើកសេដ្ឋកិច្ចឡើងវិញ។

ហានិភ័យចំពោះទស្សនវិស័យសកលនៅតែមានទំនោរទៅរកការធ្លាក់ចុះ។ ស្ថានភាពហិរញ្ញវត្ថុពិភពលោកដ៏តឹងតែង ខណៈបំណុលខ្ពស់ អាចបង្កឱ្យមានភាពតានតឹងផ្នែកហិរញ្ញវត្ថុ ជាពិសេសនៅក្នុងប្រទេសដែលមានពិន្ទុឥណទានទាប។ គោលនយោបាយរូបិយវត្ថុអាចបន្តតានតឹងយូរជាងការរំពឹងទុក ប្រសិនបើសម្ពាធអតិផរណានៅតែបន្ត។ ប្រសិនបើកំណើនកាន់តែខ្សោយ លំហសារពើពន្ធមានកម្រិតនៅក្នុងប្រទេសជាច្រើននឹងកាត់បន្ថយសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការគាំទ្រសកម្មភាពពាណិជ្ជកម្ម។

កំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានរំពឹងថាធ្លាក់ចុះ ទន្ទឹមនឹងការធ្លាក់ចុះយ៉ាងទូលំទូលាយនៅក្នុងកំណើនសក្តានុពលសកល និងទីផ្សារដែលកំពុងលូតលាស់ និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍។[ខ] បើគ្មានកំណែទម្រង់ទេ កំណើនសក្តានុពលនៅក្នុងទីផ្សារដែលកំពុងលូតលាស់ និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ ត្រូវបានព្យាករណ៍ថានឹងបន្តធ្លាក់ចុះក្នុងប៉ុន្មានឆ្នាំចុងក្រោយនៃទសវត្សឆ្នាំ 2020 នេះ (រូបភាព B1.2)។ ការរួមបញ្ចូលគ្នានៃបញ្ហាដែលបង្កឡើងដោយការរាតត្បាតនៃជំងឺកូវីដ-19 និងផលជះពីសង្គ្រាមនៅអ៊ុយក្រែន ត្រូវបានរំពឹងថានឹងមានសម្ពាធលើកំណើនរយៈពេលវែង រួមទាំងផ្តល់ផលប៉ះពាល់អវិជ្ជមានលើការប្រមូលផ្តុំមូលធនមនុស្ស និងការវិនិយោគ។ តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិកត្រូវបានរំពឹងថានឹងប្រឈមការធ្លាក់ចុះខ្លាំងបំផុតនៅក្នុងប្រទេសដែលមានទីផ្សារដែលកំពុងលូតលាស់ និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ទាំងអស់ ដែលឆ្លុះបញ្ចាំងពីភាពយឺតយ៉ាវនៃការប្រមូលផ្តុំមូលធន និងកំណើនផលិតភាពកត្តាសរុប រួមទាំងនៅក្នុងប្រទេសចិន។

រូបភាព B1.1 អតិផរណា




រូបភាព B1.2 កំណើនសក្តានុពល




**ប្រភព ៖** ក. ធនាគារពិភពលោក 2023a. b. Kose និង Ohnsorge 2023; ធនាគារពិភពលោក 2023b.
**សម្គាល់៖** ប្រអប់នេះត្រូវបានរៀបចំដោយ Samuel Christopher Hill, ក្រុមទស្សនវិស័យសេដ្ឋកិច្ចអភិវឌ្ឍន៍។

## ការធ្លាក់ចុះនៃការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបមានចំនួន 95 ភាគរយនៃការធ្លាក់ចុះសរុប

**ការធ្លាក់ចុះតម្រូវការពីសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ដែលបណ្ដាលមកពីការធ្លាក់ចុះសេដ្ឋកិច្ចនៅក្នុងទីផ្សារនាំចេញសំខាន់ទាំងពីរ គឺជាមូលហេតុចម្បងនៃការធ្លាក់ចុះការនាំចេញរបស់កម្ពុជា។** ការរួមចំណែករបស់ទីផ្សារសហរដ្ឋអាមេរិកដល់កំណើននៃការនាំចេញទំនិញរបស់កម្ពុជាបានធ្លាក់ចុះពី 35 ពិន្ទុភាគរយក្នុងខែមេសា ឆ្នាំ 2022 ដល់អត្រាអវិជ្ជមាន 7.6 ពិន្ទុភាគរយនៅក្នុងខែកុម្ភៈ ឆ្នាំ 2023 ខណៈពេលដែលទីផ្សារសហភាពអឺរ៉ុបបានធ្លាក់ចុះពី 11.9 ពិន្ទុភាគរយទៅអវិជ្ជមាន 3.1 ពិន្ទុភាគរយក្នុងអំឡុងពេលដូចគ្នា (រូបភាព 3) ។ ដោយសារទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបគឺជាទីផ្សារនាំចេញធំជាងគេទី 1 និងទី 2 សម្រាប់ប្រទេសកម្ពុជា ការធ្លាក់ចុះនៃទីផ្សារទាំងពីររួមបញ្ចូលគ្នាមានចំនួន 95.4 ភាគរយនៃការធ្លាក់ចុះសរុបនៃការនាំចេញក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ 2023 ។

**ការនាំចេញទំនិញរបស់កម្ពុជា ទៅកាន់សហរដ្ឋអាមេរិកបានធ្លាក់ចុះ 20.2 ភាគរយក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ 2023។** ជាលទ្ធផល ចំណែកនៃទីផ្សារសហរដ្ឋអាមេរិកបានធ្លាក់ចុះដល់ 40.9 ភាគរយនៃការនាំចេញទំនិញសរុបក្នុងខែកុម្ភៈ ឆ្នាំ 2023 បន្ទាប់ពីបានឡើងដល់កម្រិតកំពូល 48.3 ភាគរយនៅក្នុងខែមិថុនា ឆ្នាំ 2022។ ដូចគ្នានេះដែរ ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុបបានធ្លាក់ចុះ 17.7 ភាគរយ។ ចំណែកនៃទីផ្សារសហភាពអឺរ៉ុបបានធ្លាក់ចុះមកត្រឹម 17.1 ភាគរយនៅក្នុងខែកុម្ភៈ ឆ្នាំ 2023 បន្ទាប់ពីបានឡើងដល់កម្រិតកំពូល 20.6 ភាគរយនៅក្នុងខែកក្កដា ឆ្នាំ 2022។ ផ្ទុយទៅវិញ ការរួមចំណែករបស់ទីផ្សារចិន និងអាស៊ានចំពោះកំណើននៃការនាំចេញទំនិញរបស់កម្ពុជានៅតែមានភាពវិជ្ជមាន ប៉ុន្តែមិនសូវសំខាន់ ពោលគឺមានត្រឹមតែ 0.7 ពិន្ទុភាគរយ និង 0.1 ពិន្ទុភាគរយប៉ុណ្ណោះ។

**ការធ្វើពិពិធកម្មផលិតផលនាំចេញកំពុងលេចចេញជាបណ្ដើរៗ។** ទោះបីជាបន្តពឹងផ្អែកលើការនាំចេញសម្លៀកបំពាក់ក៏ដោយ ក៏ការនាំចេញមិនមែនសម្លៀកបំពាក់កំពុងកើនឡើង។ ចំណែកនៃការនាំចេញផលិតផលកាត់ដេរ (និងវាយនភណ្ឌ) បានធ្លាក់ចុះមកនៅត្រឹម 45.2 ភាគរយក្នុងឆ្នាំ 2022 ចុះពី 54.4 ភាគរយក្នុងឆ្នាំ 2019 (រូបភាព 4)។ ចំណែកនៃការនាំចេញទំនិញដែលត្រូវបានកំណត់ក្រោមប្រភេទទំនិញ "ផ្សេងទៀត" បានកើនឡើងដល់ 21.8 ភាគរយក្នុងឆ្នាំ 2022 កើនពី 9.4 ភាគរយក្នុងឆ្នាំ 2019 ។ ក្នុងអំឡុងពេលដូចគ្នានេះ ចំណែកនៃការនាំចេញកង់បានកើនឡើងដល់ 4.4 ភាគរយ កើនពី 3.7 ភាគរយ។ ទោះជាយ៉ាងណាក៏ដោយ ចំណែកនៃផលិតផលអេឡិចត្រូនិច អគ្គិសនី និងរថយន្តនៅក្នុងការនាំចេញសរុបនៅតែមានកម្រិតតិចតួច ហើយមិនផ្លាស់ប្ដូរទេ គឺប្រហែល 3.5 ភាគរយ ដែលវាអាចបង្ហាញថា វិស័យអេឡិចត្រូនិក និងអគ្គិសនីរបស់ប្រទេសនេះមិនទាន់មានឧត្តមភាពប្រកួតប្រជែងនៅឡើយ។ មានបញ្ហាប្រឈមជាបន្តបន្ទាប់ក្នុងការដោះស្រាយបញ្ហាថ្លៃខ្ពស់ (និងអស្ថិរភាពនៃការផ្គត់ផ្គង់) នៃថាមពល និងភស្តុភារ និងកង្វះកម្លាំងពលកម្មជំនាញសរុប ដែលទំនងជារាំងការចូលរួមរបស់ប្រទេសក្នុងខ្សែសង្វាក់តម្លៃអេឡិចត្រូនិក និងអគ្គិសនី។ ដូចគ្នានេះដែរ ចំណែកនៃទំនិញធ្វើដំណើរ និងផលិតផលស្បែកជើងនៅតែមិនផ្លាស់ប្ដូរ គឺ 8.7 ភាគរយ និង 8.0 ភាគរយរៀងគ្នា។

រូបភាព 3 ការរួមចំណែកដល់កំណើននៃការនាំចេញ
(ពិន្ទុភាគរយ)




**ប្រភព៖** អាជ្ញាធរកម្ពុជា។
**សម្គាល់៖** RoW = ផ្នែកផ្សេងទៀតនៃពិភពលោក។

រូបភាព 4 ការធ្វើពិពិធកម្មការនាំចេញបានបន្ត
(ចំណែកភាគរយ)




**ប្រភព៖** អាជ្ញាធរកម្ពុជា។

## ចំនួនទុនវិនិយោគសរុបនៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តបានថមថយ

**ក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ 2023 តម្លៃគម្រោងនិយោគផ្ទាល់ពីបរទេសដែលបានអនុម័ត ដែលត្រូវបានចាត់ថ្នាក់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ) បានធ្លាក់ចុះមកត្រឹម 156 លានដុល្លារអាមេរិក ចុះ 92.3 ភាគរយ (រូបភាព 5)។** ទោះបីជាមានការធ្លាក់ចុះនៃការនាំចេញផលិតផលសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង (GTF) ក៏ដោយ ចំណង់ផ្តល់ហិរញ្ញប្បទានពីអ្នកវិនិយោគបរទេសដល់ឧស្សាហកម្មសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង នៅតែមាន។ ក្នុងចំណោមទឹកប្រាក់សរុប 156 លានដុល្លារនោះ 83 លានដុល្លារ (60 ភាគរយ) ជាការវិនិយោគក្នុងឧស្សាហកម្មកាត់ដេរ ខណៈ 73 លានដុល្លារ (40 ភាគរយ) ទៀតជាការវិនិយោគលើការផលិតទំនិញធ្វើដំណើរ ស្បែកជើង និងឧស្សាហកម្មវេចខ្ចប់។ ទន្ទឹមនឹងនេះ ច្បាប់វិនិយោគថ្មីដែលត្រូវបានអនុម័តនៅចុងឆ្នាំ 2021 មិនទាន់ត្រូវបានអនុវត្តទេ ដោយសារការពន្យារពេលក្នុងការដាក់ឱ្យប្រើប្រាស់អនុក្រឹត្យដែលរំពឹងថានឹងរួចរាល់នៅឆ្នាំនេះ។

**ការធ្លាក់ចុះនៅឆ្នាំនេះកើតមានបន្ទាប់ពីកំណើនយ៉ាងខ្លាំងនៃតម្លៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលបានអនុម័តកាលពីឆ្នាំមុន។** ចំនួនទឹកប្រាក់វិនិយោគសរុបឈានដល់ 1.15 ពាន់លានដុល្លារក្នុងឆ្នាំ 2022 ឬកើនឡើង 75.4 ភាគរយ។ លើសពីនេះ គម្រោងដែលបានអនុម័តត្រូវបានធ្វើពិពិធកម្មលើសពីវិស័យកាត់ដេរ ដែលវិស័យកាត់ដេរបានទទួលត្រឹមតែ 267 លានដុល្លារអាមេរិក ឬ 22.8 ភាគរយនៃការវិនិយោគសរុបប៉ុណ្ណោះ (រូបភាព 6)។ តម្លៃវិនិយោគនៃគម្រោងវិនិយោគផ្ទាល់ពីបរទេស ដែលត្រូវបានអនុម័តក្នុងវិស័យឧស្សាហកម្មមិនមែនកាត់ដេរបានឈានដល់ 803 លានដុល្លារអាមេរិក ឬ 68.6 ភាគរយនៃការវិនិយោគសរុប ក្នុងនោះវិស័យភស្តុភារ និងបដិសណ្ឋារកិច្ចទទួលបាន 1.3 ពាន់លានដុល្លារ និង 129 លានដុល្លាររៀងគ្នា។ ការវិនិយោគលើវិស័យថាមពល (រោងចក្រវារីអគ្គិសនី) មានចំនួន 389.4លានដុល្លារអាមេរិក។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើពិពិធកម្មការនាំចេញ និងការកែលម្អខ្សែសង្វាក់តម្លៃនៅតែជាបញ្ហាប្រឈមមួយ ដោយសារការចំណាយខ្ពស់នៃអគ្គិសនី (និងស្ថិរភាពនៃការផ្គត់ផ្គង់) និងភស្តុភារ និងគម្លាតជំនាញ ដែលកាត់បន្ថយភាពប្រកួតប្រជែងខាងក្រៅរបស់កម្ពុជាក្នុងផលិតផលមានតម្លៃបន្ថែមខ្ពស់។

**លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជាបានកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយ ហើយនៅតែមានភាពរឹងមាំដដែល ទោះបីក្នុងកំឡុងពេលនៃជំងឺកូវីដ-19 ក៏ដោយ។** លំហូរនៃការវិនិយោគផ្ទាល់ពីបរទេសមកកាន់ប្រទេសកម្ពុជាមានចំនួន 12.9 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2021 ដែលជាប្រទេសទទួលការវិនិយោគផ្ទាល់ពីបរទេសធំជាងគេទី 11 នៅលើពិភពលោកក្នុងលក្ខខណ្ឌធៀបនឹង ផ.ស.ស. និងធំជាងគេទីពីរនៅក្នុងអាស៊ានបន្ទាប់ពីប្រទេសសិង្ហបុរី (26.5 ភាគរយនៃ ផ.ស.ស.) ។ ការវិនិយោគផ្ទាល់ពីបរទេសរបស់កម្ពុជាភាគច្រើនបានមកពីប្រទេសចិន និងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ប៉ុន្តែវាមានលក្ខណៈចម្រុះជាងប្រទេសភាគច្រើន។ គិតត្រឹមឆ្នាំ 2022 ការវិនិយោគផ្ទាល់ពីបរទេសមានប្រភពមកពីប្រទេសចិន (រួមទាំងតំបន់រដ្ឋបាលពិសេសហុងកុង) កូរ៉េ សិង្ហបុរី ជប៉ុន និងតៃវ៉ាន់ ដែលជាប្រភពនៃការវិនិយោគផ្ទាល់ពីបរទេសធំជាងគេទាំងប្រាំ ដែលមានចំនួន 17.2 ពាន់លានដុល្លារអាមេរិក 5.3 ពាន់លានដុល្លារ 2.9 ពាន់លានដុល្លារ 2.7 ពាន់លានដុល្លារ និង 2.6 ពាន់លានដុល្លារ រៀងគ្នា។ ការវិនិយោគផ្ទាល់ពីបរទេសខ្ពស់បំផុតទាំងប្រាំរួមបញ្ចូលគ្នាមានចំនួនច្រើនជាង 2/3 នៃការវិនិយោគផ្ទាល់ពីបរទេស សរុបចំនួន 44.5 ពាន់លានដុល្លារអាមេរិក។ ទោះជាយ៉ាងណាក៏ដោយ លំហូរចូលនៃការវិនិយោគមិនសូវទទួលបានជោគជ័យក្នុងការរួមចំណែកដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច ឬការបង្កើតតម្លៃបន្ថែមក្នុងតំបន់ទេ (សម្រាប់ការពិភាក្សាបន្ថែមអំពីការវិនិយោគផ្ទាល់ពីបរទេស សូមមើលប្រអប់ 2)។

រូបភាព 5 ចំណង់នៃការវិនិយោគបានធូរស្រាល

តម្លៃគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលបានអនុម័ត (ពាន់លានដុល្លារអាមេរិក, ការផ្លាស់ប្តូរជាមធ្យម 6 ខែ, ទ្រព្យសកម្មថេរ)




**ប្រភព៖** អាជ្ញាធរកម្ពុជា។
**សម្គាល់៖** គ.ល.គ = គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

រូបភាព 6 គម្រោងដែលផ្តល់ហិរញ្ញប្បទានដោយការវិនិយោគផ្ទាល់ពីបរទេសដែលបានអនុម័ត តាមវិស័យ

(ពាន់លានដុល្លារអាមេរិក ឆ្នាំ 2022 )




**ប្រភព៖** អាជ្ញាធរកម្ពុជា។

## ប្រអប់ 2 តើមានអ្វីបន្ថែមទៀតដែលអាចធ្វើបានដើម្បីកែលម្អការរួមចំណែកនៃការវិនិយោគផ្ទាល់ពីបរទេសដល់សេដ្ឋកិច្ច?

នៅទូទាំងពិភពលោក បរិយាកាសសេដ្ឋកិច្ចកាន់តែយ៉ាប់យ៉ឺនដែលបណ្តាលមកពីវិបត្តិត្រួតគ្នា (ការរាតត្បាតនៃជំងឺសកលកូវីដ-19 ការឈ្លានពានរបស់រុស្ស៊ីនៅអ៊ុយក្រែន និងការរឹតបន្តឹងរូបិយវត្ថុដើម្បីទប់ទល់នឹងអតិផរណាពិភពលោក) បានបង្កើតភាពប្រែប្រួល និងភាពមិនច្បាស់លាស់ដែលមិនធ្លាប់មានពីមុនមកសម្រាប់លំហូរនៃការវិនិយោគផ្ទាល់ពីបរទេសទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍។ លំហូរនៃការវិនិយោគផ្ទាល់ពីបរទេសមានការប្រែប្រួលសន្សឹមៗ ប៉ុន្តែការផ្លាស់ប្តូរជាបន្តបន្ទាប់និងការប្រែប្រួលការរៀបចំផលិតកម្មអន្តរជាតិរបស់សាជីវកម្មពហុជាតិនិងការសម្រេចចិត្តបោះទីតាំង ការវិនិយោគផ្ទាល់ពីបរទេសដែលពាក់ព័ន្ធនៅតែមានជាបន្ត។ ការរាតត្បាតនៃជំងឺកូវីដ-19 បានរំខានដល់កំណើននៃចំណែកនៃការវិនិយោគផ្ទាល់ពីបរទេសដល់ប្រទេសកំពុងអភិវឌ្ឍន៍ ប៉ុន្តែបានជំរុញកំណើនការវិនិយោគផ្ទាល់ពីបរទេសលើវិស័យសេវាកម្ម ហើយការផ្លាស់ប្តូរសមាសភាពភូមិសាស្ត្រនៃការវិនិយោគផ្ទាល់ពីបរទេស ដូចជាកំណើននៃការទាញកម្លាំងពលកម្មពីប្រទេសជិតខាង និងពិពិធកម្មនៃខ្សែសង្វាក់ផ្គត់ផ្គង់ ក៏បានលេចឡើង។ ការផ្លាស់ប្តូរទីតាំងវិនិយោគពីប្រទេសចិនគឺជាកត្តារួមចំណែកដ៏សំខាន់ក្នុងការកំណត់រចនាសម្ព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ឡើងវិញ (រូបភាព B2.1)។

លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជាបានកើនឡើងយ៉ាងឆាប់រហ័សក្នុងមួយទសវត្សរ៍កន្លងទៅ។ លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសបានកើនឡើងទ្វេដងក្នុងឆ្នាំ 2019 បើធៀបទៅនឹងឆ្នាំ 2015 (រូបភាព B2.2) ហើយនៅតែមានភាពធន់ ទោះបីក្នុងរយៈពេលនៃវិបត្តិកូវីដ-19 ក៏ដោយ។ ប្រភពនៃការវិនិយោគផ្ទាល់ពីបរទេសរបស់កម្ពុជាមានភាពចម្រុះជាងប្រទេសភាគច្រើនដទៃទៀត បើទោះបីជាការវិនិយោគស្ទើរតែទាំងស្រុងមានប្រភពពីតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក — ប្រទេសចិន (រួមទាំងក្រុងហុងកុង) សាធារណរដ្ឋកូរ៉េ សិង្ហបុរី ជប៉ុន និងតៃវ៉ាន់ ដែលជាប្រទេសនៃការវិនិយោគផ្ទាល់ពីបរទេសកំពូលទាំងប្រាំ ស្មើនឹង 69 ភាគរយនៃការវិនិយោគផ្ទាល់ពីបរទេសសរុប (44 ពាន់លានដុល្លារ) ក្នុងឆ្នាំ 2022។ លំហូរនៃការវិនិយោគផ្ទាល់ពីបរទេសមកកាន់ប្រទេសកម្ពុជាមានចំនួន 12.9 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2021 ដែលជាជាប្រទេសទទួលការវិនិយោគផ្ទាល់ពីបរទេសធំជាងគេទី 11 នៅលើពិភពលោកក្នុងលក្ខខណ្ឌធៀបនឹង ផ.ស.ស. និងធំជាងគេទីពីរនៅក្នុងអាស៊ានបន្ទាប់ពីប្រទេសសិង្ហបុរី (26.5 ភាគរយនៃ ផ.ស.ស.) ។ លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជាបានប្រមូលផ្តុំកាន់តែខ្លាំងឡើងក្នុងវិស័យសេវាស្នាក់នៅ សំណង់ អចលនទ្រព្យ និងវិស័យហិរញ្ញវត្ថុ។ ទោះជាយ៉ាងណាក៏ដោយ លំហូរចូលមិនសូវទទួលបានជោគជ័យក្នុងការរួមចំណែកដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច ឬការបង្កើតតម្លៃបន្ថែមក្នុងស្រុកទេ។ តម្លៃកម្លាំងពលកម្មទាប និងការលើកទឹកចិត្តផ្នែកពន្ធ គឺជាកត្តាទាក់ទាញចម្បងពីរ។ [ក]

**រូបភាព B2.1** កំណើននៃការទាញកម្លាំងពលកម្មពីប្រទេសជិតខាង និងពិពិធកម្មនៃខ្សែសង្វាក់ផ្គត់ផ្គង់




**រូបភាព B2.2** ការវិនិយោគផ្ទាល់ពីបរទេស របស់កម្ពុជាតាមវិស័យ (លានដុល្លារ)




**ប្រភព៖** អាជ្ញាធរកម្ពុជា។
**សម្គាល់៖** ACR = កន្លែងស្នាក់នៅ សំណង់ និងអចលនទ្រព្យ។

## ប្រអប់ 2 តើមានអ្វីបន្ថែមទៀតដែលអាចធ្វើបានដើម្បីកែលម្អការរួមចំណែកនៃការវិនិយោគផ្ទាល់ពីបរទេសដល់សេដ្ឋកិច្ច? (ត)

គោលនយោបាយវិនិយោគដើម្បីទាក់ទាញ ជំរុញ និងតភ្ជាប់ការវិនិយោគផ្ទាល់ពីបរទេសត្រូវបានសង្ខេបនៅក្នុងតារាង B2.1 ។ ខណៈពេលដែលកម្ពុជាធ្វើបានល្អក្នុងការទាក់ទាញ ការវិនិយោគផ្ទាល់ពីបរទេស ប្រទេសនេះមិនទទួលបានជោគជ័យក្នុងការតភ្ជាប់ការវិនិយោគផ្ទាល់ពីបរទេសជាមួយនឹងការវិនិយោគក្នុងស្រុកនៅឡើយទេ។ ការកែលម្អបរិយាកាសធុរកិច្ច និងបទប្បញ្ញត្តិធុរកិច្ចដែលផ្តោតលើការផ្តល់អាជ្ញាប័ណ្ណអាជីវកម្ម និងការអនុញ្ញាតឱ្យប្រកបអាជីវកម្មគឺជាការចាំបាច់។ សាជីវកម្មពហុជាតិចាត់ទុកការកែលម្អបរិយាកាសធុរកិច្ចថាជាយុទ្ធសាស្ត្រដែលមានឥទ្ធិពលបំផុតសម្រាប់ការប្រើប្រាស់ប្រភពក្នុងស្រុក។ [៩] ភ័ស្តុតាងជាក់ស្តែងបញ្ជាក់ថា ឧបសគ្គបរិយាកាសធុរកិច្ចមានទំនាក់ទំនងជាមួយនឹងផលិតភាពទាបរបស់ក្រុមហ៊ុនកម្ពុជា។ នៅក្នុងសន្ទស្សន៍ភាពប្រកួតប្រជែងសកលឆ្នាំ 2022 កម្ពុជាជាប់ចំណាត់ថ្នាក់ទាបជាងប្រទេសស្រដៀងគ្នានានាក្នុងវិធានការបរិយាកាសធុរកិច្ចជាច្រើន។ ការដកចេញភ្លាមៗនូវវិធានការគោលនយោបាយតឹងរ៉ឹងដែលដាក់ឱ្យអនុវត្តក្នុងអំឡុងពេលការរាតត្បាតនៃជំងឺ ពោលគឺការអនុវត្តឡើងវិញ និងការពង្រីក "គន្លងបៃតង" របស់គយមានសារៈសំខាន់ណាស់ក្នុងការសម្រួលពាណិជ្ជកម្ម។ ទោះបីជាវិនិយោគិនកត់សម្គាល់ឃើញភាពប្រសើរឡើងយ៉ាងខ្លាំងនៃគុណភាព និងការផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ ការដឹកជញ្ជូន និងអគ្គិសនីនៅតែជាឧបសគ្គមួយក្នុងចំណោមឧបសគ្គធំបំផុតទាំង 10 ។

### តារាង B2.1 គោលនយោបាយវិនិយោគ

| 1. ទាក់ទាញ | 2. ជំរុញ | 3. តភ្ជាប់ |
|---|---|---|
| **គោលបំណង៖** ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសដែលមានផលិតភាពខ្ពស់ កិច្ចការ ចំណែកនៅក្នុងខ្សែសង្វាក់តម្លៃសកល/តំបន់។ គោលការណ៍៖ បើកច្រក (លុបបំបាត់របាំង និងការគាំពារនិយម)។ គោលដៅជំរុញការវិនិយោគ។ ធានាឱ្យមានការអនុវត្តប្រកបដោយតម្លាភាព និងសង្គតិភាពនៃច្បាប់ស្តីពីការវិនិយោគថ្មី និងអនុក្រឹត្យរបស់វា។ តម្រឹមនីតិវិធីផ្តល់អាជ្ញាប័ណ្ណអាជីវកម្ម។ | **គោលបំណង៖** ជំរុញការវិនិយោគផ្ទាល់ពីបរទេសដែលមានស្រាប់សម្រាប់ការវិនិយោគឡើងវិញនៃប្រាក់ចំណូលសាជីវកម្ម បង្កើនការវិនិយោគ និងពង្រីកប្រតិបត្តិការ។ គោលនយោបាយ៖ ពង្រឹងការការពារការវិនិយោគ (សិទ្ធិរបស់ម្ចាស់ភាគហ៊ុន) ការដោះស្រាយជម្លោះ។ បង្កើតតុលាការពាណិជ្ជកម្ម យន្តការរក្សាការវិនិយោគបែបបុរេសកម្ម និងកម្មវិធីថែទាំតាមក្រោយឱ្យចំគោលដៅ។ | **គោលបំណង៖** តភ្ជាប់ការវិនិយោគផ្ទាល់ពីបរទេសទៅកាន់ក្រុមហ៊ុនក្នុងស្រុក និងធ្វើឱ្យស៊ីជម្រៅដល់ការរួមបញ្ចូលខ្សែសង្វាក់តម្លៃសកល។ គោលការណ៍៖ បង្កើតវិបផតថលអនឡាញ និងកម្មវិធីឌីជីថលដើម្បីផ្តល់សេវាកម្មផ្គូផ្គងមូលដ្ឋាន។ បង្កើតកម្មវិធីអភិវឌ្ឍន៍អ្នកផ្គត់ផ្គង់ ការលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម អភិវឌ្ឍធនធានមនុស្ស និងបង្កើនជំនាញ។ សម្រួលការបង្វិលសងពន្ធលើតម្លៃបន្ថែម។ |

**ប្រភព៖** ទិន្នន័យការស្ទង់មតិភាពប្រកួតប្រជែងនៃការវិនិយោគសកលរបស់ធនាគារពិភពលោកឆ្នាំ 2021-2022 ។
**សម្គាល់៖** ប្រអប់នេះត្រូវបានរៀបចំដោយ Peter Kusek, Gerlin May U. Catangui, និង លី សូដេត, ក. ការស្ទង់មតិការវិនិយោគផ្ទាល់ពីបរទេស ឆ្នាំ 2018, ខ. ការស្ទង់មតិការវិនិយោគផ្ទាល់ពីបរទេស ឆ្នាំ 2018 ។ SME = សហគ្រាសធុនតូច និងមធ្យម អ.ត.ប = អាករលើតម្លៃបន្ថែម។

## ការអនុញ្ញាតសាងសង់បានកើនឡើងជាលើកដំបូងចាប់តាំងពីឆ្នាំ 2019

**ជាលើកដំបូងចាប់តាំងពីឆ្នាំ 2019 តម្លៃនៃការអនុញ្ញាតសាងសង់បានកើនឡើងក្នុងអំឡុងពេលពីរខែដំបូងនៃឆ្នាំ 2023។** ប្រហែលជាឆ្លុះបញ្ចាំងពីចំណង់ថ្មីរបស់អ្នកវិនិយោគក្នុងការវិនិយោគលើវិស័យសំណង់ និងអចលនទ្រព្យ តម្លៃការអនុញ្ញាតសាងសង់ដែលបានអនុម័តបានកើនឡើងដល់ 802 លានដុល្លារអាមេរិក ឬកើនឡើង 484 ភាគរយក្នុងអំឡុងពេលពីរខែដំបូងនៃឆ្នាំ 2023 (រូបភាព 7) ។ ក្នុងនោះ ការអនុញ្ញាតសាងសង់គម្រោងនៅខេត្តព្រះសីហនុដែលមានការរីកចម្រើនសំណង់លឿនបំផុតក្នុងអំឡុងពេលមុនការរាតត្បាតមានចំនួន 160 លានដុល្លារអាមេរិក កើនឡើងពីសូន្យ នៅឆ្នាំ 2022 ។ ចំនួននៃការអនុញ្ញាតសាងសង់គិតជាម៉ែត្រការ៉េដែលបានអនុម័តក៏បានកើនឡើងផងដែរ ដែលឈានដល់ 1.2 លាន ឬកើនឡើង 278 ភាគរយ។ ទោះបីជាមានការកែលម្អចំនួនការអនុញ្ញាតសាងសង់ក៏ដោយ សកម្មភាពអភិវឌ្ឍន៍អចលនទ្រព្យទំនងជានៅតែបន្តទទួលរងផលប៉ះពាល់ពីការផ្គត់ផ្គង់លើស។ ប៉ុន្មានឆ្នាំមុនពេលការរាតត្បាតនៃជំងឺតំបន់ទីក្រុងរបស់កម្ពុជាដូចជា រាជធានីភ្នំពេញ តំបន់ទេសចរណ៍ខេត្តសៀមរាប ទីក្រុងមាត់សមុទ្រខេត្តព្រះសីហនុ និងទីប្រជុំជនព្រំដែនប៉ោយប៉ែត និងបាវិតទទួលបានការរីកដុះដាលនៃការសាងសង់យ៉ាងឆាប់រហ័ស។ ដោយសារទីផ្សារក្នុងស្រុកមានទំហំតូច ការរីកដុះដាលបានបង្កើតឱ្យមានការផ្គត់ផ្គង់លើស។ លើសពីនេះ វិស័យហិរញ្ញវត្ថុបានគាំទ្រមួយផ្នែកលើការរីកចំរើននៃវិស័យសំណង់នាពេលថ្មីៗនេះ។ ក្នុងន័យនេះ វាមានសារៈសំខាន់កាន់តែខ្លាំងឡើងក្នុងការការពារស្ថិរភាពហិរញ្ញវត្ថុ (សូមមើលផ្នែកជម្រើសគោលនយោបាយ)។

**ទោះបីជាតម្លៃការអនុញ្ញាតសាងសង់កើនឡើងក្នុងកំឡុងពីរខែដំបូងនៃឆ្នាំ 2023 ក៏ដោយ ការនាំចូលសម្ភារៈសំណង់មានស្ថានភាពផ្សេងៗគ្នា។** ទោះបីការនាំចូលដែកថែបដែលប្រើប្រាស់ជាចម្បងសម្រាប់ឧស្សាហកម្មសំណង់បានបង្កើនល្បឿនដោយកើនឡើង 18.5 ភាគរយក្នុងបរិមាណក្នុងរយៈពេលពេលពីរខែដំបូងនៃឆ្នាំ 2023 (រូបភាព 8) ការនាំចូលបរិក្ខាសំណង់ និងស៊ីម៉ងត៍បានធ្លាក់ចុះក្នុងអត្រា 7.1 ភាគរយ និង 38.3 ភាគរយរៀងគ្នា។

## ការងើបឡើងវិញនៃសកម្មភាពទេសចរណ៍កំពុងបង្កើនល្បឿន

**គាំទ្រដោយការដកចេញទាំងស្រុងនូវវិធានការរឹតបន្តឹងការធ្វើដំណើរដោយសារជំងឺកូវីដ-19 ការមកដល់នៃភ្ញៀវអន្តរជាតិបានកើនឡើងយ៉ាងឆាប់រហ័ស ឈានដល់ 837,000 នាក់ក្នុងអំឡុងពេលពីរខែដំបូងនៃឆ្នាំ 2023 ជិតដល់កម្រិតមុន កូវីដ-19 (រូបភាព 9)។** ការមកដល់តាមផ្លូវអាកាសកំពុងកើនឡើងដែលស្មើនឹង 37.5 ភាគរយនៃការមកដល់សរុបក្នុងឆ្នាំ 2023 កើនឡើងពី 30.1 ភាគរយក្នុងឆ្នាំ 2022។ ដោយឆ្លុះបញ្ចាំងពីការកើនឡើងនៃចំនួនភ្ញៀវទេសចរបរទេសដែលមកទស្សនាខេត្តសៀមរាប ដែលជាតំបន់ទេសចរណ៍ដ៏ធំបំផុតរបស់កម្ពុជា និងដែលមានឧទ្យានបុរាណអង្គរ ការមកដល់របស់ភ្ញៀវអន្តរជាតិនៅអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាបក៏បានកើនឡើងផងដែរ ដែលឈានដល់ 30.4 ភាគរយ (93,000) នៃចំនួនអ្នកមកទស្សនាតាមផ្លូវអាកាសសរុបក្នុងអំឡុងពេលពីរខែដំបូងនៃឆ្នាំ 2023 កើនឡើងពី 10.6 ភាគរយ (3,000) ក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022។ មួយផ្នែកដោយសារកំណើននៃការមកដល់របស់ភ្ញៀវអន្តរជាតិទៅកាន់ប្រទេសថៃ ការមកដល់តាមផ្លូវគោកបានកើនឡើងដល់ 523,000 ក្នុងអំឡុងពេលពីរខែដំបូងនៃឆ្នាំ 2023 កើនឡើងពី 42,000 ក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022។

**ចំនួនភ្ញៀវទេសចរក្នុងស្រុកក៏កើនឡើងផងដែរ។** ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ ក្នុងខែមេសា ឆ្នាំ2023 មានភ្ញៀវទេសចរក្នុងស្រុកប្រមាណ 13លាននាក់ ដែលលើសពីកម្រិតមុនការរាតត្បាត ដែលក្នុងនោះ 2.1លាននាក់បានមកលេងខេត្តសៀមរាប។ ចំណូលបានពីការលក់សំបុត្រទស្សនាអង្គរបានកើនដល់ 7.38 លានដុល្លារក្នុងអំឡុងពេលពីរខែដើមឆ្នាំ 2023 កើនពី 478,000 ដុល្លារក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022។

**បន្ទាប់ពីចិនបើកប្រទេសឡើងវិញ ការមកដល់របស់ភ្ញៀវទេសចរចិនក៏ចាប់ផ្តើមមានសន្ទុះឡើងវិញផងដែរ។** ការមកដល់ពីប្រទេសចិនបានកើនឡើងយ៉ាងឆាប់រហ័សក្នុងឆ្នាំ 2023 កើនដល់ 9.5 ភាគរយនៃការមកដល់សរុបក្នុងអំឡុងពេលពីរខែដំបូងនៃឆ្នាំ 2023 កើនពី 5.8 ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022។ ភ្ញៀវទេសចរចិនជាប់ចំណាត់ថ្នាក់លេខ3 បន្ទាប់ពីភ្ញៀវទេសចរវៀតណាម (28ភាគរយ) និងថៃ (26ភាគរយ) ដែលជាប់ចំណាត់ថ្នាក់លេខ1 និងទី2រៀងគ្នា។

រូបភាព 7 តម្លៃការអនុញ្ញាតសាងសង់ដែលបានអនុម័តបានកើនឡើង (លានដុល្លារ)




**ប្រភព៖** អាជ្ញាធរកម្ពុជា។
**សម្គាល់៖** RHS = មាត្រដ្ឋានខាងស្តាំ; SHV = ក្រុងព្រះសីហនុ; YTD = រហូតដល់ឆ្នាំបច្ចុប្បន្ន ឆ្នាំ/ឆ្នាំ = ធៀបនឹងមួយឆ្នាំមុន។

រូបភាព 8 បរិមាណនៃការនាំចូលសម្ភារៈសំណង់នៅមានកម្រិតទាប
(ឆ្នាំ/ឆ្នាំ, ការផ្លាស់ប្តូរភាគរយ)




**ប្រភព៖** អាជ្ញាធរកម្ពុជា។
**សម្គាល់៖** ឆ្នាំ/ឆ្នាំ = ធៀបនឹងមួយឆ្នាំមុន

## ប្រអប់ 3 ការតភ្ជាប់ "ប៉ូលសេដ្ឋកិច្ចទីបួន" ទៅកាន់ច្រកទ្វារអន្តរជាតិ

កត្តាដែលបណ្តាលមកពីថ្លៃដឹកជញ្ជូនរបស់កម្ពុជាខ្ពស់រួមមាន បណ្តាញដឹកជញ្ជូនមិនគ្រប់គ្រាន់ និងគ្មានប្រសិទ្ធភាព។ ថ្លៃដឹកជញ្ជូនខ្ពស់ធ្វើឱ្យតម្លៃនាំចេញកសិផលរបស់ប្រទេសមានភាពប្រកួតប្រជែងកម្រិតទាប ទោះបីជាតម្លៃទីផ្សារកសិកម្មមានភាពប្រកួតប្រជែងក៏ដោយ។ ជាលទ្ធផល កសិករភាគច្រើនលក់កសិផលរបស់ពួកគេទៅឱ្យឈ្មួញមកពីប្រទេសជិតខាងសម្រាប់ការនាំចេញ។ ទោះបីកម្ពុជាផលិតមើមដំឡូងមីបានជាង 13 លានតោនសម្រាប់នាំចេញ ដែលមានតម្លៃ 728 លានដុល្លារក្នុងមួយឆ្នាំ ការនាំចេញដោយផ្ទាល់ទៅកាន់ប្រទេសចិនមានត្រឹមតែ 16.0 លានដុល្លារអាមេរិក (2.2 ភាគរយ)។[ក] ដូចគ្នានេះដែរ តម្លៃនាំចេញអង្ករដោយផ្ទាល់របស់ប្រទេសមានប្រហែល 20 ភាគរយនៃការនាំចេញអង្ករសរុប។ ដូច្នេះ កម្ពុជាបានវិនិយោគយ៉ាងច្រើនក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសផ្លូវថ្នល់ និងកំពង់ផែ និងមជ្ឈមណ្ឌលដឹកជញ្ជូនថ្មីៗបន្ថែមទៀត ដើម្បីកែលម្អការតភ្ជាប់ក្នុងប្រទេស និងជាមួយទីផ្សារក្នុងតំបន់ និងពិភពលោក។ បណ្តាញផ្លូវថ្នល់ដែលទើបសាងសង់ថ្មីដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា ដោយសារវាតភ្ជាប់មនុស្ស ទំនិញ និងសេវាកម្មក្នុងស្រុក និងក្នុងតំបន់ ទន្ទឹមនឹងនោះជួយសម្រួលពាណិជ្ជកម្ម លើកកម្ពស់ទេសចរណ៍ ជំរុញការវិនិយោគ និងរួមចំណែកដល់ការបង្កើតការងារ និងកាត់បន្ថយភាពក្រីក្រ។

បច្ចុប្បន្ន ការនាំចេញដោយផ្ទាល់នូវផលិតផលកសិកម្ម ឧទាហរណ៍ អង្ករ 88 ភាគរយ និងស្វាយ 78 ភាគរយ ត្រូវបានដឹកចេញពីខេត្តបាត់ដំបងនៅភាគពាយ័ព្យ ដែលជាចំណុចកណ្តាលនៃ “ប៉ូលសេដ្ឋកិច្ចទី 4” របស់កម្ពុជា តាមផ្លូវជាតិលេខ 5 និងបន្ទាប់មកផ្លូវជាតិលេខ 4 (ខ្សែពណ៌ខៀវ) ទៅកាន់ច្រកទ្វារអន្តរជាតិនៃកំពង់ផែក្រុងព្រះសីហនុ ដែលមានចម្ងាយប្រហែល 500 គីឡូម៉ែត្រ និងចំណាយពេលប្រហែល 9 ម៉ោង (រូបភាព B3.1) ។ ទោះយ៉ាងណាក៏ដោយ ជាមួយនឹងច្រករបៀងផ្លូវថ្មី (ខ្សែពណ៌បៃតង) ដែលរួមមានផ្លូវជាតិលេខ 48, 55, 5, 6, 56, 57, 66 និង 68 រួមជាមួយនឹងផ្លូវជាតិលេខ 10 (កំពុងសាងសង់) តភ្ជាប់ជាមួយកំពង់ផែទឹកជ្រៅបុទុមសាគរ ខេត្តកោះកុង ដែលចម្ងាយដឹកជញ្ជូន (និងពេលវេលា) ត្រូវបានប៉ាន់ប្រមាណថានឹងត្រូវកាត់បន្ថយប្រហែលមួយភាគបួន។ “ប៉ូលសេដ្ឋកិច្ចទី4” របស់កម្ពុជា ដែលមានខេត្តផលិតដំណាំនៅភាគពាយ័ព្យសំខាន់ៗចំនួនបួន គឺខេត្តពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ និងប៉ៃលិន រួមជាមួយនឹងខេត្តជាប់ជាប់ព្រំប្រទល់ចំនួនប្រាំមួយ ដែលផលិតកសិផលភាគច្រើនរបស់ប្រទេស ដូចជាស្រូវ ដំឡូងមី មាន ស្វាយ គ្រាប់ស្វាយចន្ទី និងដំណាំផ្សេងទៀត (តារាង B3.1)។[ខ] ច្រករបៀងផ្លូវថ្មីនេះនឹងផ្តល់លទ្ធភាពកាន់តែប្រសើរឡើងទៅកាន់ខេត្តផលិតកសិផល និងកន្លែងកែច្នៃកសិផលសំខាន់ៗនៅភាគពាយ័ព្យ ដែលអាចជំរុញសកម្មភាពសេដ្ឋកិច្ចនៅទីនោះ ដោយសម្រួលដល់ការដឹកជញ្ជូនកសិផល និងការធ្វើដំណើររបស់ប្រជាជន ដែលគាំទ្រដល់អាជីវកម្ម ជាពិសេសក្រុមហ៊ុនកែច្នៃកសិផលឱ្យកាន់តែមានភាពប្រកួតប្រជែងខ្ពស់។

ទោះយ៉ាងណាក៏ដោយ វានឹងត្រូវការពេលវេលាដើម្បីទទួលបានសក្តានុពលពេញលេញ។ ទីមួយ ធនធាន និងកិច្ចខិតខំប្រឹងប្រែងបន្ថែមទាំងពីវិស័យសាធារណៈ និងវិស័យឯកជនគឺជារឿងចាំបាច់ដើម្បី "កំណត់រចនាសម្ព័ន្ធ" ខ្សែសង្វាក់ផ្គត់ផ្គង់កសិកម្មឡើងវិញ ដែលនឹងតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងក្នុងការលើកទឹកចិត្តដល់វិស័យឯកជនឱ្យផ្លាស់ប្តូរទីតាំង (និងវិនិយោគបន្ថែមទៀតលើ) រោងចក្រកែច្នៃកសិផលតាមបណ្តោយ (ឬជិតៗ) ច្រករបៀងផ្លូវថ្មីនេះ។ វាអាចត្រូវបានជំរុញ និងពង្រឹងដោយការផ្តល់ធនធានតាមរយៈយន្តការហិរញ្ញប្បទានកសិកម្ម និងកសិឧស្សាហកម្មដែលមានស្រាប់ ការគាំទ្រផ្នែកបច្ចេកទេស និងសារពើពន្ធ និងការទទួលបានការផ្គត់ផ្គង់ថាមពល។ លើសពីនេះ បណ្តាញផ្លូវជនបទ និងខេត្តដែលតភ្ជាប់

### រូបភាព B 3.1 ប៉ូលសេដ្ឋកិច្ចទីបួន




**ប្រភព៖** ការប៉ាន់ស្មានរបស់អ្នកនិពន្ធ។

### តារាង B3.1 ខេត្តផលិតដំណាំនៅភាគពាយ័ព្យសំខាន់ៗ

| ខេត្ត | ស្រូវអង្ករ | | ដំឡូងមី | | មៀន | |
|---|---|---|---|---|---|---|
| | ពាន់តោន | (%) | ពាន់តោន | (%) | តោន | (%) |
| បាត់ដំបង | 1,514 | 12.4 | 3,276 | 24.8 | 7,457 | 5.7 |
| បន្ទាយមានជ័យ | 1,007 | 8.2 | 1,534 | 11.6 | 82,803 | 63.0 |
| ពោធិសាត់ | 702 | 5.8 | 490 | 3.7 | 355 | 0.3 |
| សៀមរាប | 574 | 4.7 | 530 | 4.0 | - | 0.0 |
| ឧត្តមានជ័យ | 271 | 2.2 | 1,516 | 11.5 | 200 | 0.2 |
| កំពង់ធំ | 976 | 8.0 | 1,068 | 8.1 | 75 | 0.1 |
| កំពត | 537 | 4.4 | 7 | 0.1 | 364 | 0.3 |
| កោះកុង | 27 | 0.2 | 0 | 0.0 | 30 | 0.0 |
| ព្រះវិហារ | 290 | 2.4 | 606 | 4.6 | 52 | 0.0 |
| ប៉ៃលិន | 25 | 0.2 | 649 | 4.9 | 26,780 | 20.4 |
| សរុបតាមផ្នែក | 5,923 | 48.5 | 9,676 | 73.1 | 118,116 | 89.8 |
| ផលិតកម្មសរុប | 12,207 | 100.0 | 13,233 | 100.0 | 131,498 | 100.0 |

**ប្រភព៖** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ2022 **សម្គាល់៖** ត = តោន

### ប្រអប់ 3 ការតភ្ជាប់ "ប៉ូលសេដ្ឋកិច្ចទីបួន" ទៅនឹងច្រកទ្វារអន្តរជាតិ (ត)

ច្រករបៀងផ្លូវថ្មីនេះ នឹងត្រូវសាងសង់ និងកែលម្អ ដើម្បីពង្រីកការចូលទៅកាន់កន្លែងកែច្នៃកសិផលសម្រាប់ការស្តុកទុក កែច្នៃ និងនាំចេញផលិតផលកសិកម្ម។ បណ្តាញផ្លូវជនបទ និងផ្លូវខេត្តភាគច្រើនដែលផលិតកម្មកសិកម្មភាគច្រើនពឹងផ្អែកលើ សម្រាប់ការផ្គត់ផ្គង់ធាតុចូល និងការចូលទៅកាន់ទីផ្សារ បានចុះខ្សោយ គ្មានការតភ្ជាប់ ឬមិនទាន់ក្រាលកៅស៊ូ ដូចដែលបានបង្ហាញដោយការធ្លាក់ចុះនៃសន្ទស្សន៍គុណភាពហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរបស់កម្ពុជាពី 3.1 (2010) ដល់ 2.1 (2018) ក្នុងចំណោមពិន្ទុសរុប 7.0 ។[គ]

ទីពីរ ហើយប្រហែលជាកាន់តែសំខាន់ ការលើកកម្ពស់ការដឹកជញ្ជូន និងការសម្របសម្រួលពាណិជ្ជកម្ម ដើម្បីបង្កើនភាពអាចទុកចិត្តបាននៃខ្សែសង្វាក់ផ្គត់ផ្គង់ និងគុណភាពសេវាកម្ម គឺជាគន្លឹះសម្រាប់ការរៀបចំឡើងវិញប្រកបដោយជោគជ័យ។ វានឹងធ្វើអោយប្រសើរឡើងនូវដំណើរការដឹកជញ្ជូន និងភស្តុភាររបស់កម្ពុជា ដោយសារការព្យាករណ៍មិនគ្រាន់តែទាក់ទងនឹងកត្តាពេលវេលា និងការចំណាយប៉ុណ្ណោះទេ ប៉ុន្តែក៏ជាធាតុផ្សំនៃគុណភាពនៃការដឹកជញ្ជូនផងដែរ។ មូលហេតុជាច្រើននៃការពន្យារពេល ឬភាពមិនអាចទុកចិត្តបាននៅក្នុងវិស័យភស្តុភាររបស់កម្ពុជា ដូចជាគុណភាពនៃសេវាកម្ម ឬតម្លៃ និងល្បឿននៃដំណើរការបញ្ចេញទំនិញពីគយ អាចត្រូវបានដោះស្រាយតាមរយៈការអន្តរាគមន៍ពីអាជ្ញាធរកម្ពុជា។ ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយការចំណាយលើ "ការធ្វើអាជីវកម្ម" ដែលរួមមាន "ការទូទាត់ក្រៅផ្លូវការ" ដើម្បីទទួលបានឯកសារទាន់ពេលវេលាសម្រាប់ការដឹកជញ្ជូន ឬដើម្បីទទួលបានការបោះត្រាមុនម៉ោងបទការិយាល័យ ឬដើម្បីអាចចេញរថយន្តដឹកទំនិញទៅ ឬមកពីកំពង់ផែ និងព្រំដែន។

**សម្គាល់៖** ប្រអប់នេះត្រូវបានរៀបចំដោយ លោក លី សូដេត និងលោក ភឹម រុនស៊ីណារិទ្ធ។

ក. 2020-25 គោលនយោបាយជាតិដំឡូងមី https://www.undp.org/cambodia/publications/national-cassava-policy

ខ. យោងតាមអាជ្ញាធរ "ប៉ូលសេដ្ឋកិច្ច" សំដៅទៅលើតំបន់ភូមិសាស្ត្រនៃសកម្មភាពសេដ្ឋកិច្ចប្រមូលផ្តុំ។ បច្ចុប្បន្ន កម្ពុជាមានប៉ូលសេដ្ឋកិច្ចចំនួនប្រាំ ដែលរួមមាន រាជធានីភ្នំពេញ ខេត្តព្រះសីហនុ ខេត្តសៀមរាប តំបន់ភាគពាយ័ព្យ និងភូមិភាគឦសាន។

គ. សូមមើល https://www.theglobaleconomy.com/Cambodia/roads_quality/ .

## ផ.ស.ស. វិស័យកសិកម្មត្រូវបានប៉ាន់ប្រមាណថាមានការកើនឡើងតិចតួច

**វិស័យកសិកម្មបានបន្តដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ច។** ទោះបីចំណែកនៃវិស័យកសិកម្មនៅក្នុង ផ.ស.ស. បានធ្លាក់ចុះមកត្រឹម 22 ភាគរយក្នុងឆ្នាំ 2022 ដោយសារការផ្លាស់ប្តូររចនាសម្ព័ន្ធរបស់ប្រទេស វិស័យនេះបានបន្តផ្តល់ការងារច្រើនជាងមួយភាគបី (35.7 ភាគរយ) នៃការងារសរុប។ លើសពីនេះ ផ.ស.ស. វិស័យកសិកម្ម (ក្នុងតម្លៃថេរ) ដែលជាកំណើនពិតនៃវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានអាជ្ញាធរប៉ាន់ប្រមាណថានឹងកើនឡើង 1.0 ភាគរយនៅឆ្នាំ 2022។[3] យ៉ាងណាក៏ដោយ ផលិតកម្មស្រូវបានធ្លាក់ចុះកាលពីឆ្នាំមុន។ បណ្តាលមកពីកត្តាអាកាសធាតុមិនស្រួលអំណោយផលដែលប៉ះពាល់ដល់ខេត្តចំនួន 22 ផលិតកម្មស្រូវសរុបក្នុងអំឡុងឆ្នាំផលិត 2022-23 បានធ្លាក់ចុះមកនៅត្រឹម 11.6 លានតោន ឬថយចុះ 4.7 ភាគរយ។ រងគ្រោះដោយគ្រោះរាំងស្ងួត និងទឹកជំនន់ ដែលបានធ្វើឱ្យខូចខាត 3.9 ភាគរយនៃផ្ទៃដីដាំដុះស្រូវសរុប ផ្ទៃដីប្រមូលផលស្រូវបានធ្លាក់ចុះ 5.5 ភាគរយមកនៅ 3.3 លានហិកតា។ តំបន់ប្រមូលផលស្រូវទាំងរដូវវស្សា និងរដូវប្រាំងបានធ្លាក់ចុះ 6.6 ភាគរយ និង 1.2 ភាគរយរៀងគ្នា។ ទោះជាយ៉ាងនេះក្តី ទិន្នផលស្រូវជាមធ្យមបានកើនឡើងតិចតួចដល់ 3.5 តោនក្នុងមួយហិកតា។ ទិន្នផលស្រូវរដូវវស្សាមានចំនួន 75 ភាគរយ ខណៈផលិតកម្មស្រូវរដូវប្រាំងមានចំនួន 25 ភាគរយ។

**ការផលិតដំណាំមិនមែនស្រូវមានស្ថានភាពផ្សេងៗគ្នា។** នៅឆ្នាំ 2022 ផលិតកម្មកៅស៊ូបានកើនឡើងដល់ 382,000 តោន ឬកើន 3.8 ភាគរយ ដោយសារកិច្ចខិតខំប្រឹងប្រែងដើម្បីជំរុញផលិតកម្មកៅស៊ូខ្នាតតូចចាប់ផ្តើមបង្ហាញលទ្ធផល។ ផលិតកម្មដំឡូងមីដែលជាដំណាំអាទិភាពទីពីរបន្ទាប់ពីស្រូវបានធ្លាក់ចុះមកត្រឹម 14.2 លានតោន ឬ 3.2 ភាគរយ បើទោះបីជាការដាក់ចេញនូវគោលនយោបាយជាតិដំឡូងមីឆ្នាំ 2020-25 នៅឆ្នាំ 2020 ក៏ដោយ។[4] ផលិតកម្មគ្រាប់ស្វាយចន្ទីបានកើនឡើងដល់ 508,283 តោន ឬកើនឡើង 7.5 ភាគរយ។ ក្នុងចំណោមផ្ទៃដីដាំដុះដំណាំមិនមែនស្រូវសរុប 1.5 លានហិកតា មាន 2.3 ភាគរយរងផលប៉ះពាល់ដោយគ្រោះរាំងស្ងួត។

---

3 ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឆ្នាំ 2023 ។

4 https://www.undp.org/sites/g/files/zskgke326/files/migration/kh/UNDPKH_ENG_Cassava-policy.pdf.

## ការនាំចេញផលិតផលកសិកម្មមានភាពប្រសើរឡើង

**យោងតាមសហព័ន្ធស្រូវអង្ករកម្ពុជា ឆ្នាំនេះតម្លៃស្រូវ និងដំណាំកសិផលផ្សេងទៀតបានកើនឡើងប្រហែលពី 10 ភាគរយ ទៅ 20 ភាគរយ ដែលគាំទ្រដល់ការនាំចេញផលិតផលកសិកម្មរបស់កម្ពុជា។** អង្ករក្រអូប និងអង្ករស មានតម្លៃ 780 ដុល្លារ និង 520 ដុល្លារក្នុងមួយតោនរៀងគ្នា។ បើនិយាយពីតម្លៃវិញ ការនាំចេញអង្ករត្រូវបានពង្រីក កើនឡើងដល់ 72.6 លានដុល្លារអាមេរិក ឬកើន 4.5 ភាគរយក្នុងអំឡុងពេលពីរខែដំបូងនៃឆ្នាំ 2023។ ដោយសារតម្លៃដឹកជញ្ជូនមានកម្រិតមធ្យម ហើយវិធានការគាំពារពាណិជ្ជកម្មដែលសហភាពអឺរ៉ុបដាក់លើអង្ករកម្ពុជាបានបញ្ចប់ក្នុងខែមករា ឆ្នាំ 2022 [5] ការនាំចេញអង្ករទៅកាន់ទីផ្សារសហភាពអឺរ៉ុបមានភាពប្រសើរឡើង។ ក្រៅពីទំនិញកសិកម្មបែបប្រពៃណី ដូចជា អង្ករ ដំឡូងមី និងកៅស៊ូ ការនាំចេញស្វាយ និងចេកស្រស់ជាពិសេសទៅកាន់ទីផ្សារប្រទេសចិនបានលេចចេញជារូបរាងឡើង។ ការនាំចេញចេកស្រស់បានកើនឡើងយ៉ាងឆាប់រហ័សដល់ 182 លានដុល្លារក្នុងឆ្នាំ 2022 កើនពី 49.3 លានដុល្លារក្នុងឆ្នាំ 2019។ ការបើកដំណើរការឡើងវិញរបស់ប្រទេសចិននឹងមានសក្តានុពលជំរុញការនាំចេញទំនិញកសិកម្មរបស់កម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ការប្រែប្រួលតម្លៃបានបន្តប៉ះពាល់ដល់ដំណើរការនាំចេញផលិតផលិកសិកម្ម ខណៈដែលលក្ខខណ្ឌអាកាសធាតុមិនសូវអំណោយផលប៉ះពាល់ដល់ទិន្នផល និងគុណភាពនៃដំណាំមួយចំនួន។

**ដោយសារតម្លៃកែច្នៃមានកម្រិតខ្ពស់ កសិករភាគច្រើនលក់កសិផលរបស់ពួកគេទៅឱ្យឈ្មួញមកពីប្រទេសជិតខាងសម្រាប់ការនាំចេញ។** ការនាំចេញផលិតផលកសិកម្មកែច្នៃ និងមិនកែច្នៃសរុបសម្រេចបាន 790.5 លានដុល្លារ[6] ស្មើនឹង 29.0 ភាគរយនៃការនាំចេញទំនិញសរុប (មិនរាប់បញ្ចូលមាស) ក្នុងអំឡុងពេលពីរខែដំបូងនៃឆ្នាំ 2023 ដែលក្នុងនោះការនាំចេញផលិតផលកសិកម្មកែច្នៃមានចំនួនតិចជាង 1/4 (23.4 ភាគរយ)។ កត្តានេះឆ្លុះបញ្ចាំងពីសក្តានុពលដ៏ធំដែលមិនទាន់បានទាញយកដែលកម្ពុជាអាចទទួលបានពីការពង្រីកឧស្សាហកម្មកែច្នៃកសិផលរបស់ខ្លួន (រូបភាព 10) ដែលនៅតែមានភាពទន់ខ្សោយដោយសារតម្លៃថាមពលខ្ពស់ (និងស្ថិរភាពនៃការផ្គត់ផ្គង់) របស់ប្រទេស ការដឹកជញ្ជូន និងការធ្វើអាជីវកម្ម។ ចំណូល 72.6 លានដុល្លារអាមេរិកពីការនាំចេញអង្ករមានត្រឹមតែ 28 ភាគរយនៃការនាំចេញអង្ករសរុបចំនួន 258.5 លានដុល្លារអាមេរិក ក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ 2023។

រូបភាព 9 ការមកដល់នៃភ្ញៀវអន្តរជាតិ និងចំណូលបានពីការលក់សំបុត្រទស្សនាអង្គរបានងើបឡើងវិញយ៉ាងឆាប់រហ័ស (លាន)




**ប្រភព៖** អាជ្ញាធរកម្ពុជា។
**សម្គាល់៖** RHS = មាត្រដ្ឋានខាងស្តាំ។

រូបភាព 10 ការនាំចេញផលិតផលកសិកម្ម - សក្តានុពលកែច្នៃកសិផលដែលមិនបានអនុវត្ត (លានដុល្លារ)




**ប្រភព៖** អាជ្ញាធរកម្ពុជា។

5 សហភាពអឺរ៉ុបដាក់វិធានការគាំពារលើអង្ករពីកម្ពុជា។ នៅថ្ងៃទី 18 ខែមករា ឆ្នាំ 2019 សហភាពអឺរ៉ុបបានកំណត់ឡើងវិញនូវពន្ធគយធម្មតាលើផលិតផលអង្កររបស់កម្ពុជាចំនួន 175 អឺរ៉ូក្នុងមួយតោនក្នុងឆ្នាំទីមួយ ដោយកាត់បន្ថយជាបន្តបន្ទាប់មកត្រឹម 150 អឺរ៉ូក្នុងមួយតោនក្នុងឆ្នាំទី 2 និង 125 អឺរ៉ូក្នុងមួយតោនក្នុងឆ្នាំទី 3 ។ https://trade.ec.europa.eu/doclib/press/index.cfm?id=1970 .

6 ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឆ្នាំ 2023 ។ "របាយការណ៍ប្រចាំឆ្នាំ 2022-23" ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីភ្នំពេញ។

## ការប្រើប្រាស់របស់អតិថិជនត្រូវបានពង្រឹង ដែលជំរុញដោយកំណើនតម្រូវការអតិថិជន

**តម្រូវការកើនឡើង ដែលគាំទ្រដោយការដកចេញទាំងស្រុងនៃការរឹតបន្តឹងការធ្វើដំណើរដោយសារជំងឺកូវីដ-19 និងការធ្លាក់ចុះនៃសម្ពាធអតិផរណា បានជំរុញឱ្យមានការងើបឡើងវិញនូវការប្រើប្រាស់ក្នុងស្រុក ដែលមានចំនួនប្រហែលបីភាគបួននៃ ផ.ស.ស. ។** លើសពីនេះ ការត្រឡប់មកវិញនៃការមកដល់នៃភ្ញៀវអន្តរជាតិបានជំរុញការប្រើប្រាស់ (និងការវិនិយោគ) បន្ថែមទៀត។ ការនាំចូលទំនិញប្រើប្រាស់ និងប្រើប្រាស់បានយូរបានបន្តងើបឡើងវិញក្នុងឆ្នាំ2023។ ក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ 2023 ការនាំចូលទំនិញប្រើប្រាស់បានកើនឡើង ដូចជាប្រេងសាំង 28.1 ភាគរយ អាល់កុល 16.7 ភាគរយ ប្រេងចម្អិនអាហារ 79.7 ភាគរយ និងស្ករ 49.6 ភាគរយ ឆ្នាំ/ឆ្នាំ រៀងគ្នា។ ដូចគ្នានេះដែរ តម្លៃនៃការនាំចូលទំនិញប្រើប្រាស់បានយូរ ដូចជារថយន្តដឹកអ្នកដំណើរ និងរថយន្តក្រុងបានកើនឡើងដល់ 6.63 ភាគរយ និង 127.1 ភាគរយរៀងគ្នា ឆ្នាំ/ឆ្នាំ។ ជាលទ្ធផល វិស័យសេវាកម្ម ជាពិសេសការលក់ដុំ លក់រាយ ការធ្វើដំណើរ និងទេសចរណ៍ មានសន្ទុះកើនឡើង។

## អតិផរណាបានធូរស្រាលខ្លាំង ដោយត្រឡប់ទៅកម្រិតមុនវិបត្តិ

**ដោយសារភាពធូរស្រាលនៃតម្លៃអាហារ និងប្រេង សន្ទស្សន៍តម្លៃអ្នកប្រើប្រាស់របស់កម្ពុជាបានធូរស្រាលយ៉ាងខ្លាំង ដោយឈានដល់ 2.2% ឆ្នាំ/ឆ្នាំ ក្នុងខែកុម្ភៈ ឆ្នាំ 2023។** (រូបភាព 11) ។ អតិផរណាបានឡើងដល់កម្រិត 7.8 ភាគរយ ដែលជាកម្រិតខ្ពស់រយៈពេល 13 ឆ្នាំ ក្នុងខែមិថុនា ឆ្នាំ 2022 ដែលបណ្តាលមកពីការកើនឡើងខ្ពស់នៃតម្លៃអាហារ និងផលិតផលឥន្ធនៈបង្ករដោយការវិបត្តិតម្លៃអាហារ និងប្រេងសកល។ ភាពធូរស្រាលនៃតម្លៃម្ហូបអាហារ ជាពិសេសសាច់ បន្លែ និងផ្លែឈើស្រស់ បានធ្វើឱ្យអតិផរណាធ្លាក់ចុះយ៉ាងខ្លាំង ដោយសារសមាសធាតុអាហារ (សន្ទស្សន៍រង) មានទម្ងន់ 43 ភាគរយនៃកញ្ចប់អតិផរណា។ ការរួមចំណែកនៃសន្ទស្សន៍រងអាហារចំពោះអតិផរណាបានធ្លាក់ចុះដល់ 1.7 ពិន្ទុភាគរយនៅក្នុងខែកុម្ភៈ ឆ្នាំ 2023 ចុះពីចំណុចកំពូល 3.6 ពិន្ទុភាគរយនៅក្នុងខែមិថុនា ឆ្នាំ 2022។ ក្នុងអំឡុងពេលដូចគ្នានេះ ដោយស្ថិរភាព តម្លៃប្រេង ជាពិសេសតម្លៃសាំង និងប្រេងម៉ាស៊ូត ការចូលរួមចំណែកនៃសន្ទស្សន៍រងនៃការដឹកជញ្ជូនបានធ្លាក់ចុះដល់ 0.01 ពិន្ទុភាគរយ ចុះពីចំណុចកំពូល 1.8 ពិន្ទុភាគរយ។ សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់របស់កម្ពុជា ដោយមិនរាប់បញ្ចូលម្ហូបអាហារ បានធ្លាក់ចុះមកត្រឹម 0.5 ភាគរយ ឆ្នាំ/ឆ្នាំ ក្នុងខែកុម្ភៈ ឆ្នាំ 2023 ចុះពី 4.3 ភាគរយនៅក្នុងខែមិថុនា ឆ្នាំ 2022។

**ជាមួយនឹងការធ្លាក់ចុះតម្លៃតិចតួចនៃរូបិយប័ណ្ណក្នុងស្រុកធៀបនឹងអត្រាប្តូរប្រាក់ដុល្លារអាមេរិក អត្រាអតិផរណាដែលបានគណនាក្នុងលក្ខខណ្ឌប្រាក់ដុល្លារអាមេរិកគឺ 1.2 ភាគរយក្នុងខែកុម្ភៈ ឆ្នាំ 2023[7] ដែលទាបជាងអត្រាអតិផរណាបច្ចុប្បន្ន 2.2 ភាគរយ ឆ្នាំ/ឆ្នាំ ក្នុងលក្ខខណ្ឌរូបិយប័ណ្ណក្នុងស្រុក។** ប្រការនេះបានការពារតម្លៃ និងអំណាចទិញនៃទ្រព្យសកម្មជាប្រាក់រៀល (អ្នកដែលមានប្រាក់ចំណូលជាប្រាក់រៀល) ដែលជាគោលបំណងសំខាន់មួយក្នុងការរក្សាលំនឹងអត្រាប្តូរប្រាក់រវាងប្រាក់រៀលនឹងប្រាក់ដុល្លារ។

រូបភាព 11 អតិផរណាបានធូរស្រាលបន្ទាប់ពីការកើនឡើងខ្ពស់ ការរួមចំណែកដល់អតិផរណារយៈពេល 12 ខែ (ពិន្ទុភាគរយ)




**ប្រភព៖** អាជ្ញាធរកម្ពុជា។

រូបភាព 12 អតិផរណានៅក្នុងប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា (ការផ្លាស់ប្តូរភាគរយ ឆ្នាំ/ឆ្នាំ)




**ប្រភព៖** Haver Analytics ។

**សម្គាល់៖** ឆ្នាំ/ឆ្នាំ = ធៀបនឹងមួយឆ្នាំមុន

7 អតិផរណានៅក្នុងលក្ខខណ្ឌរបស់សហរដ្ឋអាមេរិកត្រូវបានកំណត់ថាជាសមាមាត្រនៃការផ្លាស់ប្តូរសន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ទៅនឹងការផ្លាស់ប្តូរសន្ទស្សន៍អត្រាប្តូរប្រាក់រវាងដុល្លារអាមេរិកនិងប្រាក់រៀល។ អត្រាប្រាក់រៀលធៀបនឹងដុល្លារអាមេរិកនេះត្រូវបានធ្វើលិបិក្រមដំបូង ដោយប្រើឆ្នាំមូលដ្ឋានដូចគ្នានឹងសន្ទស្សន៍តម្លៃទំនិញប្រើប្រាស់។ ប្រសិនបើសន្ទស្សន៍អត្រាប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមិនផ្លាស់ប្តូរ អតិផរណាដែលបានគណនាក្នុងលក្ខខណ្ឌប្រាក់ដុល្លារអាមេរិកគឺស្មើនឹងអតិផរណានៅក្នុងលក្ខខណ្ឌរូបិយប័ណ្ណក្នុងស្រុក។ នៅពេលដែលរូបិយប័ណ្ណក្នុងស្រុកធ្លាក់តម្លៃធៀបនឹងប្រាក់ដុល្លារអាមេរិក សន្ទស្សន៍ប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកកើនឡើង ហើយអនុបាតនៃការផ្លាស់ប្តូរសន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ ធៀបនឹងការផ្លាស់ប្តូរសន្ទស្សន៍អត្រាប្តូរប្រាក់ថយចុះ។ អតិផរណាក្នុងលក្ខខណ្ឌជាប្រាក់ដុល្លារអាមេរិក នៅក្នុងករណីនេះ គឺទាបជាងតម្លៃរូបិយប័ណ្ណក្នុងស្រុក។

## សមតុល្យគណនីចរន្តមានភាពប្រសើរឡើង ដោយសារការធូរស្រាលនៃវិបត្តិតម្លៃប្រេង

**ថ្វីបើការនាំចេញទំនិញធ្លាក់ចុះក៏ដោយ សមតុល្យគណនីចរន្តកំពុងមានភាពប្រសើរឡើង ដោយសារតម្លៃប្រេងមានកម្រិតមធ្យម។** ជាមួយនឹងការរីកចម្រើនជារួមនៅក្នុងសកម្មភាពសេដ្ឋកិច្ច រួមទាំងការងើបឡើងវិញនៃឧស្សាហកម្មធ្វើដំណើរ និងទេសចរណ៍ សេវាកម្មសុទ្ធដែលភាគច្រើនជាការមកដល់នៃភ្ញៀវទេសចរ និងប្រាក់ចំណូលបន្ទាប់បន្សំ ដែលភាគច្រើនជាការផ្ញើប្រាក់ចូលប្រទេស កំពុងកើនឡើង។ នៅឆ្នាំ 2022 ឱនភាពពាណិជ្ជកម្មបានរួមតូច ដោយសារការនាំចេញរឹងមាំ ដែលបណ្ដាលឱ្យមានភាពប្រសើរឡើងនៃសមតុល្យគណនីចរន្ត (រូបភាព 13)។ កំណើនការនាំចេញទំនិញរបស់កម្ពុជាបានកើនឡើងកាលពីឆ្នាំមុន លើសពីអត្រាកំណើនមុនការរាតត្បាតនៃជំងឺ។ ការនាំចេញទំនិញ (មិនរាប់បញ្ចូលមាស) បានកើនឡើង 22.5 ភាគរយ ឆ្នាំ/ឆ្នាំ ក្នុងឆ្នាំ 2022 ឡើងពី 17.9 ភាគរយក្នុងឆ្នាំ 2021។ ក្នុងអំឡុងពេលដូចគ្នានេះ កំណើននៃការនាំចូលទំនិញ (មិនរាប់បញ្ចូលមាស) បានថយចុះមកត្រឹម 11.9 ភាគរយ ឆ្នាំ/ឆ្នាំ ធ្លាក់ចុះពី 25.9 ភាគរយ។ កត្តានេះនាំឱ្យមានការកែលម្អសមតុល្យពាណិជ្ជកម្ម។ ជាលទ្ធផល ឱនភាពគណនីចរន្តត្រូវបានប៉ាន់ប្រមាណថាបានរួមតូចមកត្រឹម 26.3 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2022។ ឱនភាពគណនីចរន្តត្រូវបានបន្តទប់ទល់ដោយហិរញ្ញប្បទានទូលំទូលាយនៃលំហូរចូលមូលធន ជាពិសេសលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស ដែលមានស្ថិរភាពទូលំទូលាយ ហើយត្រូវបានប៉ាន់ប្រមាណថាមានចំនួនប្រហែល 4.0 ពាន់លានដុល្លារអាមេរិកក្នុងកំឡុងឆ្នាំ 2020-22 និងទុនបម្រុងអន្តរជាតិ។ លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសបន្ត និងការផ្ដល់ហិរញ្ញប្បទានសម្បទានគ្របដណ្ដប់យ៉ាងទូលំទូលាយលើតម្រូវការហិរញ្ញប្បទានខាងក្រៅ (សូមមើលការពិភាក្សាបន្ថែមស្ដីពីការផ្ដល់ហិរញ្ញប្បទានសម្បទាន-ការទូទាត់បំណុលក្រោមផ្នែកសារពើពន្ធខាងក្រោម)។

**ទោះបីនៅមានស្ថិរភាព ដោយមានតម្លៃប្រហែល 4,100 រៀលក្នុងមួយដុល្លារអាមេរិកក៏ដោយ អត្រាប្តូរប្រាក់បានឡើងថ្លៃធៀបនឹងរូបិយប័ណ្ណរបស់ដៃគូពាណិជ្ជកម្មផ្សេងទៀត។** អត្រាប្ដូរប្រាក់រៀល-ដុល្លារអាមេរិកស្ថិតក្រោមសម្ពាធកើនឡើង នៅពេលដែលធនាគារកណ្ដាលអាមេរិកបានដំឡើងអត្រាការប្រាក់ដើម្បីគ្រប់គ្រងអតិផរណាខ្ពស់របស់ខ្លួន (សូមមើលផ្នែករូបិយវត្ថុខាងក្រោមសម្រាប់ការពិភាក្សាបន្ថែមអំពីការកើនឡើងអត្រាការប្រាក់)។ អត្រាប្ដូរប្រាក់រៀលក្នុងមួយដុល្លារអាមេរិកបានធ្លាក់ចុះតិចតួចចាប់តាំងពីខែឧសភា ឆ្នាំ 2022 (រូបភាព 14)។ ការរក្សាលំនឹងអត្រាប្ដូរប្រាក់រវាងប្រាក់រៀលនឹងប្រាក់ដុល្លារបានធ្វើឱ្យប្រាក់រៀលឡើងថ្លៃធៀបនឹងរូបិយប័ណ្ណក្នុងតំបន់ជាច្រើន ជាពិសេសប្រាក់យន់ចិន ប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម។ ប្រាក់រៀលក៏បានឡើងថ្លៃធៀបនឹងប្រាក់អឺរ៉ូ ប្រាក់ដុល្លារកាណាដា និងប្រាក់ផោនអង់គ្លេស ដែលធ្វើឲ្យការនាំចេញរបស់កម្ពុជាមិនសូវមានភាពប្រកួតប្រជែង។ ប្រហែលដោយសារអន្តរាគមន៍ដើម្បីរក្សាស្ថិរភាព រូបិយប័ណ្ណទុនបម្រុងអន្តរជាតិសរុបរបស់កម្ពុជាបានធ្លាក់ចុះមកត្រឹម 17.7 ពាន់លានដុល្លារអាមេរិក (ប្រហែលប្រាំពីរខែនៃការនាំចូល) ក្នុងខែកុម្ភៈ ឆ្នាំ 2023 ចុះពី 20.2 ពាន់លានដុល្លារអាមេរិកនៅចុងឆ្នាំ 2021។

រូបភាព 13 គណនីចរន្តមានភាពប្រសើរឡើង
(ភាគរយនៃ ផ.ស.ស. ដោយមិនរាប់បញ្ចូលមាស)




**ប្រភព៖** អាជ្ញាធរកម្ពុជា និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក។
**សម្គាល់៖** CAB = សមតុល្យគណនីចរន្ត; RHS = មាត្រដ្ឋានខាងស្តាំ។

រូបភាព 14 អត្រាប្តូរប្រាក់រៀល-ដុល្លារអាមេរិក ស្ថិតក្រោមសម្ពាធ




**ប្រភព៖** អាជ្ញាធរកម្ពុជា។
**សម្គាល់៖** RHS = មាត្រដ្ឋានខាងស្តាំ។

## កំណើនសាច់ប្រាក់ជារួមបានបន្តថមថយ

**កំណើនសាច់ប្រាក់ជារួមបានបន្តថមថយដែលទំនងជាឆ្លុះបញ្ចាំងពីការរឹតបន្តឹងហិរញ្ញវត្ថុសកល។** ដោយសារសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់ ធនាគារកណ្ដាលរបស់ប្រទេសគឺធនាគារជាតិនៃកម្ពុជា មានលទ្ធភាពតិចតួចក្នុងការមានឥទ្ធិពលលើការផ្គត់ផ្គង់សាច់ប្រាក់។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីគាំទ្រសន្ទនីយភាពចាំបាច់សម្រាប់ការងើបឡើងវិញនៃសេដ្ឋកិច្ច ធនាគារកណ្ដាលបានរក្សាសមាមាត្រតម្រូវការទុនបម្រុង 7 ភាគរយសម្រាប់ទាំងប្រាក់បញ្ញើ និងកម្ចីជាប្រាក់ដុល្លារអាមេរិក និងប្រាក់រៀល។ ជំរុញដោយការបន្ធូរបន្ថយប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស កំណើនសាច់ប្រាក់ជារួម (M2) បានថយចុះមកត្រឹម 6.8 ភាគរយ ឆ្នាំ/ឆ្នាំ ក្នុងខែកុម្ភៈ ឆ្នាំ 2023 ចុះពី 14.5 ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022 (រូបភាព 15)។ ក្នុងចំណោមកំណើនសាច់ប្រាក់ជារួម 6.8 ភាគរយ ការរួមចំណែកនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស (និងប្រាក់បញ្ញើផ្សេងទៀត) ប្រាក់បញ្ញើដែលអាចផ្ទេរបាន និងរូបិយប័ណ្ណកំពុងចរាចរមាន 5.7 ពិន្ទុភាគរយ អវិជ្ជមាន 2.3 ពិន្ទុភាគរយ និងអវិជ្ជមាន 0.1 ភាគរយរៀងគ្នា ធ្លាក់ចុះពី 11.7 ពិន្ទុភាគរយ 3.2 ពិន្ទុភាគរយ និង 0.3 ពិន្ទុភាគរយរៀងគ្នា។ នៅពេលដែលលំហូរចូលមូលធនមានការថយចុះ ការដាក់បញ្ចូលរូបិយប័ណ្ណក្នុងស្រុកឱ្យចរាចរត្រូវបានរឹតត្បិតកាន់តែខ្លាំងឡើង ដោយសារសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់។ ដូច្នេះ ដូចដែលបានរៀបរាប់ខាងលើ ការរួមចំណែកនៃរូបិយប័ណ្ណ (ក្នុងស្រុក) ដែលកំពុងចរាចរដល់កំណើនសាច់ប្រាក់ជារួម បានធ្លាក់ចុះមកនៅអវិជ្ជមាន 2.3 ពិន្ទុភាគរយក្នុងខែកុម្ភៈ ឆ្នាំ 2023 ចុះពី 0.3 ភាគរយក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ 2022។ ការរួមចំណែកអវិជ្ជមាននៃរូបិយប័ណ្ណក្នុងស្រុកដែលកំពុងចរាចរដល់កំណើនសាច់ប្រាក់ជារួមក៏អាចឆ្លុះបញ្ចាំងពីអន្តរាគមន៍របស់ធនាគារកណ្ដាលនៅក្នុងទីផ្សារប្តូរប្រាក់បរទេស ដោយការបញ្ចេញប្រាក់ដុល្លារអាមេរិកផងដែរ។

## កំណើនឥណទានបានធ្លាក់ចុះយ៉ាងខ្លាំង ប៉ុន្តែនៅតែមានការប្រមូលផ្តុំឥណទាននៅក្នុងវិស័យអចលនទ្រព្យ

**ទោះបីវានៅបន្តកើនឡើងលឿនជាងកំណើន ផ.ស.ស. ចរឹកឥណទានក្នុងស្រុកបានថមថយយ៉ាងខ្លាំង ក្នុងកំណើន 14.8 ភាគរយ ឆ្នាំ/ឆ្នាំ ដែលជាកម្រិតទាបរយៈពេល 13 ឆ្នាំចុងក្រោយក្នុងខែកុម្ភៈ ឆ្នាំ 2023 ទាបខ្លាំងជាងអត្រាកំណើន 22.0 ភាគរយដែលបានកត់ត្រាក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022 (រូបភាព 16)។** កំណើនឥណទានកាន់តែមានការរឹតត្បិតខ្លាំង ខណៈធនាគារប្រឈមនឹងការកើនឡើងថ្លៃដើមនៃកម្ចី ដោយសារកំណើនអត្រាការប្រាក់សកល។[8] ប៉ុន្តែ អនុបាតឥណទានធៀបនឹង ផ.ស.ស. បានកើនឡើងបន្ថែមទៀត ដោយឈានដល់ 183.7 ភាគរយក្នុងឆ្នាំ 2022 កើនឡើងពី 37.0 ភាគរយកាលពីមួយទសវត្សរ៍មុន។ កំណើនយ៉ាងឆាប់រហ័សនៃឥណទានក្នុងស្រុកដែលកើនឡើងក្នុងអត្រាជាមធ្យមប្រហែល 30 ភាគរយក្នុងមួយឆ្នាំស្ទើរតែមួយទសវត្សរ៍ក្នុងអំឡុងពេលមុនវិបត្តិកូវីដ-19 មានការថយចុះយ៉ាងខ្លាំងក្នុងឆ្នាំ 2020 ដោយសារការរាតត្បាតនៃជំងឺបានវាយប្រហារ។

រូបភាព 15 កំណើនសាច់ប្រាក់ជារួមបានថយចុះ

ការរួមចំណែកដល់កំណើនសាច់ប្រាក់ជារួម (ពិន្ទុភាគរយ)




**ប្រភព៖** អាជ្ញាធរកម្ពុជា។

រូបភាព 16 ការប្រមូលផ្តុំឥណទាននៅក្នុងវិស័យអចលនទ្រព្យ

ការរួមចំណែកដល់កំណើនឥណទានក្នុងស្រុក (ពិន្ទុភាគរយ)




**ប្រភព៖** អាជ្ញាធរកម្ពុជា។

**សម្គាល់៖** CRM = សំណង់ អចលនទ្រព្យ និងកម្ចីទិញផ្ទះ។

8 ការកើនឡើងខ្លាំងនៃអត្រាការប្រាក់សកលអាចបង្កឱ្យមានក្តីបារម្ភសម្រាប់ក្រុមហ៊ុន និងបង្កបញ្ហាកាន់តែទូលំទូលាយសម្រាប់សេដ្ឋកិច្ចប្រទេសជាច្រើន។ https://www.imf.org/en/Blogs/Articles/2023/01/31/countries-should-act-now-to-limit-rising-risks-from-corporate-distress .

ទោះជាយ៉ាងណាក៏ដោយ កំណើនឥណទានបានចាប់ផ្តើមងើបឡើងវិញរហូតដល់ត្រីមាសទី 1 ឆ្នាំ 2022 នៅពេលដែលធនាគារកណ្តាលអាមេរិកបានចាប់ផ្តើមរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ខ្លួន ដើម្បីទប់ទល់នឹងការកើនឡើងអតិផរណានៅក្នុងសហរដ្ឋអាមេរិក។ [9]

**នៅឆ្នាំ 2023 ប្រហែលដោយសារការវិនិយោគបែបប្រថុយលើអចលនទ្រព្យ ឥណទានក្នុងស្រុកដែលកើនឡើង និងប្រមូលផ្តុំនៅក្នុងវិស័យសំណង់ និងអចលនទ្រព្យនៅតែបន្ត ទោះបីមានការកើនឡើងថ្លៃដើមនៃកម្ចី និងការធ្លាក់ចុះសកម្មភាពសំណង់បន្ទាប់ពីសំណង់ដែលរីកដុះដាលបានជាប់គាំងក្នុងអំឡុងពេលការរាតត្បាតនៃជំងឺ។** នៅក្នុងខែកុម្ភៈ ឆ្នាំ 2023 ការចូលរួមចំណែកសរុបនៃវិស័យសំណង់ អចលនទ្រព្យ និងកម្ចីទិញផ្ទះ ធៀបនឹងកំណើនឥណទានសរុបបានកើនឡើងដល់ 43 ភាគរយ កើនពី 37 ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022។ ការរួមចំណែកនៃវិស័យកសិកម្ម ការលក់ដុំ ការលក់រាយ និងវិស័យសណ្ឋាគារ និងភោជនីយដ្ឋានដល់កំណើនឥណទានបានបន្តថមថយដល់ 1.3 ពិន្ទុភាគរយ 1.3 ពិន្ទុភាគរយ 2.3 ពិន្ទុភាគរយ និង 0.6 ពិន្ទុភាគរយរៀងគ្នា ក្នុងអំឡុងពេលពីរខែដំបូងនៃ ឆ្នាំ 2023 ចុះពី 2.4 ពិន្ទុភាគរយ 2.1 ពិន្ទុភាគរយ 4.5 ពិន្ទុភាគរយ និង 0.8 ពិន្ទុភាគរយរៀងគ្នា ក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022 ។ មិនទាន់ច្បាស់ថាតើការប្រមូលផ្តុំឥណទានក្នុងវិស័យសំណង់ និងអចលនទ្រព្យនឹងមានរយៈពេលប៉ុន្មាន។

**ប្រាក់បញ្ញើរបស់វិស័យឯកជនបានធូរស្រាលខ្លាំង។** ដូចគ្នានេះដែរ កំណើនប្រាក់បញ្ញើរបស់វិស័យឯកជនបានធ្លាក់ចុះពាក់កណ្តាល មកនៅត្រឹម 7.5 ភាគរយ ឆ្នាំ/ឆ្នាំ ក្នុងខែកុម្ភៈ ឆ្នាំ 2023 ធ្លាក់ចុះពី 15.8 ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022។ ដូច្នេះ អនុបាតប្រាក់កម្ចីធៀបនឹងប្រាក់បញ្ញើបានកើនឡើងបន្ថែមទៀត ដោយឈានដល់ 141.5 ភាគរយនៅក្នុងខែកុម្ភៈ ឆ្នាំ 2023 កើនឡើងពី 132.5 ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022។ ការធូរស្រាលប្រាក់បញ្ញើក្នុងស្រុកអាចជំរុញធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឱ្យដំឡើងអត្រាការប្រាក់លើប្រាក់បញ្ញើ ដើម្បីទាក់ទាញអ្នកដាក់ប្រាក់បញ្ញើ។ អត្រាការប្រាក់ជាមធ្យមនៃប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិក និងប្រាក់រៀលបានកើនដល់ 5.54 ភាគរយ និង 6.7 ភាគរយក្នុងមួយឆ្នាំរៀងគ្នា កើនឡើងពី 3.94 ភាគរយ និង 5.54 ភាគរយរៀងគ្នាក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022។ នៅចុងឆ្នាំ 2022 អនុបាតប្រាក់កម្ចីមិនដំណើរការសរុបដែលបានរាយការណ៍នៅតែមានកម្រិតទាប នៅត្រឹម 3.2 ភាគរយ និង 2.6 ភាគរយសម្រាប់វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុរៀងគ្នា។[10] ប៉ុន្តែ វាប្រហែលជាមិនឆ្លុះបញ្ចាំងទាំងស្រុងពីការថយចុះគុណភាពទ្រព្យសកម្មនោះទេ ដោយសារតែការរៀបចំកម្ចីឡើងវិញដ៏ច្រើនត្រូវបានអនុញ្ញាតក្នុងអំឡុងពេលនៃវិបត្តិកូវីដ-19។ លើសពីនេះ បំណុលឯកជនមានកម្រិតខ្ពស់បង្កក្តីបារម្ភអំពីការការយឺតយ៉ាវនៃសេដ្ឋកិច្ច ប្រសិនបើអ្នកខ្ចីពិបាកសងបំណុល។

## សម្ពាធលើអត្រាការប្រាក់ក្នុងស្រុកបានបន្ត

**ការរឹតបន្តឹងខ្លាំងនៃលក្ខខណ្ឌហិរញ្ញវត្ថុសកលបានដាក់សម្ពាធកាន់តែខ្លាំងលើអត្រាការប្រាក់ក្នុងស្រុក។** អត្រាការប្រាក់របស់កម្ពុជាបានកើនឡើងយ៉ាងឆាប់រហ័ស បន្ទាប់ពីការដំឡើងអត្រាការប្រាក់របស់ធនាគារកណ្តាលអាមេរិក ដែលអត្រាមូលនិធិសហព័ន្ធកើនដល់ 4.75% ទៅ 5% កើនឡើងពី 0.25% ទៅ 0.5% ក្នុងកំឡុងខែមីនា ឆ្នាំ 2022-23។ កំណើនថ្លៃដើមសម្រាប់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជាបានបង្កើនចំណាយប្រតិបត្តិការរបស់ពួកគេ ដែលតម្រូវឱ្យពួកគេបង្កើនអត្រាការប្រាក់លើប្រាក់កម្ចី។ នៅក្នុងខែកុម្ភៈ ឆ្នាំ 2023 អត្រាការប្រាក់ជាមធ្យមនៃប្រាក់កម្ចីមានកាលកំណត់ជាប្រាក់ដុល្លារអាមេរិក និងប្រាក់រៀលបានកើនឡើងដល់ 10.19 ភាគរយ និង 12.61 ភាគរយក្នុងមួយឆ្នាំរៀងគ្នា កើនឡើងពី 9.51 ភាគរយ និង 11.54 ភាគរយរៀងគ្នាក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ 2022។ (រូបភាព 17) ។ ដោយសារភាពយឺតយ៉ាវក្នុងការផ្លាស់ប្តូរគោលនយោបាយរូបិយវត្ថុ លទ្ធផលពីសកម្មភាពនៃការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុបច្ចុប្បន្នមិនទាន់សម្រេចបានទាំងស្រុងនៅឡើយទេ។ ទៅអនាគតវដ្តនៃការរឹតបន្តឹងទំនងជានឹងប៉ះពាល់ដល់ការវិនិយោគ និងការចំណាយរបស់អ្នកប្រើប្រាស់។

រូបភាព 17 អត្រាការប្រាក់ក្នុងស្រុកបានបន្តកើនឡើង (ភាគរយក្នុងមួយឆ្នាំ)




**ប្រភព៖** អាជ្ញាធរកម្ពុជា។
**សម្គាល់៖** RHS = មាត្រដ្ឋានខាងស្តាំ។
MDI = គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។

9 Ferroni, Fisher, និង Melosi ឆ្នាំ 2023។
10 ធនាគារជាតិនៃកម្ពុជា ឆ្នាំ 2023 ។

## ប្រព័ន្ធធនាគារនៅតែមានភាពធន់

**យោងតាមធនាគារជាតិនៃកម្ពុជា ក្នុងឆ្នាំ 2022 អនុបាតភាពគ្រប់គ្រាន់នៃមូលធនប័ត្រមាន 22.5 ភាគរយ និង 21.2 ភាគរយ សម្រាប់វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុរៀងគ្នា លើសពីកម្រិតប្រុងប្រយ័ត្ន 15 ភាគរយ។** អនុបាតនៃការគ្របដណ្តប់សន្ទនីយភាពមាន 143 ភាគរយ និង 172.8 ភាគរយសម្រាប់វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុរៀងគ្នា បើធៀបនឹងកម្រិត 100 ភាគរយ (រូបភាព 18) ។[11] ចំនួនគណនីអតិថិជនដាក់ប្រាក់បញ្ញើបានកើនឡើងដល់ 14.3 លាន និងគណនីឥណទានកើនឡើងដល់ 3.7 លាន កើនពី 12.7 លាន និង 3.4 លានរៀងគ្នា។ ទ្រព្យសកម្មសរុបនៃវិស័យធនាគារ មីក្រូហិរញ្ញវត្ថុ និងភតិសន្យាហិរញ្ញវត្ថុមានចំនួន 85.2 ភាគរយ 14.2 ភាគរយ និង 0.6 ភាគរយនៃទ្រព្យសម្បត្តិប្រព័ន្ធធនាគារសរុបរៀងគ្នា។ ទោះបីបន្តកើនឡើង ទ្រព្យសកម្មសរុបនៃប្រព័ន្ធធនាគារបានថយចុះ មកនៅត្រឹម 14.5 ភាគរយក្នុងឆ្នាំ 2022 ធ្លាក់ចុះពី 16 ភាគរយក្នុងឆ្នាំ 2021 មកនៅត្រឹម 79.7 ពាន់លានដុល្លារអាមេរិក។

## ចំណូលក្នុងស្រុកបានងើបឡើងវិញពេញលេញ និងបន្តកើនឡើង

**ការប្រមូលចំណូលក្នុងស្រុកបានបន្តប្រសើរឡើងជារួមក្នុងនៅឆ្នាំ 2023 ។** បន្ទាប់ពីការងើបឡើងវិញពេញលេញនៅឆ្នាំ 2022 ប្រាក់ចំណូលក្នុងស្រុកបានបន្តកំណើន ដោយសារការកែលម្អបន្ថែមទៀតនៅក្នុងការគ្រប់គ្រងចំណូល។ ចំណូលក្នុងស្រុករបស់រដ្ឋាភិបាលកណ្តាលបានកើនឡើង 11.2 ភាគរយក្នុងខែមករា ឆ្នាំ 2023 (រូបភាព 19)។ ដោយឆ្លុះបញ្ចាំងពីការបន្តដំណើរការល្អនៃការប្រមូលពន្ធលើប្រាក់ចំណេញ ប្រាក់ចំណូលផ្ទាល់បានរួមចំណែកច្រើនបំផុត គឺ 7.9 ពិន្ទុភាគរយនៃកំណើន 11.2 ភាគរយ។ ការរួមចំណែកនៃចំណូលប្រយោល ចំណូលពាណិជ្ជកម្មអន្តរជាតិ និងចំណូលមិនមែនពន្ធគឺអវិជ្ជមាន 0.6 ពិន្ទុភាគរយ 1.1 ពិន្ទុភាគរយ និង 2.8 ភាគរយរៀងគ្នា។ ទោះជាយ៉ាងណាក៏ដោយ អត្រាកំណើនចំណូលក្នុងស្រុក 11.2 ភាគរយក្នុងខែមករា ឆ្នាំ 2023 នៅតែទាបជាងកំណើនចំណូល 20.6 ភាគរយនៅក្នុងខែមករា ឆ្នាំ 2019 ស្របជាមួយនឹងភាពខ្សោយនៃការពង្រីកសេដ្ឋកិច្ចក្រោយវិបត្តិកូវីដ-19 បើធៀបនឹងអំឡុងពេលមុនកូវីដ-19។

**រូបភាព 18** អនុបាតនៃការគ្របដណ្តប់សន្ទនីយភាពរបស់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ភាគរយ)




**ប្រភព៖** អាជ្ញាធរកម្ពុជា។
**សម្គាល់៖** MDI = គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។

**រូបភាព 19** ការរួមចំណែកដល់កំណើនប្រាក់ចំណូលក្នុងស្រុក (ពិន្ទុភាគរយ)




**ប្រភព៖** អាជ្ញាធរកម្ពុជា។

11 អនុបាតនៃការគ្របដណ្តប់សន្ទនីយភាពស្មើនឹងចំណែកនៃទ្រព្យសកម្មរាវថែកនឹងលំហូរចេញនៃសាច់ប្រាក់សុទ្ធក្នុងរយៈពេល 30 ថ្ងៃ។ សូមមើល https://www.nbc.gov.kh/download_files/legislation/prakas_eng/5759prakas-liquidity-coverage-ratio-english.pdf .

រូបភាព 20 ការចំណាយថវិកាបានថយចុះ នៅពេលដែលកិច្ចខិតខំប្រឹងប្រែងពង្រឹងលំហសារពើពន្ធ (ពិន្ទុភាគរយ)




**ប្រភព៖** អាជ្ញាធរកម្ពុជា។

**នៅឆ្នាំ 2022 ចំណូលក្នុងស្រុកបានកើនឡើងយ៉ាងឆាប់រហ័ស។** ចំណូលក្នុងស្រុកទូទៅរបស់រដ្ឋាភិបាល (មិនរាប់បញ្ចូលជំនួយ) ឈានដល់ 22.5 ភាគរយនៃ ផ.ស.ស. ដែលតំណាងឱ្យការកើនឡើង 21.9 ភាគរយ ឆ្នាំ/ឆ្នាំ ក្នុងឆ្នាំ 2022 ។ ចំណូលក្នុងស្រុកត្រូវបានប្រមូលជាចម្បងដោយភ្នាក់ងារប្រមូលចំណូលចំនួនពីរ គឺអគ្គនាយកដ្ឋានពន្ធដារ (47.0 ភាគរយនៃចំនួនសរុប) និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករ (44.7 ភាគរយនៃចំនួនសរុប)។ នៅឆ្នាំ 2022 ចំណូលផ្ទាល់ដែលភាគច្រើនជាពន្ធលើប្រាក់ចំណេញបានកើនឡើងយ៉ាងឆាប់រហ័សដល់ 6.1 ភាគរយនៃ ផ.ស.ស. ដែលលើសអាករលើតម្លៃបន្ថែមចំនួន 5.8 ភាគរយនៃ ផ.ស.ស. ជាលើកដំបូងក្នុងប្រវត្តិសាស្ត្រនៃការប្រមូលចំណូលក្នុងស្រុកនាពេលថ្មីៗនេះ។ កិច្ចខិតខំប្រឹងប្រែងដើម្បីកែលម្អការប្រមូលចំណូលបានបន្ត ដោយមានការគ្រប់គ្រងពន្ធដារកាន់តែប្រសើរ អភិបាលកិច្ចល្អ ទំនើបកម្ម និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធប្រកាសពន្ធអេឡិចត្រូនិក ការទូទាត់អេឡិចត្រូនិក និងសេវាកម្មអ្នកបង់ពន្ធ ទន្ទឹមនឹងនោះលុបបំបាត់ចន្លោះប្រហោងនៅក្នុងច្បាប់ស្តីពីពន្ធដារ និងធ្វើសុខដុមរមនីយកម្មក្របខ័ណ្ឌច្បាប់ដើម្បីបង្ការការគេចវេសផ្នែកពន្ធការរំលោភលើតម្លៃផ្ទេរ និងការយកពន្ធស្ទួន។ ការស្ទង់មតិអ្នកបង់ពន្ធបានបង្ហាញថា 88 ភាគរយនៃអ្នកឆ្លើយតបបានយល់ស្របថាទំនើបកម្ម រដ្ឋបាលសារពើពន្ធ ជាពិសេសការធ្វើស្វ័យប្រវត្តិកម្ម បានជួយកែលម្អការបង់ពន្ធ។[12]

## ទោះបីជាមានការខិតខំប្រឹងប្រែងក្នុងការពង្រឹងផ្នែកសារពើពន្ធក៏ដោយ ការចំណាយបានកើនឡើងតិចតួច

**សម្រាប់ផ្នែកចំណាយ ចំណាយសាធារណៈត្រូវបានរំពឹងថានឹងកើនឡើងបន្តិច បើទោះជាមានការខិតខំប្រឹងប្រែងពង្រឹងសារពើពន្ធក៏ដោយ។** ទោះបីទាំងចំណាយមូលធន និងចំណាយចរន្តត្រូវបានគ្រោងបង្កើននៅឆ្នាំនេះក៏ដោយ ចំណាយសាធារណៈកំពុងមានការផ្លាស់ប្តូរដើម្បីជួយដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់កម្ពុជា ខណៈដែលការចំណាយបណ្តោះអាសន្នដើម្បីជំរុញការផ្តល់ហិរញ្ញប្បទានដល់វិស័យសង្គម ជាពិសេសវិស័យសុខាភិបាលត្រូវបានដកចេញ ខណៈដែលចំណាយទាក់ទងនឹងជំងឺកូវីដ-19 ត្រូវបានបិទបញ្ចប់។ ក្នុងន័យនេះ ចំណាយមូលធនសម្រាប់វិស័យសង្គមត្រូវកំណត់ឱ្យធ្លាក់ចុះពី 0.91 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2022 មកត្រឹម 0.8 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2023 ។ ការធ្លាក់ចុះនេះឆ្លុះបញ្ចាំងយ៉ាងទូលំទូលាយពីការដកការជំរុញចំណាយសម្រាប់វិស័យសុខាភិបាល ដោយសារការឆ្លងជំងឺ កូវីដ-19 បានផុតរលុតស្ទើរតែទាំងស្រុង។ ចំណាយមូលធនដែលបានគ្រោងសម្រាប់ក្រសួងសុខាភិបាលបានធ្លាក់ចុះស្ទើរតែមួយភាគបួនដែលមានត្រឹមតែ 0.44 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2023 ធ្លាក់ចុះពី 0.62 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2022 ។[13] ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលបានពិភាក្សានៅក្នុងផ្នែកផ្តោតពិសេសនៃរបាយការណ៍នេះ កម្ពុជាបានពង្រីកការចំណាយសាធារណៈយ៉ាងច្រើននៅក្នុងវិស័យសង្គមក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ដោយបានគូសបញ្ជាក់ពីតម្រូវការបន្ទាន់ក្នុងការធានាការចំណាយប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធិផលក្នុងវិស័យទាំងនេះ ដើម្បីផ្តល់សេវាសាធារណៈ និងរួមចំណែកដល់ការបង្កើតមូលធនមនុស្ស។ ក្នុងទស្សវត្សរ៍ចុងក្រោយនេះ ការធ្វើឱ្យប្រសើរឡើងនៃលំហសារពើពន្ធដែលកើតចេញពីកំណើនយ៉ាងឆាប់រហ័សនៃចំណូលក្នុងស្រុក បានអនុញ្ញាតឱ្យរដ្ឋាភិបាលបង្កើនការចំណាយក្នុងវិស័យសុខាភិបាល និងអប់រំ។ លើសពីនេះ ការបង្កើនការវិភាជថវិការបស់កម្ពុជាត្រូវបានជំរុញមួយផ្នែកដោយការដំឡើងប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីរាជការទូទៅ។ ប្រាក់បៀវត្សរ៍ប្រចាំខែរបស់វិស័យសាធារណៈជាមធ្យមគឺខ្ពស់ជាងប្រាក់បៀវត្សរ៍របស់វិស័យឯកជន។ បច្ចុប្បន្ន កម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលមានអត្រានៃចំណូលរដ្ឋខ្ពស់បំផុតចំណាយលើប្រាក់បៀវត្សរ៍មន្ត្រីសាធារណៈ (សូមមើលអត្ថបទផ្តោតពិសេស)។

12 "ព្រឹត្តិបត្រពន្ធ - ត្រីមាសទីបួន ឆ្នាំ 2022"; https://www.tax.gov.kh/en/tax-bulletin
13 ថវិកាប្រចាំឆ្នាំ 2022 និង 2023 រាជរដ្ឋាភិបាលកម្ពុជា https://mef.gov.kh/documents-category/law-and-regulation/budget/

**ខណៈពេលដែលការវិនិយោគសាធារណៈក្នុងវិស័យសេដ្ឋកិច្ច ត្រូវបានកំណត់ថវិកាឱ្យនៅតែមិនផ្លាស់ប្តូរក្នុងអត្រា 4.1 ភាគរយ នៃ ផ.ស.ស. ក្នុងឆ្នាំ 2023 ក្រសួងសេដ្ឋកិច្ចមួយចំនួនបាន ទទួលការជំរុញការចំណាយដើមទុនយ៉ាងច្រើនដើម្បីគាំទ្រដល់ ការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់កម្ពុជា។** ចំណាយមូលធនដែល បានបែងចែកទៅឱ្យក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកើនឡើងដល់ 0.62 ភាគរយនៃ ផ.ស.ស. និង 0.29 ភាគរយនៃ ផ.ស.ស. រៀងគ្នា ក្នុងឆ្នាំ 2023 កើនឡើងពី 0.56 ភាគរយនៃ ផ.ស.ស. និង 0.16 ភាគរយនៃ ផ.ស.ស. រៀងគ្នា ក្នុងឆ្នាំ 2022 ។ បន្ទាប់ពីការបង្កើនល្បឿនក្នុង កំឡុងឆ្នាំ 2020-21 ដើម្បីឆ្លើយតបនឹងការកើនឡើងនៃតម្រូវការ ចំណាយទាក់ទងនឹងការរាតត្បាតនៃជំងឺ ល្បឿននៃការចំណាយ សាធារណៈបានថយចុះ។ នៅខែមករាឆ្នាំ 2023 ការចំណាយរបស់ រដ្ឋាភិបាលកណ្តាលមានកម្រិតមធ្យម ដោយបានធ្លាក់ចុះ 21.6 ភាគរយ មួយភាគធំដោយសារការធ្លាក់ចុះចំណាយមូលធន។ ក្នុង ចំណោមការធ្លាក់ចុះ 21.6 ភាគរយ ចំណាយមូលធនថយចុះ 26.0 ពិន្ទុភាគរយ ខណៈដែលចំណាយចរន្តបានរួមចំណែកដល់ កំណើនចំនួន 4.4 ពិន្ទុភាគរយ (រូបភាព 20) ។

## ការដំឡើងប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈ ទូទាំងប្រទេសបានចាប់ផ្តើមឡើងវិញ

**ការកើនឡើងនៃចំណាយថវិកាចរន្តឆ្លុះបញ្ចាំងពីការអនុវត្ត ឡើងវិញនូវការដំឡើងប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈជារួម។** ការដំឡើងប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈត្រូវបានផ្អាកក្នុង កំឡុងឆ្នាំ 2021-22 ដើម្បីសន្សំធនធានថវិកា សម្រាប់ផ្តល់ ហិរញ្ញប្បទានដល់កំណើនតម្រូវការចំណាយ ដើម្បីកាត់បន្ថយ ផលប៉ះពាល់នៃវិបត្តិកូវីដ-19។ លើសពីនេះ រដ្ឋាភិបាលបានបង្កើន អត្ថប្រយោជន៍សន្តិសុខសង្គមដល់អតីតមន្ត្រីរាជការ និងអតីត យុទ្ធជន។ ការដំឡើងប្រាក់បៀវត្សរ៍នេះត្រូវបានអនុវត្តសម្រាប់អតីត មន្ត្រីរាជការដែលទទួលបានប្រាក់បៀវត្សរ៍ទាបនៅពេលពួកគេធ្វើ ការជាមន្ត្រីរាជការ ជាងមន្ត្រីរាជការបច្ចុប្បន្ន។ ការកើនឡើងនៃ ការចំណាយចរន្តក៏ចាំបាច់ផងដែរ ដើម្បីផ្តល់ហិរញ្ញប្បទានដល់ ការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី 32 និងការចំណាយទាក់ទងនឹងការបោះឆ្នោតជាតិ។

**រដ្ឋាភិបាលបានបន្តផ្តល់ជំនួយសាច់ប្រាក់សម្រាប់គ្រួសារ ក្រីក្រ និងងាយរងគ្រោះ ទោះបីជាជំងឺស្ថានភាពដ៏អាក្រក់នៃជំងឺ កូវីដ-19ត្រូវបានបញ្ចប់ហើយក៏ដោយ។** ក្នុងន័យនេះ រដ្ឋាភិបាល កម្ពុជាបានបន្តកម្មវិធីជំនួយសាច់ប្រាក់ជំងឺកូវីដ-19 បន្ថែមទៀត ជាមួយនឹងថវិកាបន្ថែមប្រមាណ 400លានដុល្លារអាមេរិក។ កម្មវិធី នេះបានផ្តល់អត្ថប្រយោជន៍ដល់មនុស្សជិត 2.8 លាននាក់ (17 ភាគរយនៃចំនួនប្រជាជន) ឬ 705,000 គ្រួសារ។ ក្នុងនោះ 110,000 នាក់ជាកុមារអាយុក្រោមប្រាំឆ្នាំ 387,000 នាក់ជា មនុស្សចាស់មានអាយុលើសពី 60 ឆ្នាំ 60,000 នាក់ជាជនមាន ពិការភាព និង 2,000 នាក់ជាអ្នកមានផ្ទុកមេរោគអេដស៍/ជំងឺ អេដស៍។ គិតត្រឹមខែមីនា ឆ្នាំ 2023 កម្មវិធីនេះបានបញ្ចេញថវិកា ចំនួន 994 លានដុល្លារអាមេរិក គិតចាប់ពីពេលចាប់ផ្តើមកម្មវិធី ក្នុងខែមិថុនា ឆ្នាំ 2020។ លើសពីនេះ រដ្ឋាភិបាលបានដាក់ចេញ នូវកម្មវិធីជំនួយសាច់ប្រាក់ថ្មីសម្រាប់គ្រួសារដែលមានហានិភ័យ ដោយសារសម្ពាធអតិផរណា និងទឹកជំនន់ធ្ងន់ធ្ងរ។ នៅក្នុងជុំទី មួយនៃការអនុវត្ត កម្មវិធីជំនួយសាច់ប្រាក់សម្រាប់គ្រួសារដែលរង ផលប៉ះពាល់ពីអតិផរណាបានបញ្ចេញប្រាក់ចំនួន 9.12 លាន ដុល្លារអាមេរិក និងផ្តល់អត្ថប្រយោជន៍ដល់គ្រួសារចំនួន 261,000។ កម្មវិធីជំនួយសាច់ប្រាក់ដល់គ្រួសាររងគ្រោះដោយទឹកជំនន់ត្រូវបាន បញ្ចប់នៅខែមីនា ឆ្នាំ 2023 ដែលបានផ្តល់ប្រាក់ចំនួន 11.6 លាន ដុល្លារអាមេរិក និងផ្តល់អត្ថប្រយោជន៍ដល់ 99,000 គ្រួសារ។ អត្រា នៃភាពក្រីក្រធៀបនឹងខ្សែបន្ទាត់ភាពក្រីក្រជាតិគឺ 17.8 ភាគរយក្នុង ឆ្នាំ 2019/20 ។ ការវិភាគធ្វើត្រាប់ដែលមិនបានរាប់បញ្ចូលផល ប៉ះពាល់នៃវិបត្តិកូវីដ-19 ឬសម្រាប់ការឆ្លើយតបគោលនយោបាយ សារពើពន្ធដើម្បីគាំទ្រគ្រួសាររវាងឆ្នាំ 2020 និងឆ្នាំ 2022 បាន បង្ហាញថា អតិផរណាអាចធ្វើឱ្យភាពក្រីក្រកើនឡើង 4 ពិន្ទុ ភាគរយលើសពីអត្រានៃភាពក្រីក្រក្នុងឆ្នាំ 2019/20 ។



©Shutterstock/Yosanon Y

## ឱនភាពសារពើពន្ធកាលពីឆ្នាំមុនត្រូវបានប៉ាន់ប្រមាណថាបានរួមតូចមកត្រឹម 4.7 ភាគរយនៃ ផ.ស.ស.

**ដោយសារការពង្រីកយ៉ាងឆាប់រហ័សនៃប្រាក់ចំណូលក្នុងស្រុក និងការចំណាយរួម ឱនភាពសារពើពន្ធត្រូវបានប៉ាន់ប្រមាណថាបានរួមតូចមកត្រឹម 4.7 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2022 ។** (រូបភាព 21) ។ កាលពីឆ្នាំមុន ប្រាក់ចំណូល រួមទាំងជំនួយ មានភាពប្រសើរឡើងយ៉ាងឆាប់រហ័ស ហើយត្រូវបានគេប៉ាន់ប្រមាណថាបានឈានដល់ 23.2 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2022 ដែលត្រូវបានជំរុញភាគច្រើនដោយប្រាក់ចំណូលពន្ធកើនឡើង ដោយសារការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ច និងការបន្តការកែលម្អការគ្រប់គ្រងប្រាក់ចំណូល។ ការចំណាយត្រូវបានប៉ាន់ប្រមាណថាបានធ្លាក់ចុះមកនៅត្រឹម 27.9 ភាគរយនៃ ផ.ស.ស. ដោយសារការចំណាយលើទំនិញ និងសេវាកម្ម និងការចំណាយមូលធនមានកម្រិតមធ្យម ខណៈដែលការចំណាយទាក់ទងនឹងការរាតត្បាតនៃជំងឺ ដូចជាចំណាយវិស័យសុខាភិបាលដែលទាក់ទងនឹងជំងឺកូវីដ-19 ត្រូវបានលុបបំបាត់។ ឱនភាពសារពើពន្ធត្រូវបានទប់ទល់ភាគច្រើនដោយហិរញ្ញប្បទានពីមូលនិធិខាងក្រៅដែល មានប្រហែល 90 ភាគរយនៃគម្លាតហិរញ្ញប្បទាន។ នៅសល់ 10 ភាគរយទៀតត្រូវបានផ្តល់ហិរញ្ញប្បទានដោយការដកប្រាក់របស់រដ្ឋាភិបាល (ទុនបម្រុងសារពើពន្ធ) ដែលមានចំនួន 17.8 ភាគរយនៃ ផ.ស.ស. នៅខែធ្នូ ឆ្នាំ 2022 ធ្លាក់ចុះពី 23.6 ភាគរយនៅចុងឆ្នាំ 2020។

## បំណុលសាធារណៈបានកើនឡើងដល់ 33.7 ភាគរយនៃ ផ.ស.ស.ដែលក្នុងនោះ 99.8 ភាគរយ ជាបំណុលខាងក្រៅ

**អាជ្ញាធរបាននឹងកំពុងបំពេញគម្លាតដែលកាន់តែរីកធំនៃហិរញ្ញប្បទានដែលបង្កឡើងដោយការរាតត្បាតនៃជំងឺ ជាចម្បងដោយប្រើចំណូលពីការផ្តល់ប្រាក់កម្ចី បន្ថែមពីលើនោះដោយការដកប្រាក់បញ្ញើរបស់រដ្ឋាភិបាល (ទុនបម្រុងសារពើពន្ធ)។** សំខាន់ជាងនេះទៅទៀត អាជ្ញាធរបានបន្តអនុវត្តតាមគោលការណ៍ខ្ចី ដោយខ្ចីបំណុលខាងក្រៅតែតាមលក្ខខណ្ឌសម្បទានប៉ុណ្ណោះ រហូតដល់ឆ្នាំ 2022 នៅពេលដែលបំណុលក្នុងស្រុក (មូលបត្ររដ្ឋាភិបាល) ត្រូវបានបោះផ្សាយលក់ ដើម្បីជួយរក្សាហានិភ័យទាបនៃចំណាត់ថ្នាក់បំណុល។

**នៅចុងឆ្នាំ 2022 អនុបាតបំណុលសាធារណៈ និង ផ.ស.ស. របស់កម្ពុជាបានឈានដល់ 33.7 ភាគរយ ឬ 9.98 ពាន់លានដុល្លារអាមេរិកនៅក្នុងបំណុលដែលមិនទាន់ចេញ។** (តារាង 1),[14] ក្នុងនោះ 9,970.5 លានដុល្លារអាមេរិក (ឬ 99.8 ភាគរយ) ជាបំណុលសាធារណៈខាងក្រៅ និង 17.5 លានដុល្លារអាមេរិក (ឬ 0.2 ភាគរយ) ជាបំណុលសាធារណៈក្នុងស្រុក។ ក្នុងចំណោមបំណុលសាធារណៈចំនួន 9,970.5 លានដុល្លារអាមេរិក បំណុលទ្វេភាគី និងបំណុលពហុភាគីមានចំនួន 67.6 ភាគរយ និង 32.4 ភាគរយរៀងគ្នា។ បង្កឡើងដោយការរាតត្បាតនៃជំងឺសាកលនៅពេលដែលការប្រមូលចំណូលជាតិបានថយចុះ ហើយតម្រូវការ

រូបភាព 21 ឱនភាពរដ្ឋាភិបាលទូទៅ (ភាគរយនៃ ផ.ស.ស.)




**ប្រភព៖** ច្បាប់ទូទាត់ថវិកា និងការប៉ាន់ស្មាន និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក។
**សម្គាល់៖** ប = ការប៉ាន់ស្មាន ព = ការព្យាករណ៍។

រូបភាព 22 អតិរេក/ឱនភាព និងហិរញ្ញប្បទានរបស់រដ្ឋាភិបាលទូទៅ (ភាគរយនៃ ផ.ស.ស)
(ពិន្ទុភាគរយ)




**ប្រភព៖** ច្បាប់ទូទាត់ថវិកា និងការប៉ាន់ស្មាន និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក។
**សម្គាល់៖** ប = ការប៉ាន់ស្មាន ព = ការព្យាករណ៍។

14 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ 2023a ។

តារាង 1 បំណុលសាធារណៈ ប្រាក់កម្ចីដែលបានចុះហត្ថលេខាខ្ចីថ្មីៗ និងការចំណាយប្រាក់កម្ចី

| | បំណុលគិតត្រឹមឆ្នាំ 2022 | | ប្រាក់កម្ចីឆ្នាំ 2022 | | ការបើកប្រាក់ឆ្នាំ 2022 | |
|---|---|---|---|---|---|---|
| | ចំនួន (លានដុល្លារអាមេរិក) | ចំណែក (%) | ចំនួន (លានដុល្លារអាមេរិក) | ចំណែក (%) | ចំនួន (លានដុល្លារអាមេរិក) | ចំណែក (%) |
| ម្ចាស់បំណុលទ្វេភាគីធំបំផុតទាំង 3 | | | | | | |
| ចិន | 4,001.7 | 40.1 | 567.3 | 26.5 | 301.1 | 22.4 |
| ជប៉ុន | 1,077.7 | 10.8 | 448.0 | 21.0 | 386.2 | 28.7 |
| សាធារណៈរដ្ឋកូរ៉េ | 482.3 | 4.8 | 351.1 | 16.4 | 60.4 | 4.5 |
| ម្ចាស់បំណុលពហុភាគីធំបំផុតទាំង 3 | | | | | | |
| ធនាគារអភិវឌ្ឍអាស៊ី | 2,051.2 | 20.6 | 373.0 | 17.4 | 238.3 | 17.7 |
| ធនាគារពិភពលោក | 933.6 | 9.4 | 262.0 | 12.3 | 268.9 | 20.0 |
| IFAD | 129.7 | 1.3 | 0.0 | 0.0 | 29.8 | 2.2 |
| ម្ចាស់បំណុលទ្វេភាគី/ពហុភាគីផ្សេងទៀត | 1,294.4 | 13.0 | 136.5 | 6.4 | 60.3 | 4.5 |
| សរុប | 9,970.5 | 100.0 | 2,137.8 | 100.0 | 1,345.0 | 100.0 |

**ប្រភព៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ 2023a ។

ចំណាយវិស័យសុខាភិបាល និងជំនួយសង្គមកើនឡើង បំណុលកម្ពុជាបានកើនឡើងដល់ 33.7 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2022 កើនឡើងពី 28.1 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2019 ។ ការខ្ចីប្រាក់ពីខាងក្រៅនៅតែមានលក្ខណៈសម្បទានខ្ពស់ ជាមួយនឹងជំនួយឥតសំណងចំនួន 44.8 ភាគរយក្នុងឆ្នាំ 2022។ អត្រាការប្រាក់ជាមធ្យមនៃប្រាក់កម្ចីដែលបានចុះកិច្ចសន្យាគឺ 1.09 ភាគរយក្នុងមួយឆ្នាំ ខណៈរយៈពេលសងជាមធ្យមគឺ 26.7 ឆ្នាំ។ ក្នុងចំណោមប្រាក់កម្ចីសរុបដែលបានចុះកិច្ចសន្យាក្នុងឆ្នាំ 2022 ប្រាក់កម្ចី 69.0 ភាគរយបានផ្តល់ហិរញ្ញប្បទានដល់វិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈរបស់ប្រទេសដូចជាការដឹកជញ្ជូន ប្រព័ន្ធធារាសាស្ត្រ ថាមពល និងការផ្គត់ផ្គង់ទឹក ហើយចំណែកនៅសល់ 31.0 ភាគរយបានផ្តល់មូលនិធិដល់អាទិភាពផ្សេងទៀត (មិនមែនហេដ្ឋារចនាសម្ព័ន្ធ) ដូចជាវិស័យសុខាភិបាល អប់រំ និងកសិកម្ម។

**ការវិភាគរួមគ្នាលើនិរន្តរភាពបំណុលរបស់ធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលបានធ្វើឡើងក្នុងឆ្នាំ 2022 បានបង្ហាញថា ប្រទេសកម្ពុជានៅតែមានហានិភ័យទាបនៃវិបត្តិបំណុលខាងក្រៅ និងជារួម ក្រោមក្របខណ្ឌនិរន្តរភាពបំណុលប្រទេសដែលមានចំណូលទាប។**[15] បំណុលសាធារណៈសរុប និងអនុបាតបំណុលធានាដោយសាធារណៈធៀបនឹង ផ.ស.ស ត្រូវបានព្យាករណ៍ថានឹងកើនឡើងប្រហែល 4 ពិន្ទុភាគរយក្នុងកំឡុងទសវត្សរ៍បន្ទាប់នេះ។ តម្លៃបច្ចុប្បន្ននៃអនុបាតបំណុលខាងក្រៅធៀបទៅនឹង ផ.ស.ស. បំពានលើកម្រិតកំណត់នៅក្នុងការធ្វើតេស្តភាពតានតឹងការនាំចេញ ដែលបង្ហាញពីការវាយតម្លៃហានិភ័យកម្រិតមធ្យម។ ទោះជាយ៉ាងណាក៏ដោយ ការបំពាននេះមានកម្រិតទាប មានរយៈពេលខ្លី និងជំរុញដោយការប្រែប្រួលពិសេសនៃការនាំចេញនៅឆ្នាំ 2020 ដែលបានបង្កើនភាពប្រែប្រួលគំរូសម្រាប់វិបត្តិស្តង់ដារ។ ជាងនេះទៅទៀត សូចនាករបន្ទុកបំណុលផ្សេងទៀតត្រូវបានព្យាករថានឹងនៅតែស្ថិតក្រោមកម្រិតកំណត់របស់វាក្រោមបន្ទាត់មូលដ្ឋាន និងសេណារីយ៉ូវិបត្តិ។

**ម្ចាស់បំណុលផ្លូវការធំជាងគេរបស់កម្ពុជា គឺប្រទេសចិន។** បំណុលសរុបដែលជំពាក់ចិនបានកើនឡើងដល់ 4.0 ពាន់លានដុល្លារអាមេរិក ឬ 40.1 ភាគរយនៃបំណុលខាងក្រៅសរុប គិតត្រឹមចុងឆ្នាំ 2022។ ម្ចាស់បំណុលធំទីពីររបស់កម្ពុជាគឺធនាគារអភិវឌ្ឍន៍អាស៊ី ដែលកម្ពុជាជំពាក់ប្រាក់ចំនួន 2.05 ពាន់លានដុល្លារអាមេរិក ឬ 20.5 ភាគរយនៃបំណុលខាងក្រៅសរុប។ ម្ចាស់បំណុលធំជាងគេទីបី ទីបួន និងទីប្រាំរបស់កម្ពុជា គឺប្រទេសជប៉ុន ធនាគារពិភពលោក និងកូរ៉េ ដែលមានចំនួន 10.8 ភាគរយ 9.3 ភាគរយ និង 4.8 ភាគរយនៃបំណុលខាងក្រៅសរុបរៀងគ្នា។ បំណុលចាស់មានចំនួន 6.3 ភាគរយនៃបំណុលខាងក្រៅសរុប។ បំណុលសាធារណៈភាគច្រើនជាប្រាក់ដុល្លារអាមេរិកដែលមានចំនួន 44.2 ភាគរយនៃបំណុលសរុប តាមពីក្រោយដោយ SDRs (Special Drawing Rights) ប្រាក់យន់ចិន ប្រាក់យ៉េនជប៉ុន និងបំណុលដែលតំណាងដោយប្រាក់អឺរ៉ូដែលមានចំនួន 21.2 ភាគរយ 12.3 ភាគរយ 10.8 ភាគរយ និង 6.8 ភាគរយរៀងគ្នា។

15 មូលនិធិរូបិយវត្ថុអន្តរជាតិ 2022a.

# ទស្សនវិស័យ

**កំណើន ផ.ស.ស.ពិតរបស់កម្ពុជាសម្រាប់ឆ្នាំ 2023 ត្រូវបានព្យាករណ៍ថានឹងកើនឡើងបន្ថែមទៀត ដល់ 5.5 ភាគរយ (សូមមើលតារាង 2)។** ខណៈដែលការនាំចេញទំនិញមានស្ថានភាពធូរស្រាល ឱនភាពគណនីចរន្តត្រូវបានរំពឹងថានឹងប្រសើរឡើងដល់ 19.3 ភាគរយនៃ ផ.ស.ស. បន្ទាប់ពីការងើបឡើងវិញនៃការនាំចេញសេវាកម្ម ជាពិសេសការទទួលបានភ្ញៀវទេសចរណ៍ និងការផ្ទេរប្រាក់ផ្ញើចូលពីបរទេស។ ទោះបីជាមានការធ្លាក់ចុះថ្មីៗនៃគម្រោងវិនិយោគផ្ទាល់ពីបរទេសដែលត្រូវបានអនុម័តក៏ដោយ លំហូរចូលមូលធនដ៏រឹងមាំ និងការផ្តល់ហិរញ្ញប្បទានសម្បទាននឹងបន្តគ្របដណ្តប់យ៉ាងទូលំទូលាយនូវតម្រូវការហិរញ្ញប្បទានពីខាងក្រៅ។

**ឱនភាពសារពើពន្ធត្រូវបានរំពឹងថានឹងកើនឡើងដល់ 6.4 ភាគរយនៃ ផ.ស.ស ។** ប្រាក់ចំណូល រួមទាំងជំនួយកំពុងមានភាពប្រសើរឡើង ហើយត្រូវបានគេព្យាករណ៍ថានឹងនៅតែរឹងមាំដោយឈានដល់ 23.5 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2023។ ការចំណាយត្រូវបានគេរំពឹងថានឹងកើនឡើងដល់ 29.9 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2023 ដោយសារការកើនឡើងនៃការចំណាយប្រតិបត្តិការក្រោយការរាតត្បាតនៃជំងឺ ដែលរួមមានការដំឡើងប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈទូទាំងក្រុមប្រឹក្សា និងការកើនឡើងនៃការចំណាយលើទំនិញ និងសេវាកម្ម ព្រមទាំងការចំណាយទាក់ទងនឹងការបោះឆ្នោតទូទៅ និងធ្វើជាម្ចាស់ផ្ទះកីឡាអាស៊ីអាគ្នេយ៍ និងអាស៊ានប៉ារ៉ាហ្គេម។

**ក្នុងរយៈពេលមធ្យម សេដ្ឋកិច្ចត្រូវបានរំពឹងថានឹងមានទំនោរត្រឡប់ទៅរកសក្តានុពលឡើងវិញ ដោយកើនឡើងក្នុងអត្រា 6 ភាគរយ។** ការនាំចេញទំនិញ និងសេវាកម្ម និងលំហូរនៃការវិនិយោគផ្ទាល់ពីបរទេស ត្រូវបានរំពឹងថានឹងជំរុញដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលទើបបានផ្តល់សច្ចាប័នថ្មីៗ កំណើនដ៏ខ្លាំងនៃការវិនិយោគឯកជន និងសាធារណៈលើវិស័យហេដ្ឋារចនាសម្ព័ន្ធបន្តសំខាន់ៗ ដូចជាកំពង់ផែសមុទ្រ និងផ្លូវថ្នល់ ជាពិសេសក្រោមភាពជាដៃគូសាធារណៈ និងឯកជន និងកំណែទម្រង់រចនាសម្ព័ន្ធ។ ភាពក្រីក្រត្រូវបានរំពឹងថានឹងធ្លាក់ចុះ ដោយសារការងើបឡើងវិញនៃសេដ្ឋកិច្ច និងអតិផរណាកម្រិតមធ្យមដែលបានព្យាករណ៍។

តារាង 2 ទស្សនវិស័យម៉ាក្រូបង្ហាញពីការបន្តងើបឡើងវិញនៃសេដ្ឋកិច្ច

| | 2021 | 2022ប | 2023ព | 2024ព | 2025ព |
|---|---|---|---|---|---|
| គណនីជាតិ និងតម្លៃ | | | | | |
| ផ.ស.ស សរុបតាមតម្លៃទីផ្សារថេរ (% ផ្លាស់ប្តូរ) | 3.0 | 5.2 | 5.5 | 6.1 | 6.3 |
| កសិកម្ម | 1.2 | 0.7 | 1.5 | 1.5 | 1.5 |
| ឧស្សាហកម្ម | 9.4 | 8.3 | 4.0 | 8.0 | 9.6 |
| សេវាកម្ម | -2.7 | 2.2 | 10.6 | 7.4 | 5.9 |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ | 2.8 | 5.5 | 2.5 | 2.5 | 2.0 |
| រដ្ឋាភិបាលទូទៅ (% នៃ ផ.ស.ស) | | | | | |
| ប្រាក់ចំណូល និងជំនួយ | 22.0 | 23.2 | 23.5 | 24.0 | 25.0 |
| ការចំណាយ និងប្រាក់កម្ចីសុទ្ធ | 29.0 | 27.9 | 29.9 | 29.0 | 29.2 |
| សមតុល្យសរុប (រួមទាំងជំនួយ) | -7.0 | -4.7 | -6.4 | -4.9 | -4.2 |
| ហិរញ្ញប្បទានពីបរទេស | 4.2 | 5.6 | 4.5 | 4.3 | 3.9 |
| ហិរញ្ញប្បទានក្នុងស្រុកសុទ្ធ (ពីប្រាក់សន្សំបច្ចុប្បន្ន) | 3.8 | 0.4 | 3.3 | 2.0 | 1.7 |
| ការរំលោះ | -1.1 | -1.2 | -1.3 | -1.4 | -1.4 |
| សាច់ប្រាក់ និងឥណទាន | | | | | |
| សាច់ប្រាក់ទូទៅ (ការផ្លាស់ប្តូរ %) | 20.0 | 8.2 | 7.2 | 9.0 | 15.6 |
| ឥណទានដល់វិស័យឯកជន (ការផ្លាស់ប្តូរ %) | 23.2 | 18.9 | 12.5 | 15.0 | 18.1 |
| វិស័យខាងក្រៅ (លានដុល្លារអាមេរិក ឬដូចបញ្ជាក់) | | | | | |
| ការនាំចេញ (ទំនិញ និងសេវាកម្ម) | 18,565.9 | 24,494.7 | 29,149.5 | 35,679.0 | 45,186.1 |
| ការនាំចូល (ទំនិញ និងសេវាកម្ម) | 28,120.6 | 38,761.9 | 42,333.4 | 49,528.1 | 57,945.5 |
| ការវិនិយោគផ្ទាល់ពីបរទេស, លំហូរចូលសុទ្ធ | 3,483.5 | 3,578.8 | 4,380.6 | 4,745.7 | 5,167.2 |
| ទុនបម្រុងផ្លូវការសរុប | 20,272.3 | 17,784.6 | 15,828.3 | 16,145.4 | 18,085.3 |
| (ចំនួនខែនាំចូល) | 8.1 | 7.0 | 6.0 | 5.5 | 5.0 |
| គណនីចរន្ត (ភាគរយនៃ ផ.ស.ស) | -42.6 | -26.3 | -19.3 | -16.1 | -13.2 |
| អត្រាប្តូរប្រាក់ (ប្រាក់រៀលក្នុងមួយដុល្លារអាមេរិកជាមធ្យម) | 4,100.0 | 4,150.0 | 4,110.0 | 4,100.0 | 4,090.0 |
| បំណុលសារធារណៈ និងសេវាកម្ម | | | | | |
| បំណុលសាធារណៈសរុប (% នៃ ផ.ស.ស) | 35.2 | 33.7 | 35.1 | 35.6 | 35.9 |
| ធាតុអនុស្សរណៈ៖ | | | | | |
| ផ.ស.ស ចារឹក លានដុល្លារអាមេរិក | 26,952.7 | 29,647.4 | 32,425.5 | 35,383.9 | 38,565.0 |

**ប្រភព៖** អាជ្ញាធរកម្ពុជា និងប៉ាន់ស្មាន និងការព្យាករណ៍របស់បុគ្គលិកធនាគារពិភពលោក។
**សម្គាល់៖** ប = ការប៉ាន់ស្មាន ព = ការព្យាករណ៍។

# បញ្ហាប្រឈម និងហានិភ័យ

**ទោះជាយ៉ាងណាក៏ដោយ ទស្សនវិស័យនេះប្រឈមនឹងហានិភ័យនៃការធ្លាក់ចុះ។** ការបន្តភាពយឺតយ៉ាវនៃតម្រូវការខាងក្រៅត្រូវបានរំពឹងថានឹងធ្វើឱ្យការផលិតសម្រាប់នាំចេញរបស់កម្ពុជាចុះខ្សោយបន្ថែមទៀត ដែលការផលិតនេះបង្កើតការងារប្រហែល 40 ភាគរយនៃការងារសរុបនៅក្នុងវិស័យឧស្សាហកម្ម (17.3 ភាគរយនៃការងារមិនមែនកសិកម្មសរុប)។ ការបន្តរឹតបន្តឹងហិរញ្ញវត្ថុសកលអាចជះឥទ្ធិពលដល់វិស័យហិរញ្ញវត្ថុដែលជាប្រភពឥណទានសំខាន់នៃការរីកចំរើនក្នុងវិស័យសំណង់នាពេលថ្មីៗនេះ។ ការប្រែប្រួលតម្លៃប្រេងអាចបង្កឲ្យមានអតិផរណា និងប៉ះពាល់ដល់ការប្រើប្រាស់ក្នុងស្រុក។ នៅក្នុងប្រទេស ការប្រមូលផ្តុំឥណទាននៅក្នុងវិស័យសំណង់នៅតែជាហានិភ័យដ៏សំខាន់ចំពោះស្ថិរភាពហិរញ្ញវត្ថុ។

**ផ្ទុយទៅវិញ កំណើនសកលដែលមានសន្ទុះខ្លាំងជាងការរំពឹងទុក អាចបន្ធូរបន្ថយផលជះនៃការធ្លាក់ចុះតម្រូវការខាងក្រៅ។** ការស្ទុះងើបឡើងវិញប្រសើរជាងការការរំពឹងទុកនៅក្នុងប្រទេសចិនអាចជំរុញការមកដល់នៃភ្ញៀវទេសចរណ៍ ការនាំចេញ និងលំហូរនៃការវិនិយោគផ្ទាល់ពីបរទេសកាន់តែខ្លាំង ដែលអាចជួយទប់ទល់ការធ្លាក់ចុះដែលរំពឹងទុកនៅក្នុងប្រទេសអភិវឌ្ឍន៍ ក្នុងកម្រិតធំជាងការសន្មត់ពីពេលមុន។ លើសពីនេះ កំណើនសេដ្ឋកិច្ចប្រទេសជឿនលឿន ទោះបីទំនងជាយឺតជាងឆ្នាំមុន ក៏អាចនឹងប្រែជាខ្លាំងជាងការរំពឹងទុក ដែលរារាំងដល់ការធ្លាក់ចុះការនាំចេញដែលបានព្យាករណ៍។

# ជម្រើសគោលនយោបាយ

**គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចគួរបន្តគាំទ្រដល់កំណើន និងការងារ ទន្ទឹមនឹងនោះរក្សាបាននូវស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ។** កត្តានេះបានក្លាយជាបញ្ហាប្រឈមកាន់តែខ្លាំងនៅក្នុងបរិបទនៃការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុ និងការកើនឡើងកម្រិតបំណុលឯកជន។ ប៉ុន្តែអតិផរណាបានធ្លាក់ចុះយ៉ាងឆាប់រហ័សដល់កម្រិតមុនការរាតត្បាតនៃជំងឺ ដែលអនុញ្ញាតឱ្យរដ្ឋាភិបាលបន្តគោលនយោបាយរូបិយវត្ថុបែបសម្របសម្រួលដោយរក្សា ឬបន្ថយអនុបាតតម្រូវការទុនបម្រុង។ ទោះបីការពង្រឹងផ្នែកសារពើពន្ធមានភាពចាំបាច់ក្នុងរយៈពេលមធ្យម វាអាចដំណើរការទៅបន្តិចម្តងៗ ដែលផ្តល់លទ្ធភាពក្នុងការគ្រប់គ្រងកម្រិតបំណុលសាធារណៈ។ ប្រទេសកម្ពុជាមានលំហសារពើពន្ធដើម្បីរក្សា ឬបង្កើនកំណើន ដោយបង្កើនការចំណាយលើហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងការអភិវឌ្ឍធនធានមនុស្ស ដែលនឹងជំរុញសមត្ថភាពផលិតភាពនៃសេដ្ឋកិច្ចក្នុងរយៈពេលវែង។ ការបន្តផ្តល់ជំនួយសង្គមដល់ជនក្រីក្រ ទន្ទឹមនឹងនោះទប់ស្កាត់ការបាត់បង់ការសិក្សាដែលកម្ពុជាបានជួបប្រទះក្នុងអំឡុងពេលនៃវិបត្តិកូវីដ-19 និងការកសាងឡើងវិញឱ្យកាន់តែប្រសើរឡើង ក៏ជាការចាំបាច់ផងដែរ ដើម្បីលើកកម្ពស់កំណើនប្រកបដោយបរិយាប័ន្ន។ កំណើននៃវិនិយោគសាធារណៈរួមផ្សំនឹងជំហានក្នុងការបង្កើនប្រសិទ្ធិភាពចំណាយនឹងធានាបានថា ការចំណាយខ្ពស់នឹងប្រែក្លាយទៅជាលទ្ធផលកាន់តែប្រសើរ ដូចដែលបរិយាយលម្អិតនៅក្នុងផ្នែកទី 2 នៃរបាយការណ៍នេះ។

**ការការពារស្ថិរភាពហិរញ្ញវត្ថុនៅតែជាអាទិភាពសំខាន់។** កំណើនឥណទានយ៉ាងឆាប់រហ័សនាពេលថ្មីៗនេះ និងបំណុលខ្ពស់ក្នុងវិស័យឯកជន ដែលប្រមូលផ្តុំនៅក្នុងវិស័យអចលនទ្រព្យបង្កហានិភ័យសំខាន់ៗដល់ស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុរបស់កម្ពុជា។ ចំបាច់ត្រូវការការត្រួតពិនិត្យកាន់តែខ្លាំង ទន្ទឹមនឹងការអនុវត្តវិធានការទាក់ទងនឹងការរាតត្បាតនៃជំងឺ ដូចជាការរៀបចំប្រាក់កម្ចីឡើងវិញ និងការអត់ធ្មត់ពុំទារបំណុលត្រូវបានបញ្ចប់។ វាអាចរួមបញ្ចូលការពង្រឹងការផ្តោតទៅលើការធ្វើតេស្តភាពតានតឹង (stress test) នៃស្ថាប័ននីមួយៗ ការត្រួតពិនិត្យជាប្រព័ន្ធនៅនឹងកន្លែង ការសម្រួលបន្ថែមទៀតនូវក្របខណ្ឌបទប្បញ្ញត្តិជាមួយនឹងស្តង់ដារអន្តរជាតិ និងការវាយតម្លៃបន្ថែមលើគុណភាពនៃផលប័ត្រប្រាក់កម្ចី ក្នុងចំណោមកត្តាផ្សេងៗទៀត។ ទន្ទឹមនឹងនោះ រដ្ឋាភិបាលគួរបន្តកិច្ចខិតខំប្រឹងប្រែង រៀបចំច្បាប់ស្តីពីការធានារ៉ាប់រងប្រាក់បញ្ញើ និងដំណោះស្រាយធនាគារ។ ដើម្បីត្រៀមសម្រាប់កំណើនកម្រិតនៃប្រាក់កម្ចីមិនដំណើរការ (NPLs) អាជ្ញាធរគួរតែធានាថាមានជម្រើសនៃដំណោះស្រាយជាស្រេចដើម្បីដាក់ឱ្យអនុវត្តនៅពេលចាំបាច់។ ស្រដៀងគ្នានេះដែរ គោលនយោបាយរបបក្ស័យធនរបស់ប្រទេសអាចត្រូវបានកែលម្អ។ ដោយសារការព្រួយបារម្ភជុំវិញសកម្មភាពធនាគារស្រមោល ដូចជាឥណទានដែលចេញដោយក្រុមហ៊ុនសាងសង់ ឬអ្នកអភិវឌ្ឍន៍អចលនទ្រព្យដល់អ្នកទិញសំណង់លំនៅដ្ឋាន វាជារឿងចាំបាច់ខ្លាំងណាស់ក្នុងការប្រមូលទិន្នន័យសំខាន់ៗដើម្បីត្រួតពិនិត្យ និងវាយតម្លៃភាពស្របច្បាប់នៃសកម្មភាពទាំងនោះ។

**ដើម្បីបង្កើនភាពធន់ និងភាពប្រកួតប្រជែងរយៈពេលវែងនៃសេដ្ឋកិច្ច កិច្ចខិតខំប្រឹងប្រែងត្រូវចាំបាច់លើកកម្ពស់បន្ថែមទៀតនូវការធ្វើពិពិធកម្មផលិតផលនាំចេញ។** មិនដូចប្រទេសដទៃទៀតក្នុងតំបន់ទេ កម្ពុជាបានទទួលជោគជ័យតិចតួចក្នុងការធ្វើពិពិធកម្មផលិតផលនាំចេញក្រៅពីសម្លៀកបំពាក់ ស្បែកជើង ខណៈដែលសមត្ថភាពកែច្នៃកសិផលរបស់ខ្លួននៅមានកម្រិតនៅឡើយ។ ដើម្បីឈានទីទៅដំណាក់កាលបន្ទាប់នៃការចូលរួមក្នុងខ្សែសង្វាក់តម្លៃសកល បណ្តុំគោលនយោបាយត្រូវមានការវិវត្តផ្លាស់ប្តូរ។ ទីមួយ គួរតែយកចិត្តទុកដាក់លើការអនុវត្តកិច្ចសន្យា ការការពារកម្មសិទ្ធិបញ្ញា និងការពង្រឹងការបញ្ជាក់គុណភាពផលិតផលថ្នាក់ជាតិ និងសមត្ថភាពធ្វើតេស្ត ដើម្បីធានាបាននូវការអនុលោមតាមស្តង់ដារអន្តរជាតិ។ ទីពីរ ការបន្ថយរបាំងពាណិជ្ជកម្ម និងកែលម្អការតភ្ជាប់ទៅកាន់ទីផ្សារនឹងពង្រីកទំហំនៃទីផ្សារផលិតផលរបស់ប្រទេសកម្ពុជា និងធ្វើអោយប្រសើរឡើងនូវលទ្ធភាពទទួលបានធាតុចូលដែលចាំបាច់សម្រាប់ផលិតកម្ម។ ទីបី បន្តពង្រឹងការអប់រំ និងជំនាញនៃកម្លាំងពលកម្មរបស់កម្ពុជា ដោយការវិនិយោគលើធនធានមនុស្ស។ ទីបួន ប្រើប្រាស់សេដ្ឋកិច្ចឌីជីថល ដើម្បីគាំទ្រក្រុមហ៊ុននានាក្នុងការធ្វើសមាហរណកម្មទៅក្នុងខ្សែសង្វាក់សកល តាមរយៈវេទិកាឌីជីថលក៏ដូចជាតាមរយៈការភ្ជាប់អ្នកចូលរួមខ្សែសង្វាក់តម្លៃ។



@ធនាគារពិភពលោក

# ជំពូក 2
# អត្ថបទផ្តោតពិសេស

## ពីការចំណាយកាន់តែច្រើន ទៅការចំណាយកាន់តែប្រសើរ – ឆ្ពោះទៅការបង្កើនគុណភាពអភិវឌ្ឍន៍មនុស្ស[16]

### សេចក្តីផ្តើម

**អត្ថបទផ្តោតពិសេសនៃបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជានេះពិនិត្យលើការចំណាយសាធារណៈ និងលទ្ធផលក្នុងវិស័យសុខាភិបាល និងអប់រំ។** កិច្ចការនេះផ្អែកលើលំហាត់រួមគ្នានាពេលថ្មីៗនេះរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា និងធនាគារពិភពលោក លើការសិក្សាប្រសិទ្ធភាពនៃការគ្រប់គ្រងថវិកា (ការត្រួតពិនិត្យការចំណាយសាធារណៈ) ។

**ក្នុងមួយទសវត្សរ៍កន្លងទៅនេះ កម្ពុជាបានរក្សាគោលនយោបាយសារពើពន្ធប្រកបដោយភាពប្រុងប្រយ័ត្ន។** ឱនភាពសារពើពន្ធត្រូវបានទប់ស្កាត់ ជាពិសេសមុនការរាតត្បាតនៃជំងឺនៃជំងឺកូវីដ-19។ បំណុលសាធារណៈនៅតែមានកម្រិតទាប។ ការប្រមូលចំណូល មានភាពប្រសើរឡើងជាលំដាប់ បង្កើតជាលំហសារពើពន្ធដ៏សំខាន់ដើម្បីអនុញ្ញាតឱ្យមានកំណើនគួរឱ្យកត់សម្គាល់នៃការចំណាយសាធារណៈ (រូបភាព S.1) ជាពិសេសនៅក្នុងវិស័យសង្គម។ ការចំណាយក្នុងវិស័យសង្គមបានកើនឡើងយ៉ាងខ្លាំងពី 4.6 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2011 ដល់ 10.5 ភាគរយនៅឆ្នាំ 2021 ខណៈដែលការចំណាយក្នុងវិស័យផ្សេងទៀតមានស្ថិរភាព។ ការពង្រីកការចំណាយសាធារណៈដ៏ធំលើវិស័យសង្គមសំខាន់ៗនេះផ្តោតទៅលើកិច្ចខិតខំប្រឹងប្រែងស្របគ្នា ដើម្បីបង្កើនគុណភាពនៃសេវាសាធារណៈ និងធានាថាការចំណាយខ្ពស់អាចនាំមកនូវលទ្ធផលអភិវឌ្ឍន៍មនុស្សកាន់តែប្រសើរ។ សំខាន់ជាងនេះទៅទៀត វាគូសបញ្ជាក់ពីសារៈសំខាន់នៃការសម្រេចបាននូវប្រសិទ្ធភាព និងសមធម៌ ដើម្បីធានាថាការបង្កើនចំណាយអាចនាំមកនូវលទ្ធផលប្រសើរឡើង និងការផ្តល់សេវាប្រកបដោយសមធម៌។

រូបភាព S.1 ថវិកាសរុបរបស់រដ្ឋាភិបាលនៅថ្នាក់ជាតិ តាមប្រភេទ (លានរៀល) ឆ្នាំ 2011-21




**ប្រភព៖** ច្បាប់ស្តីពីការទូទាត់ថវិកា និងបុគ្គលិកធនាគារពិភពលោក។

16 អត្ថបទផ្តោតពិសេសនេះត្រូវបានសរសេរដោយ Serdar Yilmaz សូ សុខប៊ុនធឿន និង ទួក ឃី។ ផ្នែកនេះនៃរបាយការណ៍ទទួលបានថវិកាគាំទ្រពីមូលនិធិបរធនបាលកិច្ចពហុម្ចាស់ជំនួយ (Multi-Donor Trust Fund) ស្តីពីហិរញ្ញវត្ថុសាធារណៈ និងការផ្តល់សាវាសាធរណៈ ដោយមានការចូលរួមចំណែកពីប្រទេសអូស្ត្រាលី និងសហភាពអឺរ៉ុប។

## ចំណូលក្នុងស្រុកដ៏រឹងមាំបានគាំទ្រដល់ការពង្រីកចំណាយសាធារណៈ

**ប្រទេសកម្ពុជាបានរក្សាអត្រាកំណើនប្រចាំឆ្នាំជាមធ្យម 7.6 ភាគរយនៅចន្លោះឆ្នាំ 1995 ដល់ឆ្នាំ 2019 ដែលធ្វើឱ្យប្រទេសនេះក្លាយជាប្រទេសមួយដែលមានសេដ្ឋកិច្ចលូតលាស់លឿនបំផុត នៅលើពិភពលោក។**[17] ដំណើរការកំណើនសេដ្ឋកិច្ចដ៏រឹងមាំ រួមជាមួយនឹងសមត្ថភាពគ្រប់គ្រងពន្ធដែលត្រូវបានពង្រឹងនៅក្រោម យុទ្ធសាស្ត្រកៀរគរចំណូល ឆ្នាំ 2014-2018 និង ឆ្នាំ 2019-2023 បានជំរុញឱ្យមានកំណើនប្រាក់ចំណូលក្នុងស្រុកយ៉ាងខ្លាំង។ ចំណូលក្នុងស្រុកសរុបឈានដល់ 25.1 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2019 កើនឡើងពី 12.8 ភាគរយក្នុងឆ្នាំ 2011 (រូបភាព S.2 ផ្ទាំង ក) ។ កត្តានេះបានអនុញ្ញាតឱ្យរដ្ឋាភិបាលប្រមូលទុនបម្រុងសារពើពន្ធដ៏ធំមួយដែលស្មើនឹង 23.7 ភាគរយនៃ ផ.ស.ស.នៅចុងឆ្នាំ 2020 ។[18] ការកើនឡើងនៃប្រាក់ចំណូលពន្ធបានធ្វើឱ្យប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសឈានមុខគេក្នុងតំបន់ និងស្ថិតក្នុងស្ថានភាពល្អប្រសើរជាងប្រទេសដែលមានចំណូលមធ្យមកម្រិតទាបដទៃទៀត (រូបភាព ស.2 បន្ទះ ខ)។ ទោះបីជា ប្រាក់ចំណូលក្នុងស្រុកបានធ្លាក់ចុះនៅឆ្នាំ 2020 និងឆ្នាំ 2021 ដោយសារផលប៉ះពាល់នៃវិបត្តិកូវីដ-19 លើសេដ្ឋកិច្ច និងការបន្ធូរបន្ថយពន្ធដល់ក្រុមហ៊ុនដែលរងផលប៉ះពាល់ អត្រាកំណើននៃការប្រមូលចំណូលក្នុងស្រុករបស់កម្ពុជាអាចស្ទុះងើបឡើងវិញស្ទើរតែដល់កម្រិតមុនកូវីដ ដែលកត្តាធំមួយគឺផ្នែកធំដោយសារកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសក្នុងការបង្កើនការប្រមូល និងការគ្រប់គ្រងពន្ធ និងការងើបឡើងវិញនៃសេដ្ឋកិច្ចជារួម។

រូបភាព S.2 ចំណូល និងចំណាយសរុបរបស់រដ្ឋាភិបាលកើនឡើងក្នុងឆ្នាំ 2011-22

**ផ្ទាំង ក** កំណើនប្រាក់ចំណូលសរុបរបស់រដ្ឋាភិបាល៖ ចំណូលក្នុងស្រុក (% នៃ ផ.ស.ស.)




**ប្រភព៖** អាជ្ញាធរកម្ពុជា។

**ផ្ទាំង ខ** ចំណូលពន្ធ (% នៃ ផ.ស.ស.) ឆ្នាំ 2019-20




**ប្រភព៖** សូចនាករអភិវឌ្ឍន៍ពិភពលោក។

17 ទោះបីជាកំណើនមានភាពរឹងមាំ ដោយឈានដល់ 7.1 ភាគរយក្នុងឆ្នាំ 2019 ក៏ដោយការរាតត្បាតនៃជំងឺ បានធ្វើឱ្យមានការថយចុះយ៉ាងខ្លាំងនៅក្នុងក្បាលម៉ាស៊ីនកំណើនសំខាន់ៗរបស់កម្ពុជានៅក្នុងត្រីមាសទីមួយនៃឆ្នាំ 2020។

18 ធនាគារពិភពលោក ឆ្នាំ 2022

## ភាពទូលំទូលាយនៃលំហសារពើពន្ធបានអនុញ្ញាតិឱ្យមានការចំណាយកាន់តែខ្ពស់ ជាពិសេសក្នុងវិស័យសង្គម

**ភាពទំលំទូលាយជាងមុននៃលំហសារពើពន្ធបានអនុញ្ញាតឱ្យរដ្ឋាភិបាលបង្កើនការចំណាយគ្រោងទុកសរុប។** ចំណាយគ្រោងទុកបានកើនឡើងពី 20,2 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2011 ដល់ 27.9 ភាគរយនៅឆ្នាំ 2021 ។ ស្របតាមគោលនយោបាយចំណាយសាធារណៈរបស់រដ្ឋាភិបាលដែលផ្តល់អាទិភាពលើ ការបង្កើនមូលធនមនុស្ស និងការបង្កើនការចំណាយក្នុងវិស័យសុខាភិបាល និងអប់រំ ចំណែកនៃការចំណាយក្នុងវិស័យសង្គមបានកើនឡើងដល់ 10.5 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2021 ពី 4.6 ក្នុងឆ្នាំ 2011 (រូបភាព S.3 ផ្ទាំង ក) ។ ទោះជាយ៉ាងណាក៏ដោយ ការបង្កើនចំណែកថវិការបស់កម្ពុជាត្រូវបានជំរុញមួយផ្នែកដោយការដំឡើងប្រាក់បៀវត្សរ៍មន្ត្រីរាជការជារួមដោយពុំមានការតភ្ជាប់ជាមួយនឹងគុណផលអនុវត្តន៍ការងារ។ ចំណាយលើប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈបានកើនឡើងយ៉ាងឆាប់រហ័សក្នុងអំឡុងពេលប៉ុន្មានឆ្នាំមុនពេលការរាតត្បាតនៃជំងឺកូវីដ-19។ ការបែងចែកចំណាយចរន្តមិនមែនបៀវត្សរ៍បានកើនឡើងក្នុងល្បឿនយឺតជាងនោះ កើនពី 6.1 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2011 ដល់ 8.6 ភាគរយនៅឆ្នាំ 2021 (រូបភាព S.3 ផ្ទាំង ខ) ។

រូបភាព S.3 ថវិកាសរុបរបស់រដ្ឋាភិបាលបានកើនឡើងចន្លោះឆ្នាំ 2011 និង 2022

**ផ្ទាំង ក** ការចំណាយរបស់រដ្ឋាភិបាល តាមក្រុមតាមវិស័យ (% នៃ ផ.ស.ស.) ឆ្នាំ 2011-21




**ផ្ទាំង ខ** ការបែងចែកថវិកាចរន្តមិនមែនប្រាក់បៀវត្សរ៍ តាមចំណាត់ថ្នាក់សេដ្ឋកិច្ច (% នៃ ផ.ស.ស.) ឆ្នាំ 2011-21




**ប្រភព៖** ច្បាប់ស្តីពីការទូទាត់ថវិកា និងបុគ្គលិកធនាគារពិភពលោក។

## បន្ទាប់ពីការធ្វើកំណែទម្រង់ និងការដំឡើងប្រាក់បៀវត្សរ៍រយៈពេលមួយទសវត្សរ៍កន្លងមក បៀវត្សរ៍ជាមធ្យមក្នុងវិស័យសាធារណៈ បច្ចុប្បន្នលើសពីប្រាក់ខែជាមធ្យមរបស់វិស័យឯកជន

**ការបង្កើនចំណាយសារធារណៈរបស់កម្ពុជាត្រូវបានជំរុញមួយផ្នែកដោយការដំឡើងប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីរាជការជារួមដោយពុំមានការតភ្ជាប់ជាមួយនឹងគុណផលអនុវត្តន៍ការងារ។** រវាងឆ្នាំ 2011 និង 2021 ប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈ បើគិតជាចំណែកនៃ ផ.ស.ស. បានកើនឡើងស្ទើតែទ្វេដងដែលឈានដល់ 7.2 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2021 កើនឡើងពី 4.4 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2011 ។ ស្ថិតិនេះបង្ហាញអំពីកំណើនបីដងនៃប្រាក់បៀវត្សរ៍អប្បបរមារបស់មន្ត្រីរាជការបើធៀបនឹងឆ្នាំ 2013 ដែលបានសម្រេចគោលដៅ 1 លានរៀលក្នុងមួយខែនៅឆ្នាំ 2018 ។ លើសពីនេះ ទោះបីរដ្ឋាភិបាលបានបង្កើនប្រាក់បៀវត្សរ៍ជាមធ្យមប្រចាំខែសម្រាប់មន្ត្រីរាជការម្នាក់ៗ វិស័យរដ្ឋបាលទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីកំណើននេះ (រូបភាព S.4)។

**រូបភាព S.4** ប្រាក់បៀវត្សរ៍ជាមធ្យមប្រចាំខែរបស់មន្ត្រីរាជការ ឆ្នាំ2021




ប្រភព៖ អាជ្ញាធរកម្ពុជា (ច្បាប់ស្តីពីការទូទាត់ថវិកាឆ្នាំ 2021)។

*សម្គាល់៖* ការចំណាយជាក់ស្តែងក្រោមជំពូក 64 សម្រាប់គ្រប់ក្រសួងទាំងអស់ (លើកលែងតែក្រសួងសុខាភិបាល សម្រាប់ឆ្នាំ 2020) និងស្ថិតិមន្ត្រីរាជការស៊ីវិល ឆ្នាំ 2022 (ក្រសួងមុខងារសាធារណៈ)។

**ការកើនឡើងនៃបញ្ជីប្រាក់បៀវត្សរ៍សាធារណៈបានធ្វើឱ្យកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលបានចំណាយចំណែកនៃចំណូលរដ្ឋខ្ពស់លើប្រាក់បៀវត្សរ៍មន្ត្រីរាជការ ជាពិសេសបើប្រៀបធៀបទៅនឹងបណ្តាប្រទេសក្នុងតំបន់ (រូបភាព S.5) ។** ប្រទេសជិតខាងក្នុងតំបន់ទាំងអស់ លើកលែងតែប្រទេសវៀតណាម និងប៉ាឡូវ (ប្រទេសទាំងពីរមានកម្រិតចំណូលមនុស្សម្នាក់ខ្ពស់ជាងកម្ពុជា) ចំណាយតិចជាងកម្ពុជាលើប្រាក់បៀវត្សរ៍មន្ត្រីរាជការរបស់ខ្លួន (រូបភាព S.5 ផ្ទាំង ក) ហើយតាមពិតកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលបានចំណាយចំណែកនៃចំនូលរដ្ឋកម្រិតខ្ពស់បំផុតលើប្រាក់បៀវត្សរ៍មន្ត្រីរាជការ (រូបភាព S.5, ផ្ទាំង ខ) ។

**រូបភាព S.5** ប្រវត្តិនៃការចំណាយប្រាក់បៀវត្សរ៍មន្ត្រីរាជការសាធារណៈ

**ផ្ទាំង ក** ចំណាយលើប្រាក់បៀវត្សរ៍មន្ត្រីរាជការ (% នៃចំណាយសាធារណៈ) ឆ្នាំ 2005-19

**ផ្ទាំង ខ** ចំណាយប្រាក់ប្រាក់បៀវត្សរ៍ និង % ផ.ស.ស.នៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក




ប្រភព៖ សូចនាករការិយាធិបតេយ្យសកលរបស់ធនាគារពិភពលោក ផ្អែកលើទិន្នន័យមូលនិធិរូបិយវត្ថុអន្តរជាតិ។

**មន្ត្រីរាជការសាធារណៈរបស់កម្ពុជាបច្ចុប្បន្នទទួលបានប្រាក់បៀវត្សរ៍ជាមធ្យមខ្ពស់ជាងអ្នកធ្វើការក្នុងវិស័យឯកជន។**[19] ប្រាក់បៀវត្សរ៍ជាមធ្យមប្រចាំខែរបស់វិស័យសាធារណៈបានកើនឡើងដល់ 1.50 លានរៀលក្នុងឆ្នាំ 2019 ធៀបនឹង 1.25 លានរៀលសម្រាប់វិស័យឯកជន។ បុព្វលាភប្រាក់បៀវត្សរ៍មន្ត្រីរាជការរបស់កម្ពុជាធៀបនឹងប្រាក់ខែរបស់បុគ្គលិកវិស័យឯកជន (ទោះបីរាប់បញ្ចូលលក្ខណៈដែលអាចសង្កេតបានដូចជាបទពិសោធន៍ គុណវឌ្ឍន៍ការអប់រំ ភេទ និងទីកន្លែងការងារ) គឺ 18.8 ភាគរយក្នុងឆ្នាំ 2019 (រូបភាព S.6)។[20] បុព្វលាភប្រាក់ឈ្នួលវិជ្ជមានដែលមន្ត្រីរាជការទទួលបានគឺខ្ពស់ជាងមធ្យមភាគក្នុងតំបន់ 3 ភាគរយ ហើយស្ថិតក្នុងចំណោមកម្រិតខ្ពស់បំផុតបើធៀបនឹងប្រទេសជិតខាងលើកលែងតែហ្វីលីពីនប៉ុណ្ណោះដែលខ្ពស់ជាង។ លើសពីនេះ លទ្ធផលបែបនេះក៏មានភាពដូចគ្នានៅក្នុងវិស័យអប់រំ និងសុខាភិបាល ដែលបុព្វលាភប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈក៏មានភាពវិជ្ជមាន និងគួរអោយកត់សម្គាល់ (6 ភាគរយក្នុងវិស័យសុខាភិបាល និង 17 ភាគរយក្នុងវិស័យអប់រំ)។

**ប្រាក់បៀវត្សរ៍វិស័យសាធារណៈជាមធ្យមខ្ពស់ជាងប្រាក់ខែវិស័យឯកជន 18.8 ភាគរយ ។** នេះបង្ហាញពីវឌ្ឍនភាពដ៏ល្អពីកម្រិតនៅឆ្នាំ 2003 ដែលពេលនោះប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈមានទាបជាងវិស័យឯកជន 38.4 ភាគរយ (រូបភាព S.7) ។ ក្នុងកំឡុងឆ្នាំ 2003-12 ដោយសារតែប្រាក់បៀវត្សរ៍ផ្តល់ដោយរដ្ឋាភិបាលមានកំម្រិតទាប (បើប្រៀបធៀបទៅនឹងវិស័យឯកជន) ការងាររដ្ឋមិនមានភាពទាក់ទាញសម្រាប់និស្សិតទើបបញ្ចប់ការសិក្សា និងកម្មករជំនាញទេ។ កត្តានេះនាំឱ្យមានបញ្ហាក្នុងចំណោមបុគ្គលិករដ្ឋាភិបាល ដូចជាត្រូវធ្វើការបន្ថែមក្រៅម៉ោង ខណៈដែលបុគ្គិលជំនាញវ័យក្មេងផ្សេងទៀតបានចាកចេញពីរដ្ឋាភិបាលសម្រាប់ការងារវិស័យឯកជនដែលផ្តល់ប្រាក់ខែខ្ពស់ជាង ដែលនាំឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រសិទ្ធភាពរបស់រដ្ឋាភិបាល។[21] បន្ទាប់ពីឆ្នាំ 2013 កំណែទម្រង់ប្រាក់បៀវត្សរ៍ក្រោមកម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាលសាធារណៈបានធ្វើឱ្យមានការរៀបចំឡើងវិញនូវទំហំប្រាក់បៀវត្សរ៍ ហើយកំណែទម្រង់នេះ រួមជាមួយនឹងការដំឡើងប្រាក់បៀវត្សរ៍ប្រចាំឆ្នាំជាបន្តបន្ទាប់ដោយពុំមានការតភ្ជាប់ជាមួយនឹងគុណផលអនុវត្តន៍ការងារនាំឱ្យប្រាក់បៀវត្សរ៍មន្ត្រីរាជការមូលដ្ឋានមានភាពប្រសើរឡើងយ៉ាងច្រើន។ ការបង្កើនប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីរាជការនេះ បានធ្វើអោយប្រាក់បៀវត្សន៍នៅក្នុងវិស័យសាធារណៈមានលក្ខណៈប្រគួតប្រជែងជាងមុន។

រូបភាព S.6 បុព្វលាភប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈ (ធៀបនឹងបុគ្គលិកវិស័យឯកជនទាំងអស់)




**ប្រភព៖** សូចនាករការិយាធិបតេយ្យទូទាំងពិភពលោករបស់ធនាគារពិភពលោក

រូបភាព S.7 បុព្វលាភប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈរបស់កម្ពុជាក្នុងពេលកន្លងមក




**ប្រភព៖** សូចនាករការិយាធិបតេយ្យទូទាំងពិភពលោករបស់ធនាគារពិភពលោក

19 ខណៈពេលដែលកម្រិតប្រាក់ឈ្នួលក្នុងវិស័យសាធារណៈគឺជាកត្តាកំណត់ដ៏សំខាន់នៃការលើកទឹកចិត្តបុគ្គលិក និងសមត្ថភាពរបស់រដ្ឋ វាក៏នាំមកនូវផលវិបាកសំខាន់ៗសម្រាប់ប្រសិទ្ធភាពនៃការចំណាយ និរន្តរភាពសារពើពន្ធ និងលទ្ធផលលំនឹងនៅក្នុងទីផ្សារការងារទាំងមូលផងដែរ។ ទោះយ៉ាងណាក៏ដោយ ការឆ្លើយសំណួរថា "តើវិស័យសាធារណៈចំណាយច្រើន ឬតិចពេក?" ជាធម្មតា ត្រូវការការប្រៀបធៀបសមស្របមួយ។ ការប្រៀបធៀបប្រាក់ឈ្នួលវិស័យសាធារណៈ និងឯកជនមានប្រយោជន៍ក្នុងន័យការវិភាគ ដោយសារជម្រើសខាងក្រៅដែលទំនងបំផុតសម្រាប់ការងារក្នុងវិស័យសាធារណៈគឺវិស័យឯកជន។

20 ភាពខុសគ្នានៃប្រាក់ឈ្នួលមិនទាន់គិតប្រភពសំណងបន្ថែមដូចជាប្រាក់ឧបត្ថម្ភ និងការឧបត្ថម្ភនានាដែលទំនងជាខ្ពស់ជាងវិស័យឯកជននៅឡើយទេ។ ដូច្នេះ ការប៉ាន់ប្រមាណទាំងនេះប្រហែលជាមានកម្រិតទាបជាបុព្វលាភប្រាក់ឈ្នួលពិតប្រាកដ។ ទោះជាយ៉ាងណាក៏ដោយ កង្វះព័ត៌មានលើការស្នងមតិគ្រួសារប៉ះពាល់ដល់សមត្ថភាពក្នុងការវិភាគបន្ថែម។

21 ឧត្តម 2012។

**ភាពខុសគ្នានៃប្រាក់បៀវត្សរ៍រវាងវិស័យសាធារណៈ និងឯកជនប្រែប្រួលទៅតាមកម្រិតនៃការអប់រំ។** មន្ត្រីរាជការសាធារណៈដែលមានការអប់រំកម្រិតឧត្តមសិក្សាទទួលបានប្រាក់ខែ 7.5 ភាគរយច្រើនជាងអ្នកធ្វើការកម្រិតដូចគ្នាក្នុងវិស័យឯកជន។ ទោះជាយ៉ាងណាក៏ដោយ មន្ត្រីក្នុងវិស័យសាធារណៈដែលគ្មានការអប់រំមានប្រាក់បៀវត្សរ៍តិចជាង 16.4 ភាគរយធៀបនឹងអ្នកធ្វើការកម្រិតដូចគ្នាក្នុងវិស័យឯកជន។[22] គម្លាតបៀវត្សរ៍រវាងបុគ្គលិកក្នុងវិស័យសាធារណៈ និងឯកជនផ្លូវការមានកម្រិតខ្ពស់បំផុតក្នុងចំណោមបុគ្គលិកដែលមានការអប់រំកម្រិតមធ្យមសិក្សា ពោលគឺ 14.7 ភាគរយដែលវិស័យសាធារណៈមានលើសឯកជន (រូបភាព S.8) ។ បុព្វលាភប្រាក់ឈ្នួលខ្ពស់ក្នុងចំណោមបុគ្គលិកដែលមានការអប់រំខ្ពស់ រួមជាមួយនឹងបរិមាណបុគ្គលិករដ្ឋដែលមានចំនួនច្រើនជាងបុគ្គលិកនៅក្នុងវិស័យឯកជន បង្ហាញពីកង្វះកម្លាំងពលកម្មជំនាញសម្រាប់វិស័យឯកជន ដោយអាចបង្ករផលប៉ះពាល់ធំជាច្រើនសម្រាប់និរន្តរភាពនៃការចំណាយលើប្រាក់បៀវត្សរ៍មន្ត្រីរាជការសាធារណៈ។

**មុខរបរបច្ចេកទេសទទួលបុព្វលាភចំណូលខ្ពស់ក្នុងវិស័យសាធារណៈជាងមុខរបរជាអ្នកគ្រប់គ្រងជាន់ខ្ពស់។** នៅកម្ពុជាអ្នកជំនាញបច្ចេកទេសក្នុងវិស័យសាធារណៈទទួលបានប្រាក់បៀវត្សរ៍ខ្ពស់ជាងបុគ្គលិកឯកជនចំនួន 40.4 ភាគរយ ដែលភាគច្រើនត្រូវបានជំរុញដោយសមាមាត្រខ្ពស់នៃមន្ត្រីនគរបាល និងមន្ត្រីរដ្ឋបាលសាធារណៈ។ មុខរបរផ្សេងទៀតទាំងអស់នៅក្នុងវិស័យសាធារណៈត្រូវបង់ពិន័យប្រាក់បៀវត្សរ៍ ហើយការពិន័យខ្ពស់បំផុតត្រូវបានគេសង្កេតឃើញក្នុងចំណោមមន្ត្រីជាន់ខ្ពស់ (65 ភាគរយ) ដូចដែលបានឃើញនៅក្នុងរូបភាព S.9 ។ ជាធម្មតា វាត្រូវបានគេសង្កេតឃើញនៅក្នុងប្រទេសផ្សេងទៀត ដែលបុព្វលាភខ្ពស់សម្រាប់មន្ត្រីរាជការកម្រិតបឋមជាងមន្ត្រីរាជការជាន់ខ្ពស់ ដែលអាចជាការរំខានជាពិសេសដល់ទីផ្សារការងារទាំងមូល។ ដោយសារតែបុព្វលាភខ្ពស់ក្នុងចំណោមអ្នកឯកទេសបែបនេះ វាមិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ដែលគេឃើញតម្រូវការសម្រាប់ការងារក្នុងវិស័យសាធារណៈមានកំរិតខ្លាំង ជាមួយនឹងការដាក់ពាក្យសុំរាប់រយសម្រាប់មុខតំណែងនីមួយៗ។

រូបភាព S.8 បុព្វលាភប្រាក់បៀវត្សរ៍តាមកម្រិតអប់រំ (ប្រៀបធៀបជាមួយបុគ្គលិកឯកជន)




រូបភាព S.9 បុព្វលាភប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈតាមក្រុមមុខរបរ (ប្រៀបធៀបជាមួយបុគ្គលិកឯកជន)




**ប្រភព៖** សូចនាករអភិបាលកិច្ចទូទាំងពិភពលោករបស់ធនាគារពិភពលោក

22 ភាពខុសគ្នានៅក្នុងគម្លាតប្រាក់ឈ្នួលតាមកម្រិតនៃការអប់រំនេះអាចបណ្តាលមកពីកត្តាជាច្រើន ហើយគេអាចកំណត់កត្តាទាំងនេះបានទេ ប្រសិនបើគ្មានទិន្នន័យពីការស្ទង់មតិគ្រួសារ។ វាអាចកើតចេញពីគម្លាតផលិតភាពផ្សេងៗគ្នានៅក្នុងវិស័យសាធារណៈ ដែលមានភាពខុសប្លែកគ្នាតាមមុខរបរ ដូចជាអំណាចចរចារបស់សហជីពដ៏ខ្លាំងរបស់បុគ្គលិកដែលមានជំនាញទាប។

**បុគ្គលិកជាស្ត្រីនៅក្នុងវិស័យសាធារណៈទទួលរងនូវគម្លាតប្រាក់បៀវត្សរ៍យេនឌ័រដ៏ធំនៅក្នុងផ្នែកជាច្រើននៃកម្លាំងការងារវិស័យសាធារណៈ។** នៅទូទាំងពិភពលោក ស្ត្រីតែងតែរកចំណូលបានតិចខ្លាំងជាងបុរស សម្រាប់ការងារដូចគ្នាទាំងក្នុងវិស័យសាធារណៈ និងឯកជន។ នៅកម្ពុជា បុគ្គលិកស្ត្រីទទួលបាន 94 ភាគរយនៃប្រាក់ខែរបស់បុគ្គលិកបុរសក្នុងវិស័យឯកជន និង 89 ភាគរយក្នុងវិស័យសាធារណៈ ហើយគម្លាតប្រាក់បៀវត្សរ៍នេះត្រូវបានគេសង្កេតឃើញថាកាន់តែកើនឡើងជាលំដាប់វិស័យសាធារណៈ (រូបភាព S.10, ផ្ទាំង ក) ។ ជាងនេះទៅទៀត ស្ត្រីនៅក្នុងប្រទេសកម្ពុជាបំពេញការងារភាគច្រើននៅក្នុងវិស័យអប់រំ និងសុខាភិបាល ប៉ុន្តែការចូលរួមរបស់ភាគច្រើនគឺនៅក្នុងការងារដែលមានប្រាក់ខែទាប។ ស្ត្រីដែលធ្វើការក្នុងវិស័យអប់រំប្រឈមនឹងការពិន័យប្រាក់បៀវត្សរ៍ 7 ភាគរយ ធៀបនឹងសមភាគីបុរសរបស់ពួកគេដែលធ្វើការដូចគ្នា និងដែលមានម៉ោងការងារប្រហាក់ប្រហែលគ្នា (រូបភាព S.10, ផ្ទាំង ខ) ទោះបីក្រោយការបូកបញ្ចូលនូវអាយុ គុណវឌ្ឍន៍អប់រំ និងទីតាំងក៏ដោយ។ នៅក្នុងរដ្ឋបាលសាធារណៈ ស្ត្រីប្រឈមនឹងការពិន័យប្រាក់ឈ្នួល 30.7 ភាគរយ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីនៅក្នុងវិស័យសុខាភិបាលទទួលបានប្រាក់បៀវត្សរ៍ស្មើរតែ 10 ភាគរយច្រើនជាងបុរសនៅក្នុងឧស្សាហកម្មតែមួយ។ ទោះបីការពិន័យប្រាក់បៀវត្សរ៍សម្រាប់ស្ត្រីត្រូវបានគេសង្កេតឃើញជាសកលក៏ដោយ នៅក្នុងប្រទេសកម្ពុជា ទំហំនៃការពិន័យទាំងនេះមានកម្រិតខ្ពស់ជាង។ ការពិន័យប្រាក់បៀវត្សរ៍យេនឌ័រសកលជាមធ្យមគឺ 3 ភាគរយសម្រាប់ការអប់រំ និង 2 ភាគរយសម្រាប់ឧស្សាហកម្មរដ្ឋបាលសាធារណៈរៀងគ្នា។

រូបភាព S.10 គម្លាតប្រាក់បៀវត្សរ៍យេនឌ័រនៅកម្ពុជា

**ផ្ទាំង ក** សមាមាត្រប្រាក់បៀវត្សរ៍រវាងបុគ្គលិកជាស្ត្រី និងបុរសតាមវិស័យការងារ




**ផ្ទាំង ខ** បុព្វលាភប្រាក់បៀវត្សរ៍យេនឌ័រវិស័យសាធារណៈ តាមវិស័យ






## ការចំណាយនៅក្នុងវិស័យអប់រំបានកើនឡើង ប៉ុន្តែនៅមិនទាន់ធ្វើឱ្យលទ្ធផលសិក្សាប្រសើរឡើងនៅឡើយទេ

**ដោយមានការផ្តោតលើអភិវឌ្ឍន៍ធនធានមនុស្សក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រដ្ឋាភិបាលកម្ពុជា គឺយុទ្ធសាស្ត្រចតុកោណ[23] ដំណាក់កាលទី4 ការចំណាយរបស់រដ្ឋាភិបាលសម្រាប់វិស័យសង្គមបានកើនឡើងយ៉ាងខ្លាំង។** កម្ពុជាបានបង្កើនការចំណាយលើវិស័យអប់រំ ប៉ុន្តែការបង្កើនថវិកានេះផ្តោតលើចំណាយប្រាក់ខែ ដែលបានកើតឡើងមុនវិបត្តិកូវីដ-19 ហើយត្រូវបានជំរុញជាចម្បងដោយការដំឡើងប្រាក់បៀវត្សរ៍សម្រាប់បុគ្គលិកអប់រំមួយចំនួនធំ។ ដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់បុគ្គលិកអប់រំជាពិសេសគ្រូបង្រៀន រដ្ឋាភិបាលបានដំឡើងប្រាក់បៀវត្សរ៍តាំងពីឆ្នាំ 2014។ ប្រាក់បៀវត្សរ៍ចាប់ផ្តើមសម្រាប់គ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិកើនឡើងទ្វេដងនៅចន្លោះឆ្នាំ 2014 និង 2020 ដោយសារតែការកើនឡើងទាំងប្រាក់ខែគោល និងប្រាក់ឧបត្ថម្ភមុខងារ។ លើសពីនេះ ចំនួនបុគ្គលិកអប់រំសរុបបានកើនឡើងចំនួន 6 ភាគរយក្នុងអំឡុងពេលដូចគ្នា ពី 107,395 នាក់ក្នុងឆ្នាំ 2014 ដល់ 114,170 ក្នុងឆ្នាំ 2020។ ដូច្នេះ ការដំឡើងប្រាក់បៀវត្សរ៍បានបង្រួម ទំហំថវិកាសម្រាប់ចំណាយមូលធន។ ឧទាហរណ៍៖ ការចំណាយប្រាក់បៀវត្សរ៍ គិតជាភាគរយនៃចំណាយសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡាកើនឡើងដល់ជិត 80 ភាគរយនៅឆ្នាំ 2021 កើនពី 70 ភាគរយក្នុងឆ្នាំ 2018។ ការចំណាយមិនមែនប្រាក់ឈ្នួលជាចំណែកនៃថវិកាសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា បានកើនឡើងបន្តិចបន្តួចក្នុងអំឡុងពេលដូចគ្នានេះ។ ទោះជាយ៉ាងណាក៏ដោយ ចំណែកថវិកាសម្រាប់ចំណាយមូលធនបានធ្លាក់ចុះយ៉ាងខ្លាំង ពី 13 ភាគរយក្នុងឆ្នាំ 2018 មកត្រឹមតែ 3 ភាគរយនៃថវិកាសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងឆ្នាំ 2021 (រូបភាព S.11)។

**ទោះបីប្រាក់បៀវត្សរ៍ជាមធ្យមរបស់វិស័យសាធារណៈខ្ពស់ជាងវិស័យឯកជន ការគ្រប់គ្រងធនធានមនុស្សនៅតែជាបញ្ហាប្រឈម។** វិស័យអប់រំនៅតែបន្តប្រឈមនឹងបញ្ហាលំបាក ជាពិសេសបញ្ហាកង្វះខាត និងការបែងចែកគ្រូមិនស្មើគ្នា។ នៅថ្នាក់ជាតិ ជាទូទៅចំនួនគ្រូសរុបគឺគ្រប់គ្រាន់។ ប៉ុន្តែ ទំហំថ្នាក់រៀន នៅតែធំជាងក្នុងបណ្តាប្រទេសអាស៊ានផ្សេងទៀត។ កម្ពុជាមានសមាមាត្រសិស្ស-គ្រូខ្ពស់បំផុតសម្រាប់ថ្នាក់បឋមសិក្សាពីឆ្នាំ 2013 ដល់ឆ្នាំ 2018។ សម្រាប់មធ្យមសិក្សា សមាមាត្រសិស្ស-គ្រូនៅតែខ្ពស់ ប៉ុន្តែទាបជាងនៅប្រទេសថៃ និងមីយ៉ាន់ម៉ាសម្រាប់រយៈពេលដូចគ្នា។ ទំហំថ្នាក់រៀនធំនៅក្នុងប្រទេសកម្ពុជា ភាគច្រើនបណ្តាលមកពីការបែងចែកគ្រូបង្រៀនមិនមានប្រសិទ្ធភាព។ នៅថ្នាក់ជាតិ ដោយផ្អែកលើបទដ្ឋានឆ្នាំ 2018 របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីសមាមាត្រសិស្ស-គ្រូ កម្ពុជាមានកង្វះគ្រូបង្រៀនសរុបចំនួន 12,305 នាក់ក្នុងឆ្នាំ 2021។ មានការកង្វះគ្រូបង្រៀនចំនួន 4,833 នាក់នៅក្នុងសាលាមត្តេយ្យសិក្សា និង 9,959 នាក់នៅក្នុងសាលាបឋមសិក្សា។ ទោះយ៉ាងណាក៏ដោយ មានអតិរេកគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិសម្រាប់ឆ្នាំដដែល។

រូបភាព S.11 ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃថវិកាក្រសួងអប់រំ យុវជន និងកីឡា (% នៃការចំណាយថវិកាសរុប)




**ប្រភព៖** ច្បាប់ថវិកាឆ្នាំ 2017-2022 និងបុគ្គលិកធនាគារពិភពលោក។

23 យុទ្ធសាស្ត្រចតុកោណរបស់កម្ពុជាត្រូវបានរៀបចំឡើង ដើម្បីដឹកនាំការអនុវត្តរបៀបវារៈរបស់រាជរដ្ឋាភិបាល។ ដំណាក់កាលទី IV ផ្តោតលើកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។

**ការចំណាយលើហេដ្ឋារចនាសម្ព័ន្ធអប់រំពឹងផ្អែកជាចម្បងលើមូលធនរបស់ដៃគូអភិវឌ្ឍន៍ (DP)។** ចន្លោះឆ្នាំ 2017 និង 2021 ថវិកាដែលទទួលបានជំនួយពីដៃគូអភិវឌ្ឍន៍ បើគិតជាចំណែកនៃថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា មានប្រហែលពី 1.5 ទៅ 3.3 ដងនៃការចំណាយដែលបានគ្រោងទុករបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងរយៈពេលដូចគ្នា។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធអប់រំបានធ្លាក់ចុះ ដែលជំរុញដោយការថយចុះនៃថវិកាដែលទទួលបានជំនួយពីដៃគូអភិវឌ្ឍន៍ និងថវិកាមូលធនរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការចំណាយមូលធនដែលបានគ្រោងទុកដែលទទួលបានជំនួយពីដៃគូអភិវឌ្ឍន៍ បើគិតជាចំណែកនៃថវិការបស់ក្រសួងអប់រំ យុវជន និងកីឡាមានចំនួន 6 ភាគរយក្នុងឆ្នាំ 2021 ដែលជាការធ្លាក់ចុះជាលំដាប់ពី 10 ភាគរយក្នុងឆ្នាំ 2017។ ថវិកាចំណាយមូលធនរបស់ក្រសួងអប់រំ យុវជន និងកីឡាបានធ្លាក់ចុះបីដង គឺពី 12 ភាគរយនៃថវិកាក្នុងឆ្នាំ 2018 មកត្រឹមតែ 3 ភាគរយនៅឆ្នាំ 2021 (រូបភាព S.12 ផ្ទាំង ក និង ខ)។

រូបភាព S.12 ចំណាយជាប្រចាំ និងចំណាយមូលធនរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ 2017-21

**ផ្ទាំង ក** ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា តាមប្រភេទ ឆ្នាំ 2017-21




**ប្រភព៖** ច្បាប់ស្តីពីការទូទាត់ថវិកា និងបុគ្គលិកធនាគារពិភពលោក។

**ផ្ទាំង ខ** ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា តាមប្រភេទ (% នៃថវិការសរុប) ឆ្នាំ 2017-21




**ប្រភព៖** ច្បាប់ស្តីពីការទូទាត់ថវិកា និងបុគ្គលិកធនាគារពិភពលោក។



**ការអនុវត្តថវិកាសម្រាប់ចំណាយជាប្រចាំស្របតាមផែនការថវិកា។** ទោះជាយ៉ាងណាក៏ដោយ លទ្ធផលថវិកាសម្រាប់ការចំណាយមូលធន - ទាំងហិរញ្ញបទានក្នុងស្រុក និងពីខាងក្រៅ - មានការប្រែប្រួលខ្លាំង (រូបភាព S.13) ។ វាបង្ហាញពីភាពទន់ខ្សោយក្នុងការរៀបចំផែនការ និងការអនុវត្តការចំណាយមូលធន។ ការធ្វើឱ្យគម្រោងវិនិយោគសាធារណៈកាន់តែគ្រប់ជ្រុងជ្រោយ និងការតម្រឹមគម្រោងវិនិយោគសាធារណៈជាមួយនឹងដំណើរការថវិកា អាចពង្រឹងការរៀបចំផែនការគម្រោងវិនិយោគ។[24] ទោះបីចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់របស់កម្ពុជាមានកម្រិតទាបបំផុត បើធៀបនឹងប្រទេសជិតខាងក្នុងតំបន់ ការចំណាយលើវិស័យអប់រំរបស់កម្ពុជាចំនួន 3.12 ភាគរយនៃ ផ.ស.ស. គឺខ្ពស់គួរសម — ខ្ពស់ជាងប្រទេសឡាវ ស្រដៀងនឹងប្រទេសថៃ (3.14 ភាគរយនៃ ផ.ស.ស.) និងទាបជាងប្រទេសឥណ្ឌូនេស៊ីបន្តិច (3.49 ភាគរយនៃ ផ.ស.ស.) ហ្វីលីពីន (3.73 ភាគរយនៃ ផ.ស.ស.) និង ម៉ាឡេស៊ី (3.91 ភាគរយនៃ ផ.ស.ស.) (រូបភាព S.14) ។

រូបភាព S.13 ផែនការចំណាយមូលធន និងលទ្ធផលថវិកា លទ្ធផលថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ 2017-21




**ប្រភព៖** ខាងឆ្វេង៖ ច្បាប់ស្តីពីការទូទាត់ថវិកា បុគ្គលិកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារពិភពលោក។ ស្តាំ៖ ការវាយតម្លៃការគ្រប់គ្រងការវិនិយោគសាធារណៈ ឆ្នាំ 2019 ។

រូបភាព S.14 ការចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំ៖ ភាគរយនៃ ផ.ស.ស. ធៀបនឹងចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ ឆ្នាំ2021




**ប្រភព៖** សូចនាករអភិវឌ្ឍន៍ពិភពលោក

24 មូលនិធិរូបិយវត្ថុអន្តរជាតិ, ការគ្រប់គ្រងការវិនិយោគសាធារណៈនៅកម្ពុជា (PIMA) ឆ្នាំ 2019។

**លទ្ធផលនៃការអប់រំមានភាពប្រសើរឡើងក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ប៉ុន្តែគម្លាតអប់រំរវាងតំបន់ទីក្រុងនិងតំបន់ជនបទនៅតែមាន។** រវាងឆ្នាំ 2009 និង 2019 អត្រាចុះឈ្មោះចូលរៀនសុទ្ធសម្រាប់ការអប់រំបឋមសិក្សាបានកើនឡើងពី 81 ភាគរយដល់ 90 ភាគរយ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិពី 31.5 ភាគរយទៅ 47.5 ភាគរយ និងសម្រាប់មធ្យមសិក្សាទុតិយភូមិពី 17.9 ភាគរយទៅ 30.9 ភាគរយ។ អត្រាអក្ខរកម្មសម្រាប់ប្រជាជនដែលមានអាយុចាប់ពី 15 ឆ្នាំឡើងទៅបានកើនឡើងពី 73.9 ភាគរយដល់ 81.9 ភាគរយក្នុងរយៈពេលដូចគ្នានេះ។ ទោះយ៉ាងណាក៏ដោយ ការចុះឈ្មោះចូលរៀនសុទ្ធនិងអត្រាអក្ខរកម្មនៅតែមានភាពខុសប្លែកគ្នាខ្លាំងរវាងទីក្រុង និងជនបទ។ ទោះបីប្រទេសកម្ពុជាបានកាត់បន្ថយភាគរយនៃប្រជាជនដែលមិនបានចូលរៀនក៏ដោយ អត្រាការបញ្ចប់ការសិក្សាសម្រាប់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិមិនមានការផ្លាស់ប្តូរទេ។ រូបភាព S.15 បង្ហាញថាការចុះឈ្មោះចូលរៀនសុទ្ធមាន អត្រាខ្ពស់នៅទីក្រុងជាងតំបន់ជនបទ ជាពិសេសបន្ទាប់ពីការអប់រំបឋមសិក្សា។

**ទោះបីជាមានភាពប្រសើរឡើងក៏ដោយ ក៏លទ្ធផលអប់រំ រួមទាំងអត្រាអក្ខរកម្មផងដែរនៅតែមានភាពយឺតយ៉ាវ បើធៀបនឹងបណ្តាប្រទេសអាស៊ានផ្សេងទៀត។** (រូបភាព S.16) ។ អត្រាបញ្ចប់ការសិក្សាក៏ទាបជាងបណ្តាប្រទេសអាស៊ានភាគច្រើនដែរ ដែលបង្ហាញពីតំរូវការការងារជាច្រើនបន្ថែមទៀត ដើម្បីរក្សាសិស្សឱ្យបន្តរៀននៅមធ្យមសិក្សា។ ម្យ៉ាងវិញទៀត អត្រាបោះបង់ការសិក្សានៅសាលាបឋមសិក្សានៅតែមានកម្រិតខ្ពស់បំផុតនៅក្នុងតំបន់អាស៊ាន។ ចំពោះភាពវិជ្ជមាន អត្រាអ្នកដែលមិនបានចូលរៀនបានធ្លាក់ចុះពី 28 ភាគរយក្នុងឆ្នាំ 2009 មក 18 ភាគរយសម្រាប់ឆ្នាំសិក្សា 2019/20 ។

### រូបភាព S.15 អត្រាចុះឈ្មោះចូលរៀនសុទ្ធ ទីក្រុង និងជនបទ 2009-2019/20




**ប្រភព៖** CSES 2014 និង CSES 2019-2020។

### រូបភាព S.16 អត្រាអក្ខរកម្មនៅកម្ពុជា និងធៀបនឹងប្រទេសអាស៊ានដទៃទៀត

**ផ្ទាំង ក** អត្រាអក្ខរកម្មនៅកម្ពុជា ឆ្នាំ2009-2019/20




**ផ្ទាំង ខ** អត្រាអក្ខរកម្មនៅកម្ពុជា ធៀបនឹងប្រទេសអាស៊ានដទៃទៀត




**ប្រភព៖** ផ្ទាំង ក៖ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា 2014 និង អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា 2019-20; ផ្ទាំង ខ៖ ប្រទេសកម្ពុជា៖ ដកស្រង់ចេញពី អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា 2019-20 និងប្រទេសផ្សេងទៀត៖ ប្រភពមកពី *សូចនាករអភិវឌ្ឍន៍ពិភពលោក* (WDI) (ដកស្រង់នៅខែមីនា ឆ្នាំ 2023)។

**កំណើនចំណាយលើវិស័យអប់រំមិនទាន់បាននាំមកនូវកំណើនលទ្ធផលសិក្សានៅឡើយទេ។** លទ្ធផលសិក្សាសម្រាប់សិស្សថ្នាក់ទី6 និងទី8 នៅមានកម្រិតទាប។ ចន្លោះឆ្នាំ 2013 និង 2021 ជាមធ្យម សិស្សថ្នាក់ទី 6 អាចឆ្លើយសំណួរភាសាខ្មែរបានតិចជាង 52 ភាគរយ។ លទ្ធផលសិក្សារបស់សិស្សសម្រាប់គណិតវិទ្យាគឺកាន់តែខ្សោយ។ ជាមធ្យម សិស្សថ្នាក់ទី 6 ឆ្លើយបានត្រឹមត្រូវតិចជាងពាក់កណ្តាលនៃសំណួរ គឺ 43 ភាគរយក្នុងឆ្នាំ 2013, 48 ភាគរយក្នុងឆ្នាំ 2016 និង 38 ភាគរយនៅឆ្នាំ 2021 (រូបភាព S.17)។ ការចុះខ្សោយនៃលទ្ធផលប្រឡងឆ្នាំ 2021 គឺដោយសារតែផលប៉ះពាល់អវិជ្ជមាននៃការរាតត្បាតនៃជំងឺកូវីដ-19។ ដូចគ្នានេះដែរ សិស្សថ្នាក់ទី 8 ចំនួន 36 ភាគរយ 19 ភាគរយ និង 52 ភាគរយមានកម្រិតចំណេះដឹងទាបជាងកម្រិតមូលដ្ឋានសម្រាប់គណិតវិទ្យា ការអានភាសាខ្មែរ និងរូបវិទ្យារៀងគ្នា ក្នុងឆ្នាំ 2017 (រូបភាព S.18)។

រូបភាព S.17 លទ្ធផលសិក្សាសម្រាប់ថ្នាក់ទី 6 ឆ្នាំ 2013-21

ភាគរយនៃសំណួរដែលបានឆ្លើយត្រឹមត្រូវ។




**ប្រភព៖** ក្រសួងអប់រំ យុវជន និងកីឡា
**សម្គាល់៖** ពិន្ទុដែលបានធ្វើមាត្រដ្ឋានត្រូវបានបំប្លែងដោយប្រើមធ្យមភាគ 500 និងគម្លាតស្តង់ដារ 100 ។

រូបភាព S.18 ភាគរយនៃសិស្សថ្នាក់ទី 8 ដែលស្ទាត់ជំនាញក្នុងការអាន និងគណិតវិទ្យាជាភាសាខ្មែរ ឆ្នាំ 2014-17

**ផ្ទាំង ក** ចំណេះដឹងគណិតវិទ្យារបស់សិស្សថ្នាក់ទី 8




**ផ្ទាំង ខ** ចំណេះដឹងការអានភាសាខ្មែរសិស្សថ្នាក់ទី 8




**ផ្ទាំង គ** ចំណេះដឹងរូបវិទ្យារបស់សិស្សថ្នាក់ទី 8




**ប្រភព៖** ក្រសួងអប់រំ យុវជន និងកីឡា
**សម្គាល់៖** ពិន្ទុដែលបានធ្វើមាត្រដ្ឋានត្រូវបានបំប្លែងដោយប្រើមធ្យមភាគ 500 និងគម្លាតស្តង់ដារ 100 ។

**ការសិក្សាលើបទពិសោធន៍របស់កម្ពុជាក្នុងកម្មវិធីវាយតម្លៃសិស្សអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍ (PISA-D) បានរកឃើញថាលទ្ធផលសិក្សារបស់សិស្សនៅកម្ពុជាមិនទាន់ឈានដល់កម្រិតតាមការរំពឹងទុកនៅឡើយទេ។** ភាគរយទាបនៃសិស្សកម្ពុជានៅអាយុ 15 ឆ្នាំសម្រេចបានកម្រិតចំណេះដឹងអប្បបរមាគឺ 8 ភាគរយលើការអាន និង 10 ភាគរយលើគណិតវិទ្យា។ សិស្សក្នុងប្រទេសកម្ពុជាបានធ្វើបានពិន្ទុទាបជាងមធ្យមសម្រាប់ប្រទេសអាស៊ានដែលចូលរួមធ្វើតេស្តផ្សេងទៀត (ឥណ្ឌូនេស៊ី សិង្ហបុរី ថៃ និងវៀតណាម) ក្នុងវិស័យបីគឺការអាន គណិតវិទ្យា និងវិទ្យាសាស្ត្រ។ ជាមធ្យម កម្ពុជាទទួលបានពិន្ទុ 321 សម្រាប់ការអាន 325 សម្រាប់គណិតវិទ្យា និង 330 សម្រាប់វិទ្យាសាស្ត្រលើតេស្ត PISA-D ដែលទាបជាងពិន្ទុមធ្យមអាស៊ាន 430 សម្រាប់ការអាន 435 សម្រាប់គណិតវិទ្យា និង 439 សម្រាប់វិទ្យាសាស្ត្រ។ ចំនួនសិស្សនៅក្នុងប្រទេសកម្ពុជាដែលមានសមត្ថភាពក្នុងការប្រឡងកំរិតសមត្ថភាពមធ្យមនៃបណ្តាប្រទេស OECD មានចំនួនតិចជាង ២ ភាគរយ នៃចំនួនសិស្សសរុបនៅក្នុងប្រទេសកម្ពុជា។ ក្នុងការអានពួកគេបានលទ្ធផលទាបជាងមធ្យមភាគតេស្ត PISA-D យ៉ាងខ្លាំង (346 ពិន្ទុ ) ។ [25]

## ប្រសិទ្ធភាពនៃគោលនយោបាយសុខភាពសាធារណៈត្រូវបានរឹតត្បិតដោយការចំណាយទាបលើសុខភាពសាធារណៈ អត្រានៃការប្រើប្រាស់មណ្ឌលសុខាភិបាលសាធារណៈទាប និងកម្រិតខ្ពស់នៃការចំណាយលុយហោប៉ៅ

**ជារួម ការចំណាយលើសុខភាពសាធារណៈត្រូវបានផ្តោតជាច្រើនទៅលើកិច្ចការរដ្ឋបាលសុខភាពសាធារណៈ ឱសថបរិក្ខារពេទ្យ និងឧបករណ៍វេជ្ជសាស្ត្រ និងតម្រូវការផ្សេងទៀតសម្រាប់សេវាជួរមុខ ដើម្បីរក្សាមណ្ឌលសុខាភិបាលសាធារណៈឱ្យដំណើរការ។** ការប្រើប្រាស់បរិក្ខារសាធារណៈទាមទារថ្លៃសេវាអ្នកប្រើប្រាស់។ មួយផ្នែកនៃមូលនិធិសាធារណៈក៏ផ្តល់ហិរញ្ញប្បទានដល់មូលនិធិសមធម៌សុខភាពសម្រាប់ជនក្រីក្រក្នុងការទទួលបានសេវាសាធារណៈផងដែរ។

**មុនការរីករាលដាលនៃជំងឺកូវីដ-19 ចំណែកថវិការបស់ក្រសួងសុខាភិបាលបានថយចុះជាបណ្តើរៗ ពី 8.6 ភាគរយនៃថវិការដ្ឋសរុបក្នុងឆ្នាំ 2017 មក 7 ភាគរយនៅឆ្នាំ 2020។** ទោះជាយ៉ាងណាក៏ដោយ ដើម្បីឆ្លើយតបនឹងការរាតត្បាតនៃជំងឺ ធនធានសាធារណៈដែលបានបែងចែកទៅក្រសួង បានកើនឡើង 58 ភាគរយ ពី 1,729,987 លានរៀល (1.9 ភាគរយនៃ ផ.ស.ស.) ក្នុងឆ្នាំ 2017 ដល់ 2,724,907 លានរៀល (2.5 ភាគរយនៃ ផ.ស.ស.) ក្នុងឆ្នាំ 2021 (រូបភាព S.19)។

**ការចំណាយមូលធនរបស់ក្រសួងសុខាភិបាល ទទួលបានជំនួយថវិកាជាធំពីហិរញ្ញប្បទាននៃមូលនិធិរបស់ដៃគូអភិវឌ្ឍន៍។** រវាងឆ្នាំ 2017 និង 2022 ការបែងចែកការវិនិយោគមូលធនរបស់រដ្ឋាភិបាលដែលបានគ្រោងទុក ជាចំណែកនៃថវិកាសរុបមានចំនួន 4 ភាគរយ ឬតិចជាងនេះ លើកលែងតែនៅឆ្នាំ 2021 នៅពេលដែលការចំណាយមូលធនរបស់រដ្ឋាភិបាលដែលបានគ្រោងទុកឈានដល់ 18 ភាគរយ (រូបភាព S.20) ដែលជាផ្នែកនៃការឆ្លើយតបទូលំទូលាយទៅនឹងវិបត្តិកូវីដ-19 ។ ហិរញ្ញវត្ថុសម្រាប់ការចំណាយមូលធនភាគច្រើនបានមកពីមូលនិធិខាងក្រៅ (ដៃគូអភិវឌ្ឍន៍)។

រូបភាព S.19 ការចំណាយថវិការបស់ក្រសួងសុខាភិបាល ឆ្នាំ 2017-22




រូបភាព S.20 ថវិកាក្រសួងសុខាភិបាល តាមប្រភេទ (% នៃថវិកាសរុប) ឆ្នាំ 2017-22




**ប្រភព៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបុគ្គលិកធនាគារពិភពលោក

**សម្គាល់៖** MoH = ក្រសួងសុខាភិបាល; MEF = ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ; KHR = ប្រាក់រៀលខ្មែរ។ ថវិកាចំណាយចរន្តរួមមានការចំណាយក្រៅពីហេដ្ឋារចនាសម្ព័ន្ធដូចជា ប្រាក់ឈ្នួល ឱសថ បរិក្ខាពេទ្យ និងការចំណាយប្រតិបត្តិការផ្សេងទៀត។ ថវិកាចំណាយមូលធនត្រូវបានប្រើប្រាស់ដើម្បីទទួលបានទ្រព្យសកម្មថេរផ្នែកហេដ្ឋារចនាសម្ព័ន្ធ ដូចជាមន្ទីរពេទ្យ ឬអគារមណ្ឌលសុខភាព។

25 ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ 2018 ។

**កំណើនថវិការជាប្រចាំរបស់ក្រសួងសុខាភិបាលក្នុងលក្ខខណ្ឌមធ្យម រវាងឆ្នាំ 2017 និង 2021 ត្រូវបានជំរុញដោយការចំណាយអត្ថប្រយោជន៍សង្គម និងប្រាក់បៀវត្សរ៍ [26] (រូបភាព S.21) ។** ការចំណាយលើអត្ថប្រយោជន៍សង្គម (ជំពូក 62) គាំទ្រដល់ការផ្តល់សេវាសុខភាព និងរួមបញ្ចូលការចំណាយលើអ្នកជំងឺ និងប្រតិបត្តិការនៅមូលដ្ឋានសុខាភិបាល ការទិញឱសថ និងការផ្គត់ផ្គង់សម្ភារៈវេជ្ជសាស្រ្ត (ប្រអប់ 2)។ ចន្លោះឆ្នាំ 2017 និង 2021 ថវិកាសម្រាប់ការចំណាយជាមធ្យមលើអត្ថប្រយោជន៍សង្គម (ជំពូក 62) បានកើនឡើង 71 ភាគរយ - ពី 469,459 លានរៀល (0.5 ភាគរយនៃ ផ.ស.ស.) ដល់ 801,031 លានរៀល (0.7 ភាគរយនៃ ផ.ស.ស.) ដែលជំរុញដោយការកើនឡើងនៃប្រាក់ឧបត្ថម្ភសម្រាប់វិស័យក្រៅផ្លូវការ។ វិស័យមូលនិធិសមធម៌សុខភាព (ជំពូក 62028) និងការចំណាយលើថ្នាំ (ជំពូក 62022)។ ចំណាយមូលធនដោយប្រើហិរញ្ញបទានក្នុងស្រុកដែលបានគ្រោងទុក (ជំពូក 21) មានកម្រិតតិចតួចក្នុងឆ្នាំ 2017 (1,199 លានរៀល ឬ 0.001 ភាគរយនៃ ផ.ស.ស.) ដោយកើនឡើងនៅឆ្នាំ 2020 (20,370 លានរៀល ឬ 0.01 ភាគរយនៃ ផ.ស.ស.) (រូបភាព S.22 និងប្រអប់ S.1) ។

រូបភាព S.21 ថវិកាជាប្រចាំរបស់ក្រសួងសុខាភិបាល តាមចំណាត់ថ្នាក់សេដ្ឋកិច្ច (លានរៀល) ឆ្នាំ 2017-21




**ប្រភព៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**សម្គាល់៖** MEF = ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការចំណាយជាក់ស្តែងលើជំងឺកូវីដ-19 មិនត្រូវបានរាប់បញ្ចូលក្នុងការចំណាយអត្ថប្រយោជន៍សង្គមទេ ( ជំពូក 62 )

រូបភាព S.22 ថវិការបស់ក្រសួងសុខាភិបាលលើការចំណាយអត្ថប្រយោជន៍សង្គម តាមចំណាត់ថ្នាក់សេដ្ឋកិច្ច (លានរៀល) ឆ្នាំ 2017-21




**ប្រភព៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **សម្គាល់៖** MEF = ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ; KHR = ប្រាក់រៀល ការចំណាយជាប្រចាំជាក់ស្តែងគឺផ្អែកលើទិន្នន័យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមិនរាប់បញ្ចូលការចំណាយលើបញ្ជីប្រាក់បៀវត្សរ៍នៅថ្នាក់ខេត្តក្នុងឆ្នាំ 2021។ ការចំណាយជាក់ស្តែងលើជំងឺកូវីដ-19 មិនត្រូវបានរាប់បញ្ចូលក្នុងការចំណាយអត្ថប្រយោជន៍សង្គមផ្សេងទៀតទេ។ ( ជំពូក 62028 )

### ប្រអប់ S.1. ការចំណាយក្រោមជំពូក 62 (ការចំណាយអត្ថប្រយោជន៍សង្គម)

**ជំពូក 62021 (ការគាំទ្រអ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ និងការចំណាយប្រតិបត្តិការសម្រាប់មណ្ឌលសុខភាព)៖** ជំពូកនេះគ្របដណ្តប់លើការចំណាយទាក់ទងនឹង (i) ការចំណាយប្រតិបត្តិការ (ទឹក ភ្លើង ទូរស័ព្ទ សម្ភារៈការិយាល័យ និងចំណាយផ្សេងៗ) (ii) ការចំណាយរបស់រដ្ឋាភិបាលលើមូលនិធិសមធម៌សុខភាព និង (iii) វិភាគទានដល់មូលនិធិគន្ធបុប្ផា។

**ជំពូក 62022 (ថ្នាំពេទ្យ)៖** ការចំណាយក្នុងជំពូកនេះរួមមានថ្នាំពេទ្យ អុកស៊ីហ្សែន អាល់កុល និងវ៉ាក់សាំង។

**ជំពូក 62023 (អាហារ និងសម្ភារៈ)៖** ឧបត្ថម្ភធនដល់អ្នកបរិច្ចាគឈាម អាហារសម្រាប់អ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ អាហារសម្រាប់ទារកទើបនឹងកើតនៅមជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារកក្រណាត់សុវត្ថិភាព ។ល។

**ជំពូក 62028 (ការចំណាយលើអត្ថប្រយោជន៍សង្គមផ្សេងទៀត)៖** ឧបត្ថម្ភធនដល់បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់កម្មការិនីដែលកំពុងសម្រាលកូននៅមណ្ឌលសុខភាព ឧបត្ថម្ភធនដល់បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីចូលនិវត្តន៍ ឧបត្ថម្ភធនដល់ស្ត្រីមានផ្ទៃពោះក្រីក្រ និងទារកអាយុក្រោម 2 ឆ្នាំ ការចំណាយរបស់រដ្ឋាភិបាលលើមូលនិធិសមធម៌សុខភាពវិស័យក្រៅប្រព័ន្ធ។

**សម្គាល់៖** ជំពូក 62028 បានដកការចំណាយលើការប្រយុទ្ធប្រឆាំងនឹងមេរោគ កូវីដ-19 ចេញពីចំណាយវិស័យសុខភិបាលទូទៅរបស់ក្រសួងសុខាភិបាល ។ HEF = មូលនិធិសមធម៌សុខភាព;
MoH = ក្រសួងសុខាភិបាល; ប.ស.ស = បេឡាជាតិរបបសន្តិសុខសង្គម។

26 ការចំណាយលើអត្ថប្រយោជន៍សង្គម (ជំពូក 62) រួមមានការចំណាយលើការធ្វើដំណើររបស់អ្នកជំងឺទៅមណ្ឌលសុខភាព ការចំណាយលើការទិញថ្នាំពេទ្យ និងសម្ភារៈវេជ្ជសាស្រ្ត។

**ការចំណាយលើការគ្រប់គ្រងប្រព័ន្ធសុខាភិបាលនៅតែមានកម្រិតខ្ពស់បើធៀបនឹងប្រទេសអាស៊ានដទៃទៀត ខណៈដែលការចំណាយលើការផ្តល់សេវាសុខភាព (ជាពិសេសការថែទាំបង្ការ) នៅតែមានកម្រិតទាប បើគិតជាភាគរយនៃការចំណាយសាធារណៈសរុប។** ក្នុងឆ្នាំ 2019 ការចំណាយរបស់កម្ពុជាលើការគ្រប់គ្រងប្រព័ន្ធសុខាភិបាល គិតជាភាគរយនៃការចំណាយផ្នែកសុខភាពរបស់រដ្ឋាភិបាល (34.5 ភាគរយ) ខ្ពស់ជាងប្រទេសមីយ៉ាន់ម៉ា 2 ដង ខ្ពស់ជាងប្រទេសវៀតណាម 4 ដង និងខ្ពស់ជាងប្រទេសថៃ និង ម៉ាឡេស៊ីជិត 3 ដង (រូបភាព S.23)។ គិតភាគរយនៃចំណាយផ្នែកសុខភាពរបស់រដ្ឋាភិបាល ចំណាយសាធារណៈរបស់កម្ពុជាលើការថែទាំព្យាបាល (61.9 ភាគរយ) គឺទាបបំផុតទីពីរ លើតែប្រទេសឡាវ ហើយទាបជាងមីយ៉ាន់ម៉ា (65.5 ភាគរយ) វៀតណាម (84.4 ភាគរយ) ថៃ (74.6 ភាគរយ) និងម៉ាឡេស៊ី (75.9 ភាគរយ)។ នៅពេលដែលការចំណាយលើការថែទាំបង្ការត្រូវបានវាស់វែងជាភាគរយនៃការចំណាយផ្នែកសុខាភិបាលរបស់រដ្ឋាភិបាលប្រទេសកម្ពុជាមានកម្រិតទាបបំផុត។ ភាគរយនៃការចំណាយរបស់រដ្ឋាភិបាលលើការថែទាំបង្ការគឺទាបបំផុតក្នុងចំណោមប្រទេសដែលបានប្រៀបធៀប។ ដូច្នេះហើយគួរតែមានការផ្លាស់ប្តូរឆ្ពោះទៅរកការផ្តល់អាទិភាពខ្ពស់ទៅដល់ការផ្តល់សេវាថែទាំបង្ការ រួមទាំងដាក់ចេញនូវគោលនយោបាយដើម្បីបង្កើនវិធានការបង្ការតាមគោលដៅស្របតាមគោលដៅជាក់លាក់ ជាពិសេសក្នុងផ្នែកណាដែលមានការចំណាយលើសុខមាលភាពមានកម្រិតខ្ពស់ និងបង្កើតយន្តការសម្រាប់លើកទឹកចិត្តប្រជាជនក្នុងការស្វែងរកសេវាថែទាំបង្ការ។

**ការប្រើប្រាស់សេវាថែទាំសុខភាពដែលផ្តល់ដោយមណ្ឌលសុខាភិបាលសាធារណៈមានកម្រិតទាប (រូបភាព S.24) ។** នៅឆ្នាំ 2021 សមាជិកគ្រួសារដែលបានស្វែងរកសេវាសុខភាពសម្រាប់ព្យាបាលជំងឺ និងរបួសពីមណ្ឌលសុខភាពឯកជន ក្នុងរយៈពេល 30 ថ្ងៃចុងក្រោយមានចំនួនច្រើនជាង 3/4 នៃសមាជិកគ្រួសារសរុបដែលបានស្តង់មតិ។ 15.3 ភាគរយ បានស្វែងរកសេវាសុខភាពពីអ្នកផ្តល់សេវាថែទាំសុខភាពសាធារណៈ 8.4 ភាគរយពីអ្នកផ្តល់សេវាមិនវិជ្ជសាស្ត្រ និង 0.2 ភាគរយស្វែងរកការថែទាំសុខភាពនៅក្រៅប្រទេស។ កម្រិតទាបនៃការប្រើប្រាស់សេវាសុខភាពសាធារណៈមានន័យថាចំណាយសាធារណៈមិនទាន់សម្រេចបាននូវសក្តានុពលពេញលេញនោះទេ។

រូបភាព S.23 ការចំណាយលើវិស័យសុខាភិបាលរបស់កម្ពុជាធៀបនឹងបណ្តាប្រទេសអាស៊ានផ្សេងទៀត តាមមុខងារថែទាំសុខភាព (% ការចំណាយលើវិស័យសុខាភិបាលរបស់រដ្ឋាភិបាល) ឆ្នាំ 2019




**ប្រភព៖** អង្គការសុខភាពពិភពលោក-ការចំណាយលើសុខភាពសកល (2022) និងបុគ្គលិកធនាគារពិភពលោក

**សម្គាល់៖** MoH = ក្រសួងសុខាភិបាល ការចំណាយវិស័យសុខាភិបាលរបស់រដ្ឋាភិបាលពីឆ្នាំ 2016 ដល់ឆ្នាំ 2019 (ក្រាហ្វិក) គឺជាតម្លៃមធ្យមដែលបានកែសម្រួលតាមអំណាចទិញ PPP ។ ការថែទាំសុខភាពផ្សេងទៀតរួមមាន ការថែទាំស្តារនីតិសម្បទា ការថែទាំសុខភាពរយៈពេលវែង សេវាបន្ថែម សម្ភារៈវេជ្ជសាស្ត្រ និងសេវាថែទាំសុខភាពផ្សេងទៀត។

រូបភាព S.24 ប្រភេទអ្នកផ្តល់សេវាសុខភាពដែលបានពិគ្រោះយោបល់ជាមុន




**ប្រភព៖** របាយការណ៍ព្រាង ៖ *ការវិភាគលើការការពារហានិភ័យហិរញ្ញវត្ថុក្នុងប្រព័ន្ធសុខាភិបាលកម្ពុជាដោយប្រើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ទិន្នន័យ ឆ្នាំ 2009-2021*។ អង្គការ GIZ ( 2023, ខាងមុខ)

*ជម្រើសសម្រាប់ការព្យាបាលនៅក្រៅប្រទេសមិនត្រូវបានរួមបញ្ចូលនៅក្នុងទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ 2009 ទេ។

**កម្ពុជាចំណាយលើការវិស័យសុខាភិបាលច្រើនជាងប្រទេសជិតខាងទាំងអស់ ទោះបីជាការចំណាយរបស់រដ្ឋាភិបាលមានកម្រិតទាបក៏ដោយ។** កម្ពុជាបានចំណាយច្រើនជាង 5.7 ភាគរយនៃ ផ.ស.ស. របស់ខ្លួនលើវិស័យសុខាភិបាលឆ្នាំ 2009 ដល់ឆ្នាំ 2019 ដែលខ្ពស់ជាងប្រទេសជិតខាងអាស៊ានទាំងអស់ក្នុងរយៈពេលជាងមួយទសវត្សរ៍ (រូបភាព S.25)។ កម្រិតនៃការចំណាយនេះនៅតែបន្តកើតមាន ទោះបីជាចំណាយរបស់រដ្ឋាភិបាលលើវិស័យសុខាភិបាលទាំងក្នុងលក្ខខណ្ឌសម្រាប់មនុស្សម្នាក់ៗ (រូបភាព S.26) និងជាភាគរយនៃថវិការដ្ឋាភិបាល (រូបភាព S.27) មានកម្រិតទាបក៏ដោយ ដែលលក្ខខណ្ឌទាំងពីរទាបជាងប្រទេសជិតស្ទើរតែទាំងអស់នៅក្នុងតំបន់។ នេះមានន័យថាចំណាយដែលនៅសល់ត្រូវបានផ្គត់ផ្គង់ដោយផ្តល់ហិរញ្ញប្បទានពីខាងក្រៅ (ដៃគូអភិវឌ្ឍន៍) និងការចំណាយលុយចេញពីហោប៉ៅផ្ទាល់ខ្លួន។

រូបភាព S.25 ចំណាយវិស័យសុខាភិបាល (% នៃ ផ.ស.ស.)




**ប្រភព៖** សូចនាករអភិវឌ្ឍន៍ពិភពលោក

រូបភាព S.26 ចំណាយវិស័យសុខាភិបាលទូទៅរបស់រដ្ឋាភិបាលក្នុងមនុស្សម្នាក់, អំណាចទិញ (ដុល្លារអន្តរជាតិបច្ចុប្បន្ន)




**ប្រភព៖** សូចនាករអភិវឌ្ឍន៍ពិភពលោក

រូបភាព S.27 ចំណាយវិស័យសុខាភិបាលទូទៅរបស់រដ្ឋាភិបាលក្នុងស្រុក (% នៃការចំណាយរបស់រដ្ឋាភិបាលទូទៅ)




**ប្រភព៖** សូចនាករអភិវឌ្ឍន៍ពិភពលោក

**បរិមាណហិរញ្ញប្បទានវិស័យសុខាភិបាលនៅកម្ពុជា គឺស្រប ទៅនឹងអ្វីដែលប្រទេសផ្សេងទៀតកំពុងចំណាយ គឺក្នុងកម្រិត ប្រាក់ចំណូលស្រដៀងគ្នា ប៉ុន្តែសមាសភាពនៃហិរញ្ញប្បទានលើ វិស័យសុខាភិបាលនេះគឺពឹងផ្អែកខ្លាំងពេកលើការចំណាយលុយ ចេញពីហោប៉ៅផ្ទាល់ខ្លួន។** ការចំណាយលុយហោប៉ៅមិនមែនជា មធ្យោបាយដ៏មានប្រសិទ្ធភាព ឬសមធម៌ ដើម្បីសម្រេចបាននូវ ការផ្តល់សេវាសុខភាពជាសកលនោះទេ។ ចំណាយវិស័យសុខា ភិបាលសរុបសម្រាប់មនុស្សម្នាក់បានកើនឡើងក្នុងលក្ខខណ្ឌ ជាក់ស្តែងពីប្រហែល 35 ដុល្លារក្នុងមួយឆ្នាំក្នុងឆ្នាំ 2000 ដល់ ប្រហែល 115 ដុល្លារក្នុងឆ្នាំ 2020។ ប្រទេសដែលផ្លាស់ប្តូរពី ស្ថានភាពប្រទេសចំណូលទាបទៅមធ្យម ជាធម្មតាក៏សម្រេចបាននូវ ការផ្លាស់ប្តូរហិរញ្ញប្បទានសុខភាពដែរ នាពេលដែល (i) បរិមាណ ហិរញ្ញប្បទានដែលបានវិនិយោគទៅលើវិស័យសុខាភិបាលបានកើន ឡើង និង (ii) សមាសភាពនៃការផ្លាស់ប្តូរមូលនិធិសុខភាពពី ការពឹងផ្អែកលើហិរញ្ញប្បទានខាងក្រៅ និងការពឹងផ្អែកលើចំណាយ លុយហោប៉ៅ ទៅយន្តការបង់ថ្លៃជាមុនឱ្យបានច្រើនលើសលុប ដូចជាការផ្តល់ហិរញ្ញប្បទានសុខភាពសាធារណៈ ឬទម្រង់នៃការ ធានារ៉ាប់រងសុខភាពមួយចំនួន។ ទោះជាយ៉ាងណាក៏ដោយ នៅ កម្ពុជា ខណៈពេលដែលចំណែកនៃហិរញ្ញប្បទានពីខាងក្រៅបាន ថយចុះចាប់តាំងពីឆ្នាំ 2015 មក ការចំណាយលុយចេញពី ហោប៉ៅផ្ទាល់ខ្លួន នៅតែជាប្រភពហិរញ្ញប្បទានចម្បងសម្រាប់ វិស័យនេះ (រូបភាព 28 ផ្ទាំង ក) ហើយចំណែកនៃហិរញ្ញប្បទានពី លុយហោប៉ៅ (60 ភាគរយក្នុងឆ្នាំ 2020) គឺលើសពីអ្វីដែល ត្រូវ បានគេសង្កេតឃើញជាមធ្យមសម្រាប់ប្រទេសដែលមានកម្រិត ប្រាក់ចំណូលស្រដៀងគ្នា (ប្រហែល 30 ភាគរយ) (រូបភាព S.28, ផ្ទាំង ខ) ។

**ការចំណាយលុយចេញពីហោប៉ៅផ្ទាល់ខ្លួនខ្ពស់មានន័យថា ជនក្រីក្រងាយរងគ្រោះនឹងវិបត្តិប្រាក់ចំណូល និងមិនសូវមាន លទ្ធភាពទទួលបានសេវាសុខភាព។** ក្នុងឆ្នាំ 2013 ក្រុមប្រជាជន ដែលមានមានប្រាក់ចំណូលខ្ពស់បំផុត (អ្នកមានបំផុត) បាន ចំណាយ 16 ដងលើការថែទាំសុខភាពច្រើនជាងក្រុមអ្នកមាន ប្រាក់ចំណូលទាបបំផុត (អ្នកក្រីក្របំផុត) ដោយពួកគេមានលទ្ធភាព កាន់តែច្រើនក្នុងការចំណាយលើសេវាថែទាំសុខភាព ឬមានថវិកា ច្រើនសម្រាប់ប្រើប្រាស់ ដែលមិនមែនសម្រាប់ម្ហូបអាហារ។[27]

រូបភាព S.28 ហិរញ្ញប្បទានសុខភាពកម្ពុជា និងការពឹងផ្អែកលើការចំណាយលុយចេញពីហោប៉ៅផ្ទាល់ខ្លួន ឆ្នាំ 2000-20

**ផ្ទាំង ក** បរិមាណហិរញ្ញប្បទានសុខភាព

**ផ្ទាំង ខ** ការពឹងផ្អែកខ្លាំងលើលុយហោប៉ៅផ្ទាល់ខ្លួន




27 WHO 2015

**នៅពីក្រោយការធ្លាក់ចុះថវិកាក្រសួងសុខាភិបាល (មិនទាក់ទងទៅនឹងវិបត្តិកូវីដ-19) ការប្រើប្រាស់មណ្ឌលសុខាភិបាលសាធារណៈទាប និងការពេញចិត្តខ្លាំងនឹងសេវាឯកជន ដែលរួមចំណែកការចំណាយលុយចេញពីហោប៉ៅផ្ទាល់ខ្លួនខ្ពស់ ប្រទេសកម្ពុជាមាន លទ្ធផលសុខភាពប្រសើរឡើងក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។** ប្រទេសកម្ពុជាបានឃើញការកើនឡើងយ៉ាងខ្លាំងនៃការផ្ដត់ផ្ដង់វ៉ាក់សាំង និងការធ្លាក់ចុះនៃចំនួនកុមារដែលមិនបានចាក់វ៉ាក់សាំង (រូបភាព S.29 ផ្ទាំង ក)។ ក៏មានការថយចុះខ្លាំងនៃមរណភាពកុមារផងដែរ ដោយអត្រាមរណភាពកុមារអាយុក្រោម 5 ឆ្នាំបានធ្លាក់ចុះពី 124 ក្នុង 1,000 កំណើតក្នុងឆ្នាំ 2000 មក 16 នៅក្នុងការស្ទង់មតិសុខភាព ឆ្នាំ 2021-22 (រូបភាព S.29, ផ្ទាំង ខ) ។

**ទោះបីមានការប្រសើរឡើងនៃលទ្ធផលសុខភាពក៏ដោយ ក៏អត្រាសង្ឃឹមរស់ និងអត្រាមរណភាពកុមារនៃនៅមានលក្ខណៈឃើតជាងបណ្ដាប្រទេសអាស៊ានភាគច្រើនក្នុង។** (រូបភាព S.30 ផ្ទាំង A និង B) ។ ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ អាយុសង្ឃឹមរស់បានកើនឡើងពី 57 ឆ្នាំក្នុងឆ្នាំ 2010 ដល់ 68 ឆ្នាំក្នុងឆ្នាំ 2019 ។ ទោះជាយ៉ាងណាក៏ដោយ អាយុសង្ឃឹមរស់របស់កម្ពុជាគឺខ្ពស់ជាងតែប្រទេសឡាវ តែទាបជាងប្រទេសដទៃទៀតក្នុងអាស៊ាន។ លើសពីនេះ អត្រាមរណភាពទារក និងកុមារអាយុក្រោម 5ឆ្នាំ របស់កម្ពុជា គឺខ្ពស់ជាងនៅប្រទេសថៃប្រហែលបីដងនិងខ្ពស់ជាងប្រទេសវៀតណាមជាង 30 ភាគរយ។

រូបភាព S.29 និន្នាការនៃការផ្ដត់ផ្ដង់វ៉ាក់សាំង និងមរណភាពកុមារ

**ផ្ទាំង ក** ការផ្ដត់ផ្ដង់វ៉ាក់សាំងឆ្នាំ 2000-2021/22




**ផ្ទាំង ខ** អត្រាមរណភាពកុមារ ឆ្នាំ 2000-2021/22




**ប្រភព៖** ការស្ទង់មតិប្រជាសាស្ត្រ និងសុខភាពកម្ពុជា ( CDHS ) ឆ្នាំ 2021-22 របាយការណ៍សូចនាករគន្លឹះ ខែមិថុនា ឆ្នាំ 2022។

រូបភាព S.30 អាយុសង្ឃឹមរស់ និងអត្រាមរណៈរបស់កុមារប្រទេសកម្ពុជាធៀបនឹងបណ្ដាប្រទេសអាស៊ាន

**ផ្ទាំង ក** អាយុសង្ឃឹមរស់ធៀបនឹងបណ្ដាប្រទេសក្នុងតំបន់




**ផ្ទាំង ខ** មរណភាពកុមារធៀបនឹងប្រទេសក្នុងតំបន់ ឆ្នាំ 2020




**ប្រភព៖** សូចនាករអភិវឌ្ឍន៍របស់ធនាគារពិភពលោកឆ្នាំ 2022 ។

**ភាពខុសគ្នានៃលទ្ធផលសុខភាពរវាងតំបន់ជនបទ និងទីក្រុង និងក្នុងចំណោមក្រុមអ្នកមានធនធានទំនងជានៅតែជាបញ្ហាប្រឈម។** នៅចន្លោះឆ្នាំ 2005 និង 2021 អត្រាមរណភាពទារក និងកុមារអាយុក្រោម 5 ឆ្នាំសម្រាប់ទីក្រុង និងតំបន់ជនបទបានធ្លាក់ចុះយ៉ាងខ្លាំង ប៉ុន្តែគម្លាតរវាងតំបន់ទីក្រុង និងជនបទនៅតែមាន។ មរណភាពទារក និងកុមារអាយុក្រោម 5 ឆ្នាំនៅតំបន់ជនបទរៀងគ្នា គឺការស្លាប់ 7 នាក់ និង 9 នាក់ក្នុង 1,000 កំណើតរស់ ហើយក៏ខ្ពស់ជាងនៅតំបន់ទីក្រុង នៅឆ្នាំ 2021 ផងដែរ (រូបភាព S.31)។ គម្លាតរវាងអ្នកមានបំផុត និងអ្នកក្រីក្របំផុតក្នុងអត្រាមរណភាពទារក និងកុមារអាយុក្រោម 5 ឆ្នាំ ក៏បានធ្លាក់ចុះផងដែរ ក្នុងអំឡុងពេលដូចគ្នានេះ។ ទោះជាយ៉ាងណាក៏ដោយ គម្លាតរវាងអ្នកក្របំផុត និងអ្នកមានបំផុតក្នុងអត្រាមរណភាពទារក និងកុមារអាយុក្រោម 5 ឆ្នាំនៅតែមាន។ នៅឆ្នាំ 2021 អត្រាមរណភាពទារកក្រីក្របំផុត និងកុមារអាយុក្រោម 5 ឆ្នាំរៀងគ្នា គឺ ស្លាប់ 16 នាក់ និងការស្លាប់ 21 នាក់ក្នុង 1,000 កំណើតរស់ ហើយខ្ពស់ជាងអត្រាមរណភាពទារកក្នុងគ្រួសារអ្នកមានបំផុត និងអត្រាមរណភាពកុមារអាយុក្រោម 5 ឆ្នាំ (រូបភាព S.32) ។ ប៉ុន្តែបញ្ហាកង្វះទិន្នន័យបានធ្វើអោយការកំណត់គោលដៅគុណភាពមានការលំបាក ហើយក៏រារាំងការរួមបញ្ចូលទិន្នន័យលទ្ធផលសុខភាពដែលមានបច្ចុប្បន្នភាពបន្ថែមទៀត ក៏ដូចជាទិន្នន័យនៅថ្នាក់ស្រុក និងឃុំ ដើម្បីវាយតម្លៃសមធម៌នៃការទទួលសេវាក្នុងខេត្ត។

**រូបភាព S.31** អត្រាមរណភាពទារក និងកុមារអាយុក្រោម 5 ឆ្នាំ ទីក្រុងធៀបនឹងជនបទ

**ផ្ទាំង ក** អត្រាមរណៈភាពទារក និងកុមារក្រោមអាយុ 5 ឆ្នាំ តាមតំបន់លំនៅដ្ឋាន (ការស្លាប់ក្នុង 1,000 កំណើតរស់) ឆ្នាំ 2014-2021/22




**ផ្ទាំង ខ** គម្លាតនៃមរណភាពកុមារ ទារក និងកុមារអាយុក្រោម 5 ឆ្នាំ រវាងទីក្រុង និងជនបទ (ការស្លាប់ក្នុង 1,000 កំណើតរស់) ឆ្នាំ 2005-2021/22




**ប្រភព៖** CDHS 2005, CDHS 2010, CDHS 2014, CDHS 2021-22

**សម្គាល់៖** CDHS=ការស្ទង់មតិប្រជាសាស្ត្រ និងសុខភាពកម្ពុជា អត្រាមរណភាពទារក៖ លទ្ធភាពនៃការស្លាប់រវាងថ្ងៃកំណើត និងអាយុមួយឆ្នាំ។ មរណភាពកុមារអាយុក្រោម 5ឆ្នាំ៖ លទ្ធភាពនៃការស្លាប់រវាងកំណើត និងអាយុមួយឆ្នាំ។ គម្លាតមរណភាពកុមារ=អត្រាមរណៈនៅជនបទ - អត្រាមរណៈក្នុងទីក្រុង។ តួលេខកាន់តែខ្ពស់ គម្លាតកាន់តែធំ។

**រូបភាព S.32** អត្រាមរណៈទារក និងកុមារអាយុក្រោម 5 ឆ្នាំ អ្នកមានបំផុតធៀបនឹងអ្នកក្រីក្របំផុត

**ផ្ទាំង ក** អត្រាមរណភាពទារក និងកុមារក្រោមអាយុ 5 ឆ្នាំ ក្រុមអ្នកមាន (ចំនួនអ្នកស្លាប់ក្នុង 1,000 កំណើតរស់) ឆ្នាំ 2014-2021/22




**ផ្ទាំង ខ** គម្លាតនៃមរណភាពកុមារ ទារក និងកុមារអាយុក្រោម 5 ឆ្នាំ រវាងអ្នកក្របំផុត និងអ្នកមានបំផុត (ការស្លាប់ក្នុង 1,000 កំណើតរស់) ឆ្នាំ 2005-2021/22




**ប្រភព៖** CDHS 2005, CDHS 2010, CDHS 2014, CDHS 2021-22

**សម្គាល់៖** CDHS=ការស្ទង់មតិប្រជាសាស្ត្រ និងសុខភាពកម្ពុជា អត្រាមរណភាពទារក៖ លទ្ធភាពនៃការស្លាប់រវាងថ្ងៃកំណើត និងអាយុមួយឆ្នាំ។ មរណភាពកុមារអាយុក្រោម 5ឆ្នាំ៖ លទ្ធភាពនៃការស្លាប់រវាងកំណើត និងអាយុមួយឆ្នាំ។ គម្លាតមរណភាពកុមារ=អត្រាមរណៈនៅជនបទ - អត្រាមរណៈក្នុងទីក្រុង។ តួលេខកាន់តែខ្ពស់ គម្លាតកាន់តែធំ។

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

**រដ្ឋាភិបាលកម្ពុជាអាចពង្រីកលំហសារពើពន្ធ រក្សានិរន្តរភាពសារពើពន្ធ និងបង្កើនការបែងចែកថវិកាដល់វិស័យសង្គមក្នុងប្រទេស។** ដោយសារកំណើននៃការកៀរគរចំណូលក្នុងស្រុក រដ្ឋាភិបាលអាចគាំទ្រកំណែទម្រង់បៀវត្សរ៍មន្ត្រីរាជការ និងផ្តល់ហិរញ្ញប្បទានកញ្ចប់ជំនួយដើម្បីដោះស្រាយវិបត្តិនៃជំងឺកូវីដ-19។

**ការចំណាយលើវិស័យសង្គមបានកើនឡើងយ៉ាងខ្លាំងពី 4.6 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2011 ដល់ 10.5 ភាគរយនៅឆ្នាំ 2021 ខណៈដែលការចំណាយក្នុងវិស័យផ្សេងទៀតមានស្ថិរភាព។** វិស័យសង្គមសំខាន់ៗ រួមទាំងវិស័យអប់រំ និងសុខាភិបាល មានកំណើនខ្ពស់នៃការបែងចែកថវិការ។ ការកើនឡើងនៃការចំណាយគឺជារួមស្របតាមគោលនយោបាយចំណាយរបស់រដ្ឋាភិបាលដែលផ្តល់អាទិភាពដល់វិស័យសង្គម។ នៅគ្រប់វិស័យ ការចំណាយមូលធនពឹងផ្អែកជាចម្បងលើហិរញ្ញប្បទានខាងក្រៅ។ ការផ្តល់ហិរញ្ញប្បទានក្នុងស្រុកបន្ថែមសម្រាប់ថវិកាមូលធន គឺចាំបាច់ ដោយសារហិរញ្ញប្បទានខាងក្រៅសម្រាប់ហេដ្ឋារចនាសម្ព័ន្ធមាននិន្នាការធ្លាក់ចុះ។ ការគ្រប់គ្រងការវិនិយោគសាធារណៈចាំបាច់ត្រូវធ្វើអោយប្រសើរឡើងវិញដើម្បីសម្រេចបាននូវគុណភាពល្អនៃការចំណាយសាធារណៈ។

**ការពង្រីកការចំណាយត្រូវបានជំរុញដោយការដំឡើងប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីរាជការទូទាំងប្រទេសដែលពុំមានការតភ្ជាប់ជាមួយនឹងគុណផលអនុវត្តន៍ការងារ។** ប្រាក់បៀវត្សរ៍ជាចំណែកនៃ ផ.ស.ស. បានកើនឡើងក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះពី 4.4 ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ 2011 ដល់ 7.2 ភាគរយនៅឆ្នាំ 2021 ។ ប្រាក់បៀវត្សរ៍ជាមធ្យមប្រចាំខែក្នុងវិស័យសាធារណៈគឺខ្ពស់ជាងប្រាក់ខែក្នុងវិស័យឯកជន ដែលឈានដល់ 1.50 លានរៀល/ខែ ក្នុងឆ្នាំ 2019 ធៀបនឹង 1.25 លានរៀលសម្រាប់វិស័យឯកជន។ បើគ្មានការវាស់វែងលទ្ធផលការងារនោះទេ ការដំឡើងប្រាក់បៀវត្សរ៍មិនអាចធានាបាននូវសមិទ្ធកម្មការងារប្រសើរជាងមុន ហេតុដូច្នេះ ក៏មិនអាចធានាបាននូវគុណភាពល្អនៃការចំណាយដែរ។

**រដ្ឋាភិបាលចាំបាច់ត្រូវដោះស្រាយគម្លាតប្រាក់បៀវត្សរ៍យេនឌ័រដើម្បីធ្វើឲ្យប្រសើរឡើងវិញនូវសមភាពយេនឌ័រក្នុងកម្លាំងពលកម្ម។** បុគ្គលិកជាស្ត្រីនៅក្នុងវិស័យសាធារណៈទទួលរងនូវគម្លាតប្រាក់ឈ្នួលយេនឌ័រដ៏ធំនៅក្នុងផ្នែកជាច្រើននៃកម្លាំងការងារវិស័យសាធារណៈ។ ស្ត្រីកម្ពុជាទទួលបាន 94 ភាគរយនៃប្រាក់ខែរបស់បុរសនៅក្នុងវិស័យឯកជន និង 89 ភាគរយនៅក្នុងវិស័យសាធារណៈ។

**ការបង្កើនគុណភាពការគ្រប់គ្រងធនធានមនុស្ស និងការដាក់ឱ្យប្រើប្រាស់យន្តការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម និងគណនេយ្យភាពអាចជួយលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពបច្ចេកទេសក្នុងការចំណាយសាធារណៈ។** វិស័យអប់រំនៅតែបន្តទទួលរងវិសមភាពនៃការបែងចែកគ្រូបង្រៀន និងកង្វះសមត្ថភាពក្នុងការដោះស្រាយបញ្ហាការលើសនិងកង្វះខាតគ្រូ ដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពអប់រំ។ បើគ្មានក្របខណ្ឌគណនេយ្យភាពទេ លទ្ធផលសិក្សារបស់សិស្សនឹងកាន់តែធ្លាក់ចុះ បើទោះបីជាប្រាក់បៀវត្សរ៍គ្រូបង្រៀនកើនឡើងគួរឱ្យកត់សម្គាល់ក៏ដោយ។

**ការប្រើប្រាស់មណ្ឌលសុខាភិបាលសាធារណៈមានកម្រិតទាប និងការពេញចិត្តខ្លាំងនូវសេវាឯកជន ដែលរួមចំណែកដល់ការចំណាយចេញពីហោប៉ៅផ្ទាល់ខ្លួនខ្ពស់ ឆ្លុះបញ្ចាំងពីប្រសិទ្ធភាពមានកម្រិតនៃគោលនយោបាយសុខភាពសាធារណៈ និងការយល់ឃើញទូទៅនៃគុណភាពនៃមណ្ឌលសុខាភិបាលសាធារណៈ។** បញ្ហាប្រឈមធំៗសម្រាប់វិស័យនេះរួមមាន (1) គុណភាពសេវាសុខភាពមានកម្រិត ដោយសារធនធានមានកម្រិត ជាពិសេសទាក់ទងនឹងចំនួនអ្នកជំនាញវិជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល (2) សមត្ថភាពនៃប្រព័ន្ធសុខាភិបាលសារធារណៈនៅមានភាពកង្វះខាតជាពិសេសក្នុងការព្យាលបាលរោគនិងជំងឺ (3) ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល រួមទាំងបច្ចេកវិទ្យា និងប្រព័ន្ធព័ត៌មាននៅមានកម្រិត និង (4) អាកប្បកិរិយាស្វែងរកសេវាថែទាំសុខភាពមិនសមស្របរបស់ប្រជាជន ជាពិសេសអ្នកដែលនៅជនបទ ឬតំបន់ដាច់ស្រយាលដែលពន្យារពេលស្វែងរកការថែទាំសុខភាព និងអ្នកដែលប្រើថ្នាំពេទ្យដើម្បីព្យាលបាលខ្លួន។[28]

**ជាការចាំបាច់ ត្រូវតែមានការធ្វើអោយប្រសើរឡើងវិញ នូវគុណភាពនៃការចំណាយ។** លទ្ធផលនៃការចំណាយសាធារណៈទាំងក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល បង្ហាញពីតម្រូវការនៃការកែលម្អបន្ថែមទៀតទាំងប្រសិទ្ធភាពនៃការវិនិយោគ និងគុណភាពនៃលទ្ធផល។ នេះតម្រូវឱ្យមានការយកចិត្តទុកដាក់កាន់តែខ្លាំងលើការពង្រឹងទាំងប្រសិទ្ធភាពវិភាជ និងប្រសិទ្ធភាពប្រតិបត្តិការ។

28 ការស្ទង់មតិពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តឆ្នាំ 2019 ។

## តារាង S.1 សង្ខេប អនុសាសន៍ទាំងនេះ

| តារាង S.1 សេចក្តីសង្ខេបនៃអនុសាសន៍ | | | |
|---|---|---|---|
| វិស័យ | បញ្ហាប្រឈម | អនុសាសន៍រយៈពេលខ្លី (1-3 ឆ្នាំ) | អនុសាស្ត្ររយៈពេលមធ្យម (3 - 5 ឆ្នាំ) |
| គ្រប់វិស័យ | ការផ្សារភ្ជាប់ការចំណាយរបស់រដ្ឋាភិបាលជាមួយនឹងលទ្ធផលសមិទ្ធកម្ម | ▪ ពិនិត្យឡើងវិញ និងកែលម្អផែនការយុទ្ធសាស្ត្រថវិកាដើម្បីកំណត់សូចនាករលទ្ធផលជាក់ស្តែង និងព័ត៌មានសមិទ្ធកម្មដែលអាចប្រៀបធៀបបាននៅក្នុងរយៈពេលរាយការណ៍ទាំងមូល<br>▪ ផ្តល់សិទ្ធិអំណាចធំជាងមុនឱ្យនាយកកម្មវិធី លើការបែងចែកធនធាន និងធ្វើឱ្យពួកគេមានគណនេយ្យភាពចំពោះលទ្ធផលសមិទ្ធកម្ម<br>▪ ពិនិត្យ និងរៀបចំរចនាសម្ព័ន្ធថវិកាកម្មវិធីឡើងវិញនៅទូទាំងវិស័យ ដើម្បីគាំទ្រទំនាក់ទំនងរវាងការបែងចែក និងលទ្ធផលសមិទ្ធកម្ម | ▪ អនុវត្តទាំងស្រុងនូវការកំណត់ថវិកាផ្អែកលើសមិទ្ធកម្ម |
| | ដាក់ឱ្យដំណើរការការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម និងផ្សារភ្ជាប់ការដំឡើងប្រាក់បៀវត្សរ៍ទៅនឹងសមិទ្ធកម្ម | ▪ ដាក់ឱ្យដំណើរការការគ្រប់គ្រងផ្អែកលើសមិទ្ធកម្មសម្រាប់ការគ្រប់គ្រងកម្រិតកណ្តាល (អគ្គនាយកដ្ឋាន និងនាយកដ្ឋាន) នៅគ្រប់វិស័យ | ▪ ដាក់ឱ្យដំណើរការការគ្រប់គ្រងផ្អែកលើសមិទ្ធកម្មសម្រាប់មន្ត្រីរាជការទាំងអស់។ |
| វិស័យសុខាភិបាល | ការផ្លាស់ប្តូរពីការពឹងផ្អែក (ខ្លាំង) លើការចំណាយចេញពីហោប៉ៅខ្លួនទៅជាការបង្កើន និងការប្រើប្រាស់អោយមានប្រសិទ្ធភាពជាងមុននូវចំណាយប្រើប្រាស់ចំណាយសាធារណៈលើវិស័យសុខាភិបាល | ▪ បង្កើនប្រសិទ្ធភាពនៃការចំណាយលើសុខភាពសាធារណៈ: ការបែងចែកធនធានអោយកាន់តែច្រើនជាងមុនសម្រាប់កាន់តែច្រើនសម្រាប់ការថែទាំបង្ការ និងព្យាបាល និងកាត់បន្ថយចំណាយរដ្ឋបាលសុខភាព<br>▪ ធ្វើអោយប្រសើរឡើងនូវលទ្ធភាពទទួលបានធនធានរួមទាំងអ្នកជំនាញផ្នែកសុខភាព ការជំរុញរោគវិនិច្ឆ័យ និងការព្យាបាល ដើម្បីលើកទឹកចិត្តដល់ការប្រើប្រាស់មូលដ្ឋានសុខភាពសាធារណៈ<br>▪ បង្កើនចំណាយវិស័យសុខាភិបាលរបស់រដ្ឋាភិបាលសម្រាប់ការទូទាត់សេវាមូលនិធិសមធម៌សុខភាព (HEF) | ▪ ពិនិត្យឡើងវិញនូវកញ្ចប់អត្ថប្រយោជន៍ដែលរួមបញ្ចូលក្នុងគម្រោងគាំពារសុខភាពសង្គមបច្ចុប្បន្ន ដើម្បីកែលម្អការការពាររបស់គម្រោងទាំងនេះ និងបញ្ចៀសភាពលំបាកហិរញ្ញវត្ថុ<br>▪ បង្កើនផ្គត់ផ្គង់សេវាសុខភាពដោយកសាងបន្ថែមលើគម្រោងគាំពារសុខភាពសង្គមដែលមានស្រាប់ |
| | បង្កើនលទ្ធភាពទទួលបានសេវាសុខភាពប្រកបដោយសមធម៌សម្រាប់ជនក្រីក្រ | ▪ បង្កើនតុល្យភាពនៃការបែងចែកធនធានសម្រាប់ការផ្តល់សេវាដល់ទីតាំងនៅថ្នាក់ស្រុក ដោយផ្តោតលើខេត្តក្រីក្រដែលមានលទ្ធផលសុខាភិបាលយឺតយ៉ាវ | ▪ រួមបញ្ចូលគម្រោងគាំពារសង្គមដែលមានស្រាប់ទាំងអស់ ដែលរួមមាន (i) ការបង្កើតស្ថាប័នរដ្ឋបាល និងអភិបាលកិច្ចដើម្បីត្រួតពិនិត្យគម្រោងគាំពារសុខភាពរួម (ii) ការធ្វើសុខដុមនីយកម្ម កញ្ចប់អត្ថប្រយោជន៍សុខភាពនៃគម្រោងគាំពារសុខភាពទាំងអស់ និង (iii) ការធានានូវថវិកាគ្រប់គ្រាន់សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការថែទាំសុខភាពក្រោមគម្រោងសុខភាពរួម |
| វិស័យអប់រំ | ការកែលម្អការគ្រប់គ្រងធនធានមនុស្ស | ▪ បង្កើនគុណភាពព័ត៌មានអំពីការលើស និងកង្វះខាតសម្រាប់គោលបំណងគ្រប់គ្រង<br>▪ កែលម្អការជ្រើសរើសនិងការចាត់តាំងគ្រូបង្រៀន ដើម្បីធានាថា គ្រូបង្រៀនដែលបានជ្រើសរើសថ្មីនឹងហើយមាននៅកន្លែងធ្វើការដែលបានកំណត់ហើយមានអត្រាផ្ទេរចេញ-ចូលទាប<br>▪ ដាក់ឱ្យអនុវត្តការបញ្ចប់ការងារសម្រាប់គ្រូបង្រៀនមុខវិជ្ជាដែលមិនមានតម្រូវការ និងការចូលនិវត្តន៍មុនកាលកំណត់សម្រាប់គ្រូដែលមិនបង្រៀនគ្រប់ចំនួនម៉ោងអប្បបរមា | ▪ ផ្ទេរសិទ្ធិអំណាចទៅសាលារៀនដែលបំពេញតាមស្តង់ដារប្រសិទ្ធភាពសាលា ដើម្បីជួលគ្រូកិច្ចសន្យា និងបែងចែកធនធានសម្រាប់សាលាទាំងនោះ។<br>▪ ដាក់ឱ្យអនុវត្តអាជ្ញាបណ្ណគ្រូបង្រៀនដែលតម្រូវឱ្យមានការបន្តអាជ្ញាបណ្ណជាថ្មី រៀងរាល់ចំនួនឆ្នាំជាក់លាក់ ហើយដែលតម្រូវឱ្យមានសេវាចាំបាច់នៅក្នុងទីតាំងដាច់ស្រយាល |
| | ពង្រឹងក្របខ័ណ្ឌគណនេយ្យភាព | ▪ បង្កើតប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មប្រកបដោយប្រសិទ្ធភាពដែលកំណត់ការរំពឹងទុក និងគោលដៅច្បាស់លាស់សម្រាប់គ្រូបង្រៀន និងបុគ្គលិកអប់រំ ហើយផ្តល់មតិកែលម្អ និងការវាយតម្លៃជាប្រចាំដោយការប្រើប្រាស់បច្ចេកវិទ្យា<br>▪ ដាក់ឱ្យដំណើរការការដំឡើងប្រាក់បៀវត្សរ៍ដោយផ្អែកលើសមិទ្ធកម្ម និងការលើកកម្ពស់អាជីពសម្រាប់គ្រូបង្រៀន និងបុគ្គលិកអប់រំ<br>▪ បន្តពង្រឹងសមត្ថភាពគ្រូបង្រៀន | ▪ អនុវត្តន៍ការគ្រប់គ្រងតាមសាលារៀនអោយបានពេញលេញ និងពង្រឹងគណនេយ្យភាព<br>▪ អនុវត្តស្តង់ដារគ្រូបង្រៀន |

# ឧបសម្ព័ន្ធទី 1៖ កម្ពុជា – សូចនាករដែលបានជ្រើសរើស

| សូចនាករដែលបានជ្រើសរើស | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023F |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ប្រាក់ចំណូល និងកំណើនសេដ្ឋកិច្ច** | | | | | | | | | | | | | | | | |
| កំណើន ផ.ស.ស. (% ប្រចាំឆ្នាំ) | 6.7 | 0.1 | 6.0 | 7.1 | 7.3 | 7.4 | 7.1 | 7.0 | 6.9 | 7.0 | 7.5 | 7.1 | -3.1 | 3.0 | 5.2 | 5.5 |
| កំណើន ផ.ស.ស. សម្រាប់មនុស្សម្នាក់ (% ប្រចាំឆ្នាំ ពិត) | 4.9 | -1.4 | 4.4 | 5.5 | 5.8 | 5.8 | 5.7 | 5.5 | 5.5 | 5.6 | 6.2 | 5.8 | -4.2 | 1.8 | 4.0 | 4.4 |
| ផ.ស.ស. ក្នុងមនុស្សម្នាក់ៗ (ដុល្លារអាមេរិក, ចារឹក) | 741.3 | 734.7 | 810.0 | 889.6 | 949.4 | 1030.1 | 1105.1 | 1183.2 | 1281.3 | 1,397.0 | 1527.3 | 1667.8 | 1583.9 | 1624.7 | 1768.1 | 1913.6 |
| កំណើននៃការប្រើប្រាស់ឯកជន (% ប្រចាំឆ្នាំ) | 12.7 | -0.2 | 8.8 | 10.4 | 4.6 | 5.8 | 4.5 | 9.4 | 5.8 | 3.7 | 6.8 | 5.9 | -4.0 | -0.7 | 9.5 | 20 |
| ការវិនិយោគសរុប (% នៃ ផ.ស.ស. ចារឹក) | 17.3 | 20.1 | 16.2 | 16.0 | 17.4 | 18.7 | 20.9 | 21.4 | 21.7 | 21.9 | 22.6 | 23.4 | 24.0 | 25.8 | 30.9 | 32.8 |
| ការវិនិយោគសរុប - សាធារណៈ (% នៃ ផ.ស.ស. ចារឹក)[2] | - | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| **សាច់ប្រាក់ និងតម្លៃ** | | | | | | | | | | | | | | | | |
| អតិផរណា តម្លៃអ្នកប្រើប្រាស់ (% ប្រចាំឆ្នាំ, EOP ឬ MRV)[1] | 12.5 | 5.1 | 2.9 | 4.6 | 2.3 | 4.5 | 0.9 | 2.8 | 3.8 | 2.1 | 1.5 | 3.0 | 2.8 | 3.7 | 5.5 | 2.5 |
| អតិផរណា ថ្លៃទំនិញប្រើប្រាស់ (%ប្រចាំឆ្នាំ រយៈពេលជាមធ្យម) | 12.3 | 3.1 | 2.6 | 5.5 | 3.0 | 2.9 | 3.9 | 1.2 | 3.0 | 2.9 | 2.5 | 1.9 | 2.9 | 2.8 | 5.5 | 2.5 |
| សាច់ប្រាក់ជារួម (% នៃ ផ.ស.ស.) | 28.3 | 37.7 | 41.6 | 39.1 | 50.1 | 55.5 | 67.1 | 72.4 | 79.2 | 88.2 | 100.7 | 116.3 | 137.2 | 152.6 | 148.3 | 146.7 |
| ឥណទានក្នុងស្រុកដល់វិស័យឯកជន (% នៃ ផ.ស.ស.) | 23.5 | 24.6 | 27.6 | 28.3 | 38.7 | 52.0 | 62.7 | 74.3 | 81.7 | 86.7 | 99.6 | 114.2 | 139.6 | - | - | - |
| អត្រាការប្រាក់រយៈពេល 10 ឆ្នាំ (ជាមធ្យមប្រចាំឆ្នាំ)[1] | - | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| អត្រាប្តូរប្រាក់មធ្យម (រូបិយប័ណ្ណក្នុងស្រុកក្នុងមួយដុល្លារអាមេរិក) | 4060.0 | 4140.0 | 4044.0 | 4016.0 | 4033.0 | 4027.0 | 4030.0 | 4025.0 | 4058.0 | 4062.0 | 4067.0 | 4070.0 | 4077.4 | 4100.0 | 4150.0 | 4110.0 |
| សន្ទស្សន៍អត្រាប្តូរប្រាក់ពិត (2015=100) | 91.3 | 90.8 | 98.0 | 94.3 | 93.3 | 92.6 | 94.9 | 100.0 | 101.9 | 101.8 | 98.5 | 99.2 | 99.2 | 92.7 | 95.7 | 87.0 |
| **សារពើពន្ធ** | | | | | | | | | | | | | | | | |
| ចំណូល (% នៃ ផ.ស.ស) | 16.4 | 15.9 | 17.7 | 17.6 | 17.7 | 18.2 | 20.0 | 19.7 | 20.9 | 21.9 | 23.8 | 27.0 | 23.8 | 22.0 | 23.2 | 23.5 |
| ការចំណាយ (% នៃ ផ.ស.ស.) | 16.1 | 20.5 | 21.0 | 23.0 | 21.9 | 21.4 | 21.9 | 20.2 | 21.1 | 22.7 | 23.4 | 25.5 | 28.8 | 29.1 | 27.9 | 29.9 |
| ការទូទាត់ការប្រាក់ (% នៃ ផ.ស.ស.) | 0.2 | 0.2 | 0.3 | 0.3 | 0.5 | 0.7 | 0.7 | 0.3 | 0.4 | 0.4 | 0.4 | 0.4 | 0.6 | 0.5 | 0.5 | 0.6 |
| ការចំណាយមិនមែនការប្រាក់ (% នៃ ផ.ស.ស.) | 15.9 | 20.3 | 20.7 | 22.7 | 21.4 | 20.7 | 21.2 | 19.9 | 20.7 | 22.3 | 23.0 | 25.1 | 28.2 | 28.5 | 27.4 | 29.3 |
| សមតុល្យសារពើពន្ធសរុប (% នៃ ផ.ស.ស) | 0.3 | -4.6 | -3.3 | -5.4 | -4.2 | -3.2 | -1.9 | -0.5 | -0.2 | -0.8 | 0.4 | 1.5 | -4.9 | -7.0 | -4.7 | -6.4 |
| សមតុល្យសារពើពន្ធចម្បង (% នៃ ផ.ស.ស) | 0.5 | -4.4 | -3.0 | -5.1 | -3.7 | -2.5 | -1.2 | -0.2 | 0.2 | -0.4 | 0.8 | 1.9 | -4.3 | -6.5 | --4.2 | -5.9 |
| បំណុលទូទៅរបស់រដ្ឋាភិបាល (% នៃ ផ.ស.ស) | 27.8 | 29.1 | 28.7 | 29.7 | 31.6 | 31.3 | 31.8 | 31.2 | 29.1 | 30.3 | 28.3 | 28.1 | 33.9 | 35.2 | 33.7 | 35.6 |
| បំណុលសាធារណៈខាងក្រៅ (% នៃ ផ.ស.ស) | 24.6 | 26.4 | 27.2 | 27.0 | 30.5 | 31.6 | 31.5 | 31.2 | 29.1 | 29.7 | 28.5 | 27.9 | 33.9 | 35.1 | - | - |
| **គណនីខាងក្រៅ** | | | | | | | | | | | | | | | | |
| កំណើនការនាំចេញ, ពន្ធ G&S (ដុល្លារអាមេរិកមធ្យម, % ប្រចាំឆ្នាំ) | 20.2 | -24.4 | 22.9 | 11.4 | 16.0 | 16.8 | 10.3 | 7.5 | 9.0 | 9.4 | 12.3 | 8.5 | 2.1 | 11.2 | 31.9 | 19.0 |
| កំណើនការនាំចូល, ពន្ធ G&S (ដុល្លារអាមេរិកមធ្យម, % ប្រចាំឆ្នាំ) | 11.3 | -17.0 | 19.1 | 11.4 | 14.2 | 16.9 | 8.8 | 7.6 | 9.0 | 7.8 | 9.3 | 17.4 | 5.7 | 46.1 | 37.8 | 9.2 |
| ការនាំចេញទំនិញ (% នៃ ផ.ស.ស.) | 49.4 | 33.9 | 38.3 | 38.8 | 41.6 | 44.6 | 45.4 | 45.4 | 45.5 | 45.2 | 46.0 | 46.0 | 51.8 | 62.8 | 70.2 | 71.8 |
| ការនាំចូលទំនិញ (% នៃ ផ.ស.ស.) | 58.2 | 46.8 | 50.4 | 50.5 | 53.7 | 57.5 | 57.5 | 57.3 | 56.9 | 55.6 | 55.1 | 54.6 | 65.7 | 92.4 | 91.4 | 93.5 |
| សេវាកម្ម, សុទ្ធ (% នៃ ផ.ស.ស.) | 6.5 | 6.2 | 6.8 | 6.3 | 7.3 | 7.8 | 7.7 | 7.5 | 7.0 | 7.0 | 7.4 | 1.8 | 4.1 | -5.8 | -26.9 | -18.9 |
| សមតុល្យគណនីចរន្ត (លានដុល្លារអាមេរិកបច្ចុប្បន្ន) | -622.3 | -1120.4 | -1165.3 | -1309.3 | -1390.7 | -1489.3 | -1899.7 | -1680.6 | -1756.5 | -2140.5 | -2180.1 | -4107.7 | -3221.0 | -11492.8 | -7798.4 | -6256.3 |
| សមតុល្យគណនីចរន្ត (% នៃ ផ.ស.ស) | -6.0 | -10.8 | -10.0 | -10.1 | -9.9 | -9.6 | -11.3 | -9.2 | -8.8 | -9.7 | -8.9 | -15.2 | -12.4 | -42.6 | -26.3 | -19.3 |
| ការវិនិយោគផ្ទាល់ពីបរទេស, លំហូរចូលសុទ្ធ (% នៃ ផ.ស.ស) | 7.6 | 8.8 | 11.8 | 11.8 | 14.0 | 13.0 | 10.6 | 9.5 | 12.0 | 12.1 | 12.6 | 13.2 | 13.5 | 12.6 | -12.6 | -13.5 |
| បំណុលពហុភាគី (% នៃបំណុលខាងក្រៅសរុប)[2] | - | - | - | - | - | - | - | - | - | - | - | - | - | - | - | - |

| សូចនាករដែលបានជ្រើសរើស | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023F |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ចំនួនប្រជាជន ការងារ និងភាពក្រីក្រ** | | | | | | | | | | | | | | | | |
| ចំនួនប្រជាជនសរុប (លាននាក់) | 13.9 | 14.2 | 14.4 | 14.6 | 14.8 | 15.0 | 15.2 | 15.4 | 15.6 | 15.8 | 16.0 | 16.2 | 16.4 | 16.6 | 16.8 | 16.9 |
| កំណើនប្រជាជន (% ប្រចាំឆ្នាំ) | 1.7 | 1.5 | 1.5 | 1.5 | 1.5 | 1.4 | 1.4 | 1.4 | 1.3 | 1.3 | 1.2 | 1.1 | 1.2 | 1.2 | 1.1 | 1.1 |
| អត្រាគ្មានការងារធ្វើ 2 | 0.8 | 0.6 | 0.8 | 0.6 | 0.5 | 0.4 | 0.7 | 0.4 | 0.7 | 0.1 | 0.1 | 0.1 | 0.3 | 0.6 | - | - |
| វិសមភាព - មេគុណហ្គីនី 2 | - | - | - | - | - | - | - | - | - | - | - | - | - | - | - | - |
| អាយុសង្ឃឹមរស់ 2 | 66.5 | 67.4 | 67.7 | 68.4 | 68.9 | 69.3 | 69.7 | 69.9 | 70.2 | 70.5 | 70.6 | 70.7 | 70.4 | - | - | - |
| **ផ្សេងទៀត** | | | | | | | | | | | | | | | | |
| ផ.ស.ស. (LCU ចរន្ត, លាន) | 41968385.4 | 43056731.7 | 47047985.2 | 52068692.7 | 56616800.5 | 62219524.1 | 67740449.6 | 73422701.6 | 81241866.0 | 89830524.8 | 99544274.8 | 110014048.2 | 105891753.0 | 110505915.9 | 123036850.5 | 133448611.2 |
| ផ.ស.ស. (បច្ចុប្បន្ន, លានដុល្លារអាមេរិក) | 10337.0 | 10400.2 | 11634.0 | 12965.3 | 14038.4 | 15450.6 | 16809.0 | 18241.7 | 20020.2 | 22114.9 | 24476.1 | 27030.5 | 25970.2 | 26952.7 | 29647.4 | 32469.3 |
| LCU ផ.ស.ស. សម្រាប់មនុស្សម្នាក់ៗ (ពិត) | 2055920.0 | 2026907.2 | 2116702.2 | 2233632.6 | 2362497.2 | 2500274.8 | 2641674.7 | 2787803.8 | 2941584.8 | 3106427.6 | 3297922.6 | 3490805.5 | 3343715.1 | 3405004.0 | 3542598.8 | 3688869.9 |
| ចំណាត់ថ្នាក់សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស3 | 145 | 145 | 147 | 148 | 147 | 147 | 146 | 148 | 148 | 147 | 148 | 147 | 148 | 146 | - | - |
| CPIA (ការវាយតម្លៃ) 2 | 3.3 | 3.3 | 3.4 | 3.4 | 3.5 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.5 | - | - |
| ការគ្រប់គ្រងសេដ្ឋកិច្ច 2 | 3.8 | 3.8 | 4.0 | 3.8 | 3.8 | 3.8 | 3.8 | 4.0 | 4.0 | 4.0 | 4.2 | 4.2 | 4.2 | 4.2 | - | - |
| គោលនយោបាយរចនាសម្ព័ន្ធ 2 | 3.3 | 3.3 | 3.3 | 3.5 | 3.7 | 3.7 | 3.7 | 3.5 | 3.5 | 3.3 | 3.3 | 3.3 | 3.3 | 3.5 | - | - |
| គោលនយោបាយបរិយាប័ន្ននិងសមធម៌សង្គម 2 | 3.3 | 3.3 | 3.4 | 3.5 | 3.5 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.5 | 3.5 | 3.6 | - | - |
| ការគ្រប់គ្រងវិស័យសាធារណៈនិងស្ថាប័ន 2 | 2.7 | 2.7 | 2.7 | 2.8 | 2.8 | 2.8 | 2.8 | 2.7 | 2.7 | 2.7 | 2.6 | 2.6 | 2.7 | 2.8 | - | - |

**សម្គាល់៖** ".." បង្ហាញថាមិនមានព័ត៌មាន។ ប = ប៉ាន់ស្មាន ព = ព្យាករណ៍។ ទិន្នន័យពី MFMOD លើកលែងតែមានការសម្គាល់ដោយឡែក។
1/ មូលដ្ឋានទិន្នន័យ GEM របស់ធនាគារពិភពលោក; MRV = តម្លៃចុងក្រោយបំផុត។
2/ មូលដ្ឋានទិន្នន័យសូចនាករអភិវឌ្ឍន៍ពិភពលោក និងការប៉ាន់ប្រមាណរបស់បុគ្គលិកធនាគារពិភពលោក។
3/ ចំណាត់ថ្នាក់ HDI ក្នុងឆ្នាំ 2001 គឺទាក់ទងនឹងប្រទេសចំនួន 175 ហើយនៅឆ្នាំ 2010 ទាក់ទងទៅនឹងប្រទេសចំនួន 169 ។ ការកែលម្អវិធីសាស្ត្រក្នុងការគណនាសន្ទស្សន៍អភិវឌ្ឍន៍មនុស្សបាននាំឱ្យមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់នៅក្នុងចំណាត់ថ្នាក់របស់ប្រទេស។
**ប្រភព៖** មូលដ្ឋានទិន្នន័យ MFMOD, សូចនាករអភិវឌ្ឍន៍ពិភពលោករបស់ធនាគារពិភពលោក និងមូលដ្ឋានទិន្នន័យ GEM, មូលនិធិរូបិយវត្ថុអន្តរជាតិ ។

# គន្ថនិទ្ទេស


សហគ្រាសអង្គរ ឆ្នាំ 2023។ ចំណូលប្រចាំខែបានពីការលក់សំបុត្រទស្សនា អង្គរ ឆ្នាំ 2023។ សហគ្រាសអង្គរ រាជធានីភ្នំពេញ https://www.angkorenterprise.gov.kh/ .

Duma, Nombulelo ឆ្នាំ 2010 ។ "ដុល្លារូបនីយកម្មនៅកម្ពុជា៖ មូលហេតុ និងផលប៉ះពាល់លើគោលនយោបាយ។ របាយការណ៍ការងាររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ WP/11/49, មូលនិធិរូបិយវត្ថុអន្តរជាតិ, ទីក្រុងវ៉ាស៊ីនតោនឌីស៊ី https://www.imf.org/external/pubs/ft/wp/2011/wp1149.pdf .

Ferroni, F., JDM Fisher, និង L. Melosi ឆ្នាំ 2023។ "តើគោលនយោបាយរូបិយវត្ថុសហរដ្ឋអាមេរិកតឹងតែងប៉ុណ្ណា?" លិខិតធនាគារកណ្ដាលអាមេរិកទីក្រុងឈីកាហ្គោ លេខ 476 ខែមីនា។ ធនាគារកណ្តាលអាមេរិក ទីក្រុងឈីកាហ្គោ https://www.chicagofed.org/publications/chicago-fed-letter/2023/476#:~:text=How%20Tight%20Is%20U.S.%20Monetary%20Policy%3F,-By%20Filippo%20Ferroni&text=Over%20the%20past%2011%20months,and%20remained%20high%20throughout%202022.

មូលនិធិរូបិយវត្ថុអន្តរជាតិ 2022a. "របាយការណ៍បុគ្គលិកកម្ពុជាសម្រាប់ការពិគ្រោះយោបល់មាត្រា 4ន ឆ្នាំ 2022" ។ មូលនិធិរូបិយវត្ថុអន្តរជាតិ ទីក្រុងវ៉ាស៊ីនតោនឌីស៊ីhttps://www.imf.org/en/Publications/CR/Issues/2022/12/15/Cambodia-2022-Article-IV-Consultation-Press-Release-Staff-Report-and-Statement-by-the-526993.

———. 2022b. ទស្សនវិស័យសេដ្ឋកិច្ចពិភពលោក ខែមេសា ឆ្នាំ 2023៖ "ការងើបឡើងវិញថ្ម។ ទីក្រុងវ៉ាស៊ីនតោនឌីស៊ី៖ មូលនិធិរូបិយវត្ថុអន្តរជាតិ https://www.imf.org/en/Publications/WEO/Issues/2023/04/11/world-economic-outlook-april-2023#:~:text=The%20baseline%20forecast%20is%20for,to%201.3%20percent%20in%202023.

Kose, M. Ayhan និង Franziska Ohnsorge, eds. ឆ្នាំ 2023 ។ ការធ្លាក់ចុះនៃចក្ខុវិស័យកំណើនរយៈពេលវែង៖ និន្នាការ ការរំពឹងទុក និងគោលនយោបាយ។ វ៉ាស៊ីនតោនឌីស៊ី៖ ធនាគារពិភពលោក។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឆ្នាំ 2022 ។ របាយការណ៍ប្រចាំឆ្នាំ 2015 ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីភ្នំពេញ។

———. 2023. "របាយការណ៍ប្រចាំឆ្នាំ 2022-23" ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីភ្នំពេញ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ 2023a ។ ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈ ភាគ17 ខែកុម្ភៈ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រាជធានីភ្នំពេញ https://gdicdm.mef.gov.kh/en/2023/03/09/11009.html

———. 2023. ស្ថិតិហិរញ្ញវត្ថុរបស់រដ្ឋាភិបាល (GFS) និង តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) ។ https://mef.gov.kh/documents-category/publication/tofe/ .

ក្រសួងផែនការ វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ 2022។ គណនីជាតិ ឆ្នាំ 2022 ។ ក្រសួងផែនការ រាជធានីភ្នំពេញ។

———. 2023. សន្ទស្សន៍តម្លៃអ្នកប្រើប្រាស់ប្រចាំខែ ឆ្នាំ 2023 ។ ក្រសួងផែនការ រាជធានីភ្នំពេញ។

ក្រសួងទេសចរណ៍ ឆ្នាំ 2023 ។ ស្ថិតិទេសចរណ៍ប្រចាំខែ។ ក្រសួងទេសចរណ៍ រាជធានីភ្នំពេញ។

ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ 2018 ។ ការអប់រំនៅកម្ពុជា៖ ការរកឃើញពីបទពិសោធន៍របស់កម្ពុជាក្នុងតេស្ត PISA សម្រាប់ការអភិវឌ្ឍន៍។ ភ្នំពេញ៖ ក្រសួងអប់រំ យុវជន និងកីឡា។

ធនាគារជាតិនៃកម្ពុជា ឆ្នាំ 2022 ។ ទិន្នន័យស្ថិតិរូបិយវត្ថុ និងហិរញ្ញវត្ថុ ឆ្នាំ2022 ។ ធនាគារជាតិនៃកម្ពុជា រាជធានីភ្នំពេញ https://www.nbc.gov.kh/english/economic_research/monetary_and_financial_statistics_data.php .

———. 2023. របាយការណ៍ប្រចាំឆ្នាំ 2022 ។ ធនាគារជាតិនៃកម្ពុជា រាជធានីភ្នំពេញ https://www.nbc.gov.kh/publications/annual_reports.php .

Oudom. C. ឆ្នាំ 2012 "ភាពខុសគ្នានៃប្រាក់ឈ្នួលក្នុងវិស័យសាធារណៈ និងឯកជននៅកម្ពុជា និងផលប៉ះពាល់របស់វាចំពោះការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យសាធារណៈ។" និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សាកលវិទ្យាល័យអន្តរជាតិជប៉ុន នីហ្គាតា ប្រទេសជប៉ុន។

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ 2021 ។ ច្បាប់ស្តីពីការទូទាត់ថវិកាឆ្នាំ 2021។ រាជរដ្ឋាភិបាលកម្ពុជា http://www.treasury.gov.kh/document/ 5 .

———. 2023. ច្បាប់ថវិកា ឆ្នាំ2023។ រាជរដ្ឋាភិបាលកម្ពុជា https://mef.gov.kh/documents-category/law-and-regulation/ .

ធនាគារកណ្តាលអាមេរិក ទីក្រុងឈីកាហ្គោ ឆ្នាំ 2023។ "តើគោលនយោបាយរូបិយវត្ថុសហរដ្ឋអាមេរិកតឹងតែងប៉ុណ្ណា?" លិខិតធនាគារកណ្តាលអាមេរិកទីក្រុងឈីកាហ្គោ លេខ 476 ខែមីនា ឆ្នាំ 2023។ ធនាគារកណ្តាលអាមេរិក ទីក្រុងឈីកាហ្គោ https://www.chicagofed.org/publications/chicago-fed-letter/2023/476#:~:text=How%20Tight%20Is%20U.S.%20Monetary%20Policy%3F,-By%20Filippo%20Ferroni&text=Over%20the%20past%2011%20months,and%20remained%20high%20throughout%202022.

ធនាគារពិភពលោក ឆ្នាំ 2022 ។ "បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាខែធ្នូ" ធនាគារពិភពលោក ទីក្រុងវ៉ាស៊ីនតោនឌីស៊ី។

———. 2023a. បច្ចុប្បន្នភាពសេដ្ឋកិច្ចអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ខែមេសា ឆ្នាំ 2023៖ ការបង្កើតកំណើនឡើងវិញ។ វ៉ាស៊ីនតោនឌីស៊ី៖ ធនាគារពិភពលោក https://www.worldbank.org/en/publication/east-asia-and-pacific-economic-update .

———. 2023b. ទស្សនវិស័យសេដ្ឋកិច្ចសាកល ខែមករា ឆ្នាំ2023។ វ៉ាស៊ីនតោនឌីស៊ី៖ ធនាគារពិភពលោក។ https://www.worldbank.org/en/publication/global-economic-prospects .

———. 2023c. ទីផ្សារទំនិញ វ៉ាស៊ីនតោនឌីស៊ី៖ ធនាគារពិភពលោក https://www.worldbank.org/en/research/commodity-markets .

អង្គការសុខភាពពិភពលោក ឆ្នាំ 2015 ការពិនិត្យប្រព័ន្ធសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ប្រព័ន្ធសុខាភិបាលក្នុងរយៈពេលអន្តរកាល ភាគ 5 លេខ 2 ។ ទីក្រុងម៉ានីល៖ អង្គការសុខភាពពិភពលោក ការិយាល័យតំបន់សម្រាប់ប៉ាស៊ីហ្វិកខាងលិច https://apps.who.int/iris/bitstream/handle/10665/208213/9789290616917_eng.pdf?sequence=1&isAllowed=y



©Shutterstock/Nhut Minh Ho

THE WORLD BANK
IBRD • IDA | WORLD BANK GROUP
East Asia & Pacific

**ធនាគារពិភពលោក**
**ប្រចាំនៅប្រទេសកម្ពុជា**
អគារ Exchange Square
ជាន់ទី 10 IBRD និងជាន់ទី 11 IFC
ផ្លូវលេខ 51-61 និងផ្លូវលេខ 102-106
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ភ្នំពេញ ប្រទេសកម្ពុជា
វេបសាយ: www.worldbank.org/cambodia